**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# មុខងារ និងធនធានរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ណុំ វណ្ណា**

លោក **គាំង គីមហាប់**

សាស្ត្រាចារ្យណែនាំ

អនុបណ្ឌិត **ហៀង សាង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំនិស្សិត **ណុំ ចណ្ណា** និងនិស្សិត **ភាំង គីមហាប់** សូមសម្តែងនូវការដឹងគុណ និងកតញ្ញូតាធម៌ចំពោះលោកឪពុក អ្នកម្តាយ ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាង រួមទាំងកម្លាំងកាយ កម្លាំងចិត្ត ដោយផ្តល់ជាសម្ភារ និងផ្តល់នូវព្រហ្មវិហារធម៌ល្អៗ ក្នុងការចិញ្ចឹមបីបាច់ អប់រំ និងបានផ្តល់ជាដំបូន្មានល្អៗ ដែលនោះជាលទ្ធភាពដ៏វិសេសវិសាលមួយដែលលោកផ្តល់ឲ្យកូន ដើម្បីឲ្យរូបកូនបានរស់រានមានជីវិត និងបានសិក្សារៀនសូត្រចេះដឹងដល់កម្រិតនេះ ដែលវាជាមូលដ្ឋានគ្រឹះមួយ និងជាយាននាំឲ្យកូនមានសមត្ថភាពសមរម្យ ប្រកបដោយគុណធម៌ សេចក្តីថ្លៃថ្នូរ ជាសិស្សល្អ និស្សិតល្អ មិត្តល្អ និងពលរដ្ឋល្អនៅក្នុងសង្គម ដែលលទ្ធភាពនេះហើយបានរួមចំណែកជួយលើកតម្កើងដល់កិត្តិយសគ្រួសារ និងចូលរួមស្តារ កសាង និង អភិវឌ្ឍន៍សង្គមជាតិនាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម បណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងលោក លោកស្រី សាកលវិទ្យាធិការរង និងលោក លោកស្រីជាបុគ្គលិក មន្ត្រីរាជការ គ្រប់ការិយាល័យ និងគ្រប់ផ្នែកនៃសាកលវិទ្យាល័យ ដែលបានផ្តល់លទ្ធភាព និងបានបង្កលក្ខណៈវិជ្ជមានផ្សេងៗ សំដៅធានាដល់កាលានុវត្តភាព និងប្រសិទ្ធភាពនៃការសិក្សា និងដូចជាការឈានដល់ការស្រាវជ្រាវនាពេលនេះ។

យើងខ្ញុំសូមថ្លែងនូវការដឹងគុណដល់លោក លោកស្រី សាស្ត្រាចារ្យ ដែលបានធ្វើពលិកម្មទាំងកម្លាំងកាយ និងកម្លាំងចិត្តខិតខំបង្ហាត់បង្រៀនយើងខ្ញុំទាំងពីរនាក់ក៏ដូចជានិស្សិតរួមជំនាន់តាំងពីឆ្នាំសិក្សាមូលដ្ឋាន រហូតមកដល់ពេលនេះ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណ យ៉ាងស្មោះស្ម័គ្រ និងធំធេង ចំពោះលោកសាស្ត្រាចារ្យ អនុបណ្ឌិត **ហៀង សាង** ដែលជាសាស្ត្រាចារ្យដឹកនាំផ្ទាល់ក្នុងការសិក្សាស្រាវជ្រាវសារណានេះ ព្រមទាំងបានផ្តល់នូវការលើកទឹកចិត្ត ផ្តល់ដំបូន្មានល្អៗ និងមតិណែនាំកែលម្អប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ គួរជាទីគោរពត្រង់ត្រាប់ ដើម្បីឲ្យយើងខ្ញុំសម្រេចបានជាស្ថាពរក្នុងការស្រាវជ្រាវ និងរៀបចំសារណានេះឡើងបានដោយជោគជ័យ។

# អារម្ភកថា

ស្ថិតនៅក្នុងបរិបទ នៃដំណើរការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈ នៅក្នុងប្រទេសកម្ពុជា សម្រាប់ជាយានជំនិះមួយនាំឲ្យនាវាសេដ្ឋកិច្ច និងនយោបាយរបស់កម្ពុជា រីកចម្រើនឈានចូលដល់ការអភិវឌ្ឍលើគ្រប់វិស័យទាំងក្នុងតំបន់ និងទូទាំងពិភពលោក។ ជាងនេះទៅទៀតការធ្វើកំណែទម្រង់ខាងផ្នែកប្រព័ន្ធរដ្ឋបាលសាធារណៈ នេះវាជាមុំទី៣ នៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលដែលកំពុងអនុវត្តសព្វថ្ងៃ ព្រមទាំងជាផ្នែកនៃប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ដែលប្រមុខរាជរដ្ឋាភិបាលកំពុងនឹងរៀបចំ អនុវត្តនូវគោលនយោបាយនេះជាបន្តបន្ទាប់ ដើម្បីសម្រេចនូវគោលដៅមួយដែលរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋគ្រប់រូបរមែងតែងតែប្រាថ្នាចង់បាន ចង់ឃើញនូវភាពរីកចម្រើននោះគឺ ការគ្រប់គ្រងរដ្ឋបាល ឆ្ពោះទៅរក **"រដ្ឋបាលមូលដ្ឋាន"** ដែលជាប្រព័ន្ធមួយប្រភេទដែលនៅកៀកជិតស្និទ្ធជាមួយប្រជាពលរដ្ឋបំផុត។ ដោយមើលឃើញនូវសក្តានុពលដូចនេះហើយយើងខ្ញុំសូមលើកយកនូវប្រធានបទដែលជានិន្នាការមួយសម្រាប់ជួយសម្រួល ក្នុងដំណើរការអនុវត្តនាពេលបច្ចុប្បន្នមកបង្ហាញ យោងលើកម្រិតនៃការសិក្សាស្រាវជ្រាវ និងជាពិសេសការប្រមូលផ្តុំចងក្រងឯកសារពាក់ព័ន្ធនានា។ ប្រធានបទដែលយើងខ្ញុំបានស្រាវជ្រាវ និងលើកយកមកបង្ហាញគឺ **"មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ"**។

យើងខ្ញុំសង្ឃឹមថា សំណេរសារណាក្រោមប្រធានបទខាងលើនេះ នឹងក្លាយជាវិភាគទានមួយរួមចំណែកក្នុងវិស័យច្បាប់ ជាពិសេសក្នុងវិស័យរដ្ឋបាលសាធារណៈ និងចំពោះអ្នកសិក្សាជំនាន់ក្រោយ អ្នកស្រាវជ្រាវ និងអ្នកបម្រើការងារក្នុងវិស័យពាក់ព័ន្ធ ដើម្បីជាផលប្រយោជន៍ដ៏វិសេសវិសាលក្នុងការពង្រឹងផ្សព្វផ្សាយ នៃចំណេះដឹងខាងផ្នែករដ្ឋបាលសាធារណៈនេះ។ គោលបំណងទីពីរគឺការតម្កល់នូវស្នាដៃនេះនៅបណ្ណាល័យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដើម្បីជាគុណប្រយោជន៍ដល់និស្សិតជំនាន់ក្រោយ និងក្លាយជាអនុស្សាវរីយ៍មួយចំពោះសាកលវិទ្យាល័យដែលយើងខ្ញុំបានសិក្សា ក៏ដូចជាកន្លែងបណ្តុះនូវគំនិត ចំណេះដឹងបញ្ញា ស្មារតី និងមានសមត្ថភាពសមស្របដែលអាចឲ្យយើងខ្ញុំមានលទ្ធភាពចងក្រងជាសារណានេះឡើងប្រកបដោយភាពជោគជ័យ គួរជាទីមោទនភាព។

យើងខ្ញុំទាំងពីរសូមស្វាគមន៍ជានិច្ច នូវរាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ និងលោក លោកស្រី គ្រប់ស្រទាប់អ្នកសិក្សាទាំងអស់ ដោយចាត់ទុកមតិរិះគន់ទាំងនោះជាប្រទីបបំភ្លឺផ្លូវយ៉ាងត្រចះត្រចង់ ឈានឆ្ពោះទៅរកភាពជោគជ័យ និងកែលម្អនូវចំណុចខ្វះខាតក្នុងការសិក្សាស្រាវជ្រាវបន្តទៀតនាពេលអនាគត។

# មាតិកា

**មាតិកា**..................................................i
**អក្សរកាត់**..................................................iii

## សេចក្តីផ្តើម

## ជំពូកទី១

## សញ្ញាណទូទៅ នៃមុខងារ និងធនធាននៅកម្ពុជា

១. សារតាអភិបាលកិច្ចមូលដ្ឋាន..................................................០៤
២. អ្វីជាមុខងារ និងធនធាន?..................................................០៩
៣. មុខងាររបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ..................................................១០
៤. ប្រភេទនៃមុខងារ..................................................១០

## ជំពូកទី២

## តួអង្គសំខាន់ៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១. ទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ..................................................២០
២. អំពីក្រុមប្រឹក្សា..................................................២០
៣. អាណត្តិក្រុមប្រឹក្សា..................................................២២
៤. តួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា..................................................២៣
៥. អង្គប្រតិបត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ..................................................២៥
៦. សិទ្ធិរបស់ក្រុមប្រឹក្សាជាមួយគណៈអភិបាល..................................................២៩
៧. នាយករដ្ឋបាល..................................................៣០
៨. បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ..................................................៣១
៩. គណនេយ្យភាព..................................................៣៣
១០. ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ..................................................៣៥

## ជំពូកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ


១. ថវិកានៅថ្នាក់ក្រោមជាតិ..........៣៩

២. របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ..........៤១

៣. ថវិការបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ..........៤៤

៤. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់..........៤៨

៥. ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់..........៥០

៦. ការកសាងផែនការឃុំ សង្កាត់..........៥១

៧. អត្ថន័យនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់..........៥៣

**សន្និដ្ឋាន និងអនុសាសន៍**..........៥៦

**ឯកសារពិគ្រោះ**..........៥៨

**សន្ទានុក្រម**..........៦១

**ឧបសម្ព័ន្ធ**..........៦៧

# អក្សរកាត់

( ACRONYM )

**គ.ជ.អ.ប** ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**គ.ជ.ប** ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**អនក្រ.បក** ៖ អនុក្រឹត្យ ស្តីពីការបង្កើតស្ថាប័ននានា

**សជណ** ៖ សេចក្តីជូនដំណឹង

**ប្រក.បស្ថ** ៖ ប្រកាសរបស់ក្រសួងបរិស្ថាន

**ប្រ.ក.ប.ស្ថ** ៖ ប្រកាសរបស់ក្រសួងបរិស្ថាន

**ក.អ.ជ.ប្រក** ៖ ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ប្រ.ក** ៖ ប្រកាស

**សណន** ៖ សេចក្តីណែនាំ

**ផ.អ.៣.ទី២** ៖ ផែនការណ៍អនុវត្តបីឆ្នាំដំណាក់កាលទី២(២០១៥.២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(ផអ៣ទី២)

**ន.ប.ប** ៖ នាយកដ្ឋានបណ្តុះបណ្តាល

**គ.ផ.ថ** ៖ គណៈកម្មាធិការកសាងផែនការ និងថវិការឃុំ សង្កាត់

**NCDD** : The national Committee for Sub-National Democratic Development

**PILAC3** : The Project for Capacity Development for Implementing the Organic Law at The Capital and Provincial level

**NGO** : Non- Government Organization

# សេចក្តីផ្តើម

នៅក្នុងការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលសាធារណៈ ក្នុងបណ្តាប្រទេសនីមួយៗនៅលើពិភពលោក មិនថាប្រទេសនោះជាប្រទេសស្ថិតក្នុងប្រទេសអភិវឌ្ឍ ឬប្រទេសកំពុងអភិវឌ្ឍ ឬមួយជាបណ្តាប្រទេសដែលមិនទាន់អភិវឌ្ឍក៏ដោយ បញ្ហាមួយចំនួនដែលអ្នកដឹកនាំមែងតែងតែជួបប្រទះ គឺជាបញ្ហានៃការផ្តល់សេវាសាធារណៈ ការគ្រប់គ្រង ការត្រួតពិនិត្យនូវមុខងារ និងធនធានរបស់មន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ពោលគឺសំដៅដល់ការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលសាធារណៈឲ្យបានល្អប្រសើរឈានឆ្ពោះទៅរកភាពជោគជ័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការដឹកនាំប្រទេស។ យ៉ាងណាមិញ ការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលសាធារណៈនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននៅមានកម្រិតនៅឡើយ។ ជាក់ស្តែងប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិមិនទាន់មានសមត្ថភាព លទ្ធភាពពេញលេញក្នុងការអនុវត្តនូវមុខងារ ដែលថ្នាក់ជាតិបានផ្ទេរ ឬតាមរយៈការធ្វើប្រតិភូកម្មឲ្យនៅឡើយទេ។ ដោយហេតុថាធនធាន នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធនធានទាំងនោះសំដៅលើធនធានមនុស្ស ថវិកា ហិរញ្ញវត្ថុ បច្ចេកទេស គឺនៅពឹងផ្អែកមកថ្នាក់ជាតិក្នុងការចុះជួយសម្រុះសម្រួលដើម្បីអភិវឌ្ឍនូវសមត្ថភាពរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

កត្តាមួយទៀតដែលជាបញ្ហាមួយ ដែលបានធ្វើឲ្យប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈមានភាពយឺតយ៉ាវព្រោះប្រទេសជាតិ របស់យើងបានធ្លាក់ចូលក្នុងភ្លើងសង្គ្រាមផ្ទៃក្នុងដ៏រ៉ាំរ៉ៃអូសបន្លាយអស់រយៈពេលជាងបីទសវត្សរ៍ ដែលបានធ្វើឲ្យប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមានសភាពប្រែប្រួលទៅតាមបរិបទនៃសង្គម ដូចជាករណីបញ្ហាអសន្តិសុខសង្គម បញ្ហានយោបាយ អ្នកដឹកនាំត្រូវជ្រើសរើសនូវការដឹកនាំតាមបែប **"មជ្ឈការ"** ដែលជាប្រព័ន្ធមួយគ្រប់គ្រងអំណាចនៅថ្នាក់កណ្តាល ដែលគេហៅថាជាអំណាចប្រមូលផ្តុំសំដៅធ្វើយ៉ាងណាឲ្យរដ្ឋបាលថ្នាក់កណ្តាលខ្លាំងសិន ទើបគេអភិវឌ្ឍនៅថ្នាក់ក្រោមជាតិជាក្រោយ។ បន្ទាប់មកទៀតក្រោយពីប្រទេសជាតិមានសុខសន្តិភាពឡើងវិញ ប្រមុខរាជរដ្ឋាភិបាលបានគិតគូរចាប់យកការគ្រប់គ្រងប្រទេស ដោយជ្រើសរើសយកប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការជំនួសវិញ ដែលជារបបគ្រប់គ្រងដោយមានការប្រគល់ ឬការធ្វើប្រតិភូកម្ម នូវមុខងារ និងធនធានទៅឲ្យស្ថាប័ននៅក្រោមបង្គាប់ សំដៅដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច លើកកម្ពស់សមធម៌ តម្រូវការ និងការឆ្លើយតបចំពោះប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលជាយន្តការមួយសមស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។

ប្រធានបទដែលលើកយកមកសិក្សានេះ គឺមានលក្ខណៈពិសេសសម្រាប់មន្ត្រីរាជការស៊ីវិល ក៏ដូចជាសិស្ស និស្សិត និងសាធារណជនគ្រប់ស្រទាប់អ្នកសិក្សាងាយស្រួល ស្វែងយល់អំពីមុខងារ

និងធនធានរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន។ ព្រមទាំងជាគន្លឹះមួយសម្រាប់ជួយបង្ហាញឲ្យឃើញនូវឫសគល់បញ្ហា ទីតាំងនៃបញ្ហា ដំណោះស្រាយនៃបញ្ហា និងការអភិវឌ្ឍនានានៅក្នុងសង្គមជាតិ។

ការលើកប្រធានបទ **មុខងារ និងធនធាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ដើម្បីធ្វើការសិក្សាស្រាវជ្រាវគឺជាធាតុចាំបាច់មួយដែលជួយជំរុញឲ្យយន្តការក្នុងការឆ្លើយតប និងតម្រូវការនានារបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ ដែលបានអនុវត្តកន្លងមក។ ការសិក្សាស្រាវជ្រាវនេះ ផ្អែកលើលក្ខខណ្ឌគតិយុត្ត ទ្រឹស្តីវិជ្ជា និងសង្គមវិជ្ជា ក៏ដូចជាបញ្ហាដែលធ្លាប់កើតឡើងកន្លងមក និងរកឃើញនូវវិធានការថ្មីៗ ដើម្បីចូលរួមដោះស្រាយចំណោទបញ្ហាសំខាន់ៗដូចជា៖

១.តើមុខងារ និងធនធាននៅរដ្ឋបាលថ្នាក់ក្រោមជាតិមានការវិវត្តន៍យ៉ាងដូចម្តេច?

២.តើតួអង្គសំខាន់ៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពជាមួយនរណាខ្លះ?

៣.តើតួអង្គសំខាន់ៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទី ភារកិច្ចអ្វីខ្លះ?

៤.តើប្រភពចំណូលនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានពីអ្វីខ្លះ?

ចំពោះគោលបំណងនៃការស្រាវជ្រាវ ដោយយល់ឃើញថា ការអភិវឌ្ឍក្នុងវិស័យរដ្ឋបាលសាធារណៈកំពុងនឹងត្រូវបានយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល ក៏ដូចជាការគិតគូរដល់សុខទុក្ខរបស់ប្រជាពលរដ្ឋ ដែលសំដៅដល់ការឆ្លើយតប នឹងតម្រូវការនានារបស់ប្រជាពលរដ្ឋ ដ៏ដូចជាការបម្រើសេវាឆាប់រហ័សស្របគោលការណ៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងជាធាតុមួយយ៉ាងសំខាន់សម្រាប់ការសិក្សាស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ ម្យ៉ាងវិញទៀតយើងមិនទាន់ឃើញមានសំណេរច្រើននៅឡើយ ដែលបានសរសេរអំពីវិស័យរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ជាក់ស្តែងសារណាបញ្ចប់ការសិក្សា លើប្រធានបទក្នុងវិស័យរដ្ឋបាលសាធារណៈមានតែមួយចំនួនតែប៉ុណ្ណោះដែលមានដាក់តាំងនៅក្នុងបណ្ណាល័យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចយើង ដែលវាជាឧបសគ្គមួយសម្រាប់និស្សិតជំនាន់ក្រោយដែលមានបំណងចង់សិក្សាស្វែងយល់ អំពីការគ្រប់គ្រងនៃប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះផងដែរគោលបំណង ដែលសំខាន់គឺចង់ឲ្យសំណេរសារណានេះបានក្លាយជាវិភាគទានមួយចំណែកសម្រាប់ជាឧត្តមប្រយោជន៍មួយក្នុងវិស័យអប់រំ សម្រាប់អ្នកសិក្សាជំនាន់ក្រោយក៏ដូចជាអ្នកដែលធ្វើការងារក្នុងវិស័យពាក់ព័ន្ធក្នុងការសិក្សាស្វែងយល់។

ការសិក្សាស្រាវជ្រាវនេះ មានវិសាលភាពក្នុងរង្វង់នៃបរិបទជាតិ ដែលសំដៅដល់មុខងារ និងធនធាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ បទបញ្ញា នីតិវិធី ឯកសារ

និងទិន្នន័យចម្បងៗដែលពាក់ព័ន្ធ នឹងប្រធានបទ ស្ដីពី **មុខងារ និងធនធាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ដែលមានដូចជា៖

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យ ស្ដីពី លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ឯកសារច្បាប់នានា ដែលទាក់ទងនឹងមុខងារ
- ឯកសារច្បាប់នានា ដែលទាក់ទងនឹងហិរញ្ញវត្ថុ
- ឯកសារច្បាប់នានា ដែលទាក់ទងនឹងការរៀបចំ តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បឋកថា ស្ដីពី កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ សម្ដេចក្រឡាហោម **ស ខេង**
- ប្រវត្តិអភិបាលកិច្ចមូលដ្ឋាន វិមជ្ឈការ និងវិសហមជ្ឈការ និងក្របខ័ណ្ឌច្បាប់សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ដោយ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ
- វិមជ្ឈការ និងវិសហមជ្ឈការ បោះពុម្ពដោយ ន.ប.ប ក្រសួងមហាផ្ទៃ
- ឯកសារបន្ទាប់បន្សំដទៃទៀតដែលទាក់ទិននឹងប្រធានបទ។

<u>វេបសាយ ៖</u>

www.ncdd.gov.kh

ការសិក្សាលើប្រធានបទនេះ គឺផ្ដោតលើខ្លឹមសារសំខាន់ៗ ៤ជំពូក ដែលមានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ជំពូក១ រៀបរាប់អំពីសញ្ញាណទូទៅនៃមុខងារ និងធនធាននៃការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដូចជាការរំលឹកអំពីសារតាអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា។
- ជំពូក២ និយាយអំពីតួអង្គសំខាន់ៗ ដែលបកស្រាយអំពីតួនាទី ភារកិច្ច របស់តួអង្គសំខាន់ៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ជំពូក៣ និយាយអំពីការគ្រប់គ្រងទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបកស្រាយអំពីថវិការបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ និងប្រភពចំណូលចំណាយនានា។
- ចំណែកឯជំពូកចុងក្រោយគឺជាសេចក្ដីសន្និដ្ឋាន និងអនុសាសន៍ ដែលបកស្រាយអំពីការប្រឈម នឹងបញ្ហានានា និងវិធានដំណោះស្រាយ។

# ជំពូកទី ១

# សញ្ញាណទូទៅនៃមុខងារ និងធនធាននៅកម្ពុជា

## ១.សាវតារអភិបាលកិច្ចមូលដ្ឋាន

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានវប្បធម៌ អរិយធម៌ និងប្រពៃណីទំនៀមទម្លាប់ដ៏ប្រពៃ និងចំណាស់មួយក្នុងចំណោមបណ្តាប្រទេសនានានៅលើសកលលោក។ យ៉ាងណាមិញ ប្រទេសកម្ពុជាយើងនាពេលនោះក៏ជាប្រទេសមួយ ដែលមានប្រព័ន្ធអភិបាលកិច្ចសម្រាប់ការគ្រប់គ្រងក្នុងវិស័យរដ្ឋបាលរបស់ខ្លួនយ៉ាងរឹងមាំតាំងពីសម័យអតីតកាល។

ការស្រាវជ្រាវនេះ គឺគ្រាន់តែជាការបង្ហាញត្រួសៗតែប៉ុណ្ណោះ អំពីការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាំងពីសម័យបុរាណ រហូតដល់សម័យទំនើបនាពេលបច្ចុប្បន្ននេះ។

ជាក់ស្តែង តាមការសិក្សាស្រាវជ្រាវខ្លះៗបានបង្ហាញថាមុនពេលដែលបារាំងមកដល់កម្ពុជា ទឹកដីប្រទេសកម្ពុជា ចែកជាខេត្ត។ ខេត្តចែកជាស្រុក។ ស្រុកចែកជាឃុំ ហើយឃុំចែកជាភូមិ និងតំបន់ខ្លះទៀតស្រុកចែកជាឃុំ។ នៅពេលដែលបារាំងបានចូលមកគ្រប់គ្រងកម្ពុជាបារាំងបាន ចេញក្រឹត្យមួយដែលចុះនៅថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ១៩០៨[1] ជាក្របខណ្ឌច្បាប់ដំបូងបំផុតនៅកម្ពុជាដែលស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ។ គោលបំណងនៃក្រឹត្យនេះគឺ ផ្តល់និយមន័យឲ្យឃុំឲ្យបានច្បាស់លាស់ រៀបចំឃុំផ្តល់ផលប្រយោជន៍ សិទ្ធិ អំណាច និងធនធានខ្លះៗទៅឲ្យឃុំតាមរយៈមេឃុំ ហើយមេឃុំត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ ប៉ុន្តែក្រឹត្យនេះមិនបានផ្តល់អំណាចទៅឲ្យភូមិឡើយ។ ក្រោយមកទៀតបារាំងបានចេញក្រឹត្យចំនួនពីរទៀតដែលក្រឹត្យនោះចុះនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩១៩ ដែលមានគោលបំណងប្រគល់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិឲ្យឃុំ ហើយការគ្រប់គ្រងរដ្ឋបាលឃុំ ហាក់បីដូចជាខិតកាន់តែជិតជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន។

យោងតាមស្មារតីនៃក្រឹត្យដែលបានចូលជាធរមាននៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩០៨ ទឹកដីកម្ពុជាចែកចេញជាខេត្ត ស្រុក ឃុំ និងភូមិ និងបានប្តូរពីពាក្យថា**ចៅហ្វាយស្រុក** មកជាពាក្យ **ចៅហ្វាយខេត្ត** ហើយពាក្យថា **មេស្រុក** ក្លាយទៅជា **មេឃុំ** វិញ[2] ។

ក្រោយមកទៀតមានព្រះរាជក្រមមួយនៅឆ្នាំ១៩៥៩ ដែលបានតម្រូវឲ្យមានការបោះឆ្នោតជ្រើសរើសក្រុមជំនុំឃុំ ដោយផ្តល់នូវឋានៈឃុំជានីតិបុគ្គល ដូចក្នុងឆ្នាំ១៩២៦។ ក្រុមជំនុំឃុំនេះ

---

[1] ប្រវត្តិនៃអភិបាលកិច្ចមូលដ្ឋាន វិមជ្ឈការ និងវិសហមជ្ឈការ និងក្របខ័ណ្ឌច្បាប់សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ដោយ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បោះពុម្ពផ្សាយនៅខែមីនា ឆ្នាំ២០០៨ ទំព័រ ២ ។

[2] បាឋកថា ស្តីពីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បោះពុម្ពផ្សាយ ខែវិច្ឆិកា ឆ្នាំ២០១៥ ទំព័រ ៥។

មានអាណត្តិ ០៤ឆ្នាំ។ ផ្អែកតាមក្រមនេះ មេឃុំ និងជំទប់ត្រូវជ្រើសរើសពីក្រុមជំនុំឃុំដែលជាប់ឆ្នោតដោយសំឡេងភាគច្រើន។ ចៅហ្វាយខេត្តគឺជាអ្នកចេញដីកាក្នុងការតែងតាំងមេឃុំ និងក្រុមជំនុំឃុំ។ បន្ទាប់ពីការធ្វើសមាជជាតិលើកទី២០ នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៦៥ មក ពាក្យ **សង្កាត់** ត្រូវបានគេប្រកាសដាក់ឲ្យប្រើប្រាស់សម្រាប់ឃុំនៅក្នុងទីក្រុង។ ទន្ទឹមនឹងនេះផងដែរពាក្យថា **អភិបាល** ត្រូវបានគេយកមកប្រើជំនួសពីពាក្យថា **ចៅហ្វាយខេត្ត ក្រុង ស្រុក** ។

ដោយឡែកនៅក្នុងរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥) ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិដែលអនុវត្តដោយប្រព័ន្ធវិមជ្ឈការ គឺមានតែចែងក្នុងរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ ដោយសារនៅក្នុងសម័យនោះប្រទេសកម្ពុជាបានជួបប្រទះនូវសង្គ្រាមផ្ទៃក្នុង។ ជាមួយគ្នានេះផងដែរការដឹកនាំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) រចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលត្រូវបានបំផ្លាញចោលទាំងស្រុង ដែលរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិតេយ្យនេះមានតែ ២១មាត្រាតែប៉ុណ្ណោះ ហើយគេផ្តោតសំខាន់ទៅលើអំណាច **យោធា** និង **អង្គការ** ។ នៅក្នុងរបបនេះប្រជាជនស្លូតត្រង់ជាង ៣លាននាក់ត្រូវបានស្លាប់បាត់បង់ជីវិត ព្រមទាំងសំណង់ ហេដ្ឋារចនាសម្ព័ន្ធនានា សាសនា រូបិយវត្ថុ ត្រូវបានគេលុបបំបាត់ចោល ដោយប្រជាជនត្រូវជម្លៀសទៅទីជនបទដើម្បីទៅធ្វើស្រែរចម្ការ ព្រមទាំងរស់យ៉ាងលំបាកវេទនា ដោយកូនត្រូវឃ្លាតពីទ្រូងឪពុកម្តាយ ប្តីប្រពន្ធព្រាត់ព្រាស់ បងប្អូន មិត្តភ័ក្រ្ត ជីដូនជីតា ត្រូវរស់នៅដោយភាពភ័យខ្លាច ធ្វើការងារហួសកម្លាំងបរិភោគអាហារមិនគ្រប់គ្រាន់ បុរសស្ត្រីគ្មានសិទ្ធិរើសគូស្រករ ស្ត្រីខ្លះត្រូវបានបង្ខំឲ្យរៀបការជាមួយបុរសមិនស្គាល់ ជាមួយយោធាពិការ នឹងត្រូវបានគេជម្លៀសឲ្យទៅធ្វើការនៅតំបន់ដាច់ស្រយាលនៅពេលពួកនាងប្រកែក។ លើសពីនេះទៅទៀតនោះ **ខ្មែរក្រហម** បានអប់រំឲ្យមនុស្សគ្រប់គ្នាត្រូវស៊ើបអង្កេតពីគ្នាទៅវិញទៅមក ដោយគេបាននិយាយថាពួកអង្គការគឺជាអង្គការភ្នែកម្នាស់ ដែលអាចត្រួតពិនិត្យមើល សង្កេតឃើញ គ្រប់សកម្មភាព ក្តាប់បានគ្រប់រឿងដែលគ្មានជនណាអាចលាក់បាំងបានឡើយ ចំពោះជនណាដែលជាប់ មន្ទិលសង្ស័យរបស់អង្គការហើយ ត្រូវបានអង្គការប្រើពាក្យស្លោកមួយថា អង្គការហៅថាសមមិត្តទៅរៀនសូត្រ អ្នកដែលត្រូវបានអង្គការហៅទៅហើយគេមិនដែលឃើញត្រឡប់មកជួបជុំជាមួយក្រុមគ្រួសារវិញឡើយ។

ក្រោយការរំដោះនៅថ្ងៃទី ០៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានផ្លាស់ប្តូរលើគ្រប់វិស័យរួមទាំងវិស័យ សេដ្ឋកិច្ច សង្គមកិច្ច ព្រមទាំងវិស័យរដ្ឋបាលផងដែរ។ ទន្ទឹមនឹងនេះនៅចុងឆ្នាំ១៩៧៩ មានក្រសួងស្ថាប័នចំនួន១២ ត្រូវបានបង្កើតឡើង និងមានខេត្តចំនួន១៨ និងក្រុង០២ ត្រូវបានរៀបចំចំណុះក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។ នៅថ្ងៃទី ០១ ខែឧសភា ឆ្នាំ១៩៨១ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានធ្វើការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដោយមានប្រជាជនចំនួន

៣.៤១៧.៣៣៩នាក់(៩៧,៨២%)បានទៅបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រចំនួន ១១៧រូប ក្នុងចំណោមបេក្ខជនឈរឈ្មោះបោះឆ្នោត ១៤៨រូប និងមានស្ត្រីចំនួន ២១រូប។ រដ្ឋសភាបើកសម័យប្រជុំលើកទីមួយ ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ ដោយបានបោះឆ្នោតជ្រើសតាំង **សម្តេច ជា ស៊ីម** ជាប្រធានរដ្ឋសភា។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ រដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាចូលជាធរមាន។ រដ្ឋធម្មនុញ្ញនេះបានកំណត់ដែនដីរដ្ឋបាលនៅប្រទេសកម្ពុជាដូចជាៈ

- ដែនដីប្រទេសកម្ពុជាចែកជាខេត្ត និងក្រុង។
- ខេត្តចែកជាស្រុក។ ស្រុកចែកជាឃុំ។
- ក្រុងចែកជាសង្កាត់។

ក្រោយមកទៀតរដ្ឋធម្មនុញ្ញនេះបានប្តូរឈ្មោះប្រទេសពីសាធារណរដ្ឋប្រជាមានិតកម្ពុជា ទៅជា**រដ្ឋកម្ពុជា** វិញ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ ដោយបានធ្វើការកែប្រែបែងចែកទឹកដីប្រទេសកម្ពុជាដូចខាងក្រោមៈ

- ដែនដីប្រទេសកម្ពុជាចែកជាខេត្ត និងក្រុង។
- ខេត្តចែកជាទីរួមខេត្ត និងស្រុក។ ទីរួមខេត្តបែងចែកជាសង្កាត់។ ស្រុកចែកជាឃុំ។
- ក្រុងចែកជាខណ្ឌ និងស្រុកជាយក្រុង។ ខណ្ឌចែកជាសង្កាត់។ ស្រុកជាយក្រុងចែកជាឃុំដូចស្រុកចំណុះខេត្ត។

ក្រោយពីឆ្លងកាត់សង្គ្រាមដ៏រ៉ាំរ៉ៃ អស់រយៈពេលជាងបីទសវត្សរ៍រួចមកទីបំផុតប្រទេសកម្ពុជាបានទទួលនូវសុខសន្តិភាពឡើងវិញក្រោយពីការចរចា សម្របសម្រួលជាមួយគូរភាគីជម្លោះទាំង៤ភាគីរហូតបានសម្រេចលទ្ធផលក្នុង កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីដំណោះស្រាយបញ្ហានយោបាយនៅកម្ពុជា នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ដោយផ្អែកទៅលើកិច្ចព្រមព្រៀងនេះប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតនៅខែ ឧសភា ឆ្នាំ១៩៩៣ ព្រមទាំងបានតាក់តែងរដ្ឋធម្មនុញ្ញថ្មីផងដែរដែលបានប្រកាសដាក់ឲ្យប្រើប្រាស់នាថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលរដ្ឋធម្មនុញ្ញនេះបានកំណត់ថាកម្ពុជា ជាប្រទេសប្រកាន់យករបបគ្រប់គ្រងបែបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារសេរី ព្រមទាំងជារដ្ឋទោលមិនអាចបំបែកបាន(3)។

រដ្ឋធម្មនុញ្ញនេះក៏បានចែងអំពីការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលដូចជាៈ

- ដែនដីព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង។

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១ មាត្រា ៣ មាត្រា ៥១ថ្មី មាត្រា និងមាត្រា ៥៦។

- ខេត្តចែកជាស្រុក។ ស្រុកចែកជាឃុំ។
- ក្រុងចែកជាខណ្ឌ។ ខណ្ឌចែកជាសង្កាត់។

ក្រោយពីការរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ១៩៩៣ រួចមកប្រទេសកម្ពុជាបានជួបប្រទះនិងបញ្ហានយោបាយសង្គ្រាមផ្ទៃក្នុងជាបន្តទៀត ដោយមានបញ្ហាវិវាទគ្នារវាងគណបក្សនយោបាយធំៗចំនួនពីរ ស្តីអំពីលទ្ធផលនៃការបោះឆ្នោត ដែលនាំឲ្យមានបញ្ហាដល់ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ មានបញ្ហាដូចជាការផ្តល់សេវាដល់ប្រជាពលរដ្ឋមិនបានជិតដល់ រចនាសម្ព័ន្ធនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មិនច្បាស់លាស់ ក្នុងការបែងចែកអំណាចនោះឡើយ។ ដោយមើលឃើញនូវបរិបទបែបនេះហើយទើបប្រមុខរាជរដ្ឋាភិបាលបានសម្រេចជ្រើសយកប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិតាមបែប **"មជ្ឈការ"** វិញ។ ទោះជាយ៉ាងណាក៏ដោយ ក៏ស្ថានភាពនយោបាយនៅក្នុងការដឹកនាំមិនទាន់មានលក្ខណៈធូរស្រាលឡើយ ដោយគេមើលឃើញថាប្រទេសកម្ពុជាមិនទាន់មានរាជរដ្ឋាភិបាលឡើយ បញ្ហានយោបាយនៅតែជាកម្មវត្ថុមួយដ៏ចម្រូងចម្រាស់ក្តៅគគុកនៅក្នុងសង្គមកម្ពុជា។ ជាក់ស្តែងដើម្បីបញ្ចប់វិបត្តិនយោបាយទាំងព្រះបាទនរោត្តម សីហនុ បានសម្រេចបង្កើតការផ្សះផ្សារមួយដែលមាននាយករដ្ឋមន្ត្រីចំនួនពីរ ដែលនាយករដ្ឋមន្ត្រីទី១ គឺ **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** និងលោក **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីទី២ ប៉ុន្តែរាជរដ្ឋាភិបាលនេះមិនសូវចុះសម្រុងគ្នាដើម្បីដឹកនាំប្រទេសជាតិទេ។ លើសពីនេះទៅទៀតការបង្កើតនូវគោលនយោបាយ **ឈ្នះ ឈ្នះ** គឺជាគោលនយោបាយមួយបានសម្របសម្រួលឲ្យប្រជាជាតិខ្មែរទាំងមូលបានទទួលនូវពន្លឺសុខសន្តិភាពឡើងវិញ ដោយបានបង្កើតឡើងនូវស្ថាប័ន **គ.ជ.ប** មួយឡើងដើម្បីរៀបចំការបោះឆ្នោតសម្រាប់កម្ពុជានៅក្នុងឆ្នាំ១៩៩៨។

ការបោះឆ្នោតជាតិលើកទី២ បានប្រព្រឹត្តទៅតាមអាណត្តិដែលបានកំណត់ប្រកបដោយភាពជោគជ័យនាខែកក្កដា ឆ្នាំ១៩៩៨។ រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី២ នៃរដ្ឋសភាបានដាក់ចេញជាយុទ្ធសាស្ត្រត្រីកោណសម្រាប់រៀបវារៈកំណែទម្រង់នៃការគ្រប់គ្រងប្រទេសជាតិ ដែលកាលពីអាណត្តិទី១ ប្រទេសកម្ពុជាមានបញ្ហានយោបាយដោយមិនអាចបង្កើតជារាជរដ្ឋាភិបាលបានដែលនាំឲ្យប្រមុខដឹកនាំរាជរដ្ឋាភិបាលបានបង្កើតជា **"រដ្ឋបាលចាំផ្ទះ"** មួយឡើងសម្រាប់គ្រប់គ្រងរាជរដ្ឋាភិបាល និងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

ក្រោយមកទៀតបញ្ហាទាំងនេះត្រូវបានបញ្ចប់ ដោយសារមានការសម្របសម្រួលខាងនយោបាយ ដើម្បីរៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ការបោះឆ្នោតនៅតាមឃុំ សង្កាត់ និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងនៅឆ្នាំ១៩៩៩

និងឈានដល់ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានរដ្ឋសភាអនុម័ត នាខែមករា ឆ្នាំ២០០១។

នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស ចំនួន១.៦២១ ឃុំ សង្កាត់[4] ដែលបានរៀបចំឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ចាប់តាំងពីពេលនោះមកគេចាប់ផ្តើមធ្វើកំណែទម្រង់តាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ និងបានជោគជ័យជាបណ្តើរៗដែលជាកត្តាមួយជួយជំរុញទឹកចិត្តរាជរដ្ឋាភិបាលឲ្យមានការខិតខំប្រឹងប្រែងពង្រីកដំណើរការអនុវត្តកំណែទម្រង់នេះ ដល់គ្រប់រដ្ឋបាលនៅថ្នាក់ក្រោមជាតិដោយមានការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅឆ្នាំ២០០៥ និងជាចក្ខុវិស័យមួយក្នុងការតាក់តែងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដោយការបោះឆ្នោតនេះបានប្រព្រឹត្តទៅនៅឆ្នាំ២០០៩។

ផ្អែកតាមតម្រូវការនៃកំណែទម្រង់នេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីរៀបចំឡើងវិញនូវការគ្រប់គ្រងដែនដីរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជារាជធានីភ្នំពេញ និងខេត្ត។
- រាជធានីភ្នំពេញចែកជាខណ្ឌ។ ខណ្ឌចែកជាសង្កាត់។
- ខេត្តចែកជាក្រុង និងស្រុក។ ក្រុងចែកជាសង្កាត់។ ស្រុកចែកជាឃុំ និងជាសង្កាត់។

ការរៀបចំដែនដីតាមការបែងចែកនេះក្នុងគោលបំណងគ្រប់គ្រង និងរៀបចំនូវរចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យបានច្បាស់លាស់ ដែលស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមគ្នានេះដែរជាយន្តការក្នុងការអនុវត្តគោលនយោបាយគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ដោយមានរាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់ក្នុងការអនុវត្ត ដោយបានធ្វើគោលនយោបាយគាំទ្រដល់ឃុំ សង្កាត់ ព្រមទាំងជួយជំរុញបន្តនូវការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅមុខងារណាដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពអាចធ្វើបានគឺថ្នាក់ជាតិត្រូវផ្តល់សិទ្ធិ និងអំណាចជូនថ្នាក់ក្រោមជាតិដើម្បីមាន**ស្វ័យភាព ម្ចាស់ការ** និងមានលទ្ធភាពអាច**សម្រុះសម្រួល**ដោះស្រាយជាមួយតម្រូវការប្រជាពលរដ្ឋរបស់ខ្លួនឯងបាន។ ពោលគឺ ប្រមុខរាជរដ្ឋាភិបាលមានទស្សនៈវិស័យរៀបចំប្រព័ន្ធរដ្ឋបាលដែនដី ការផ្ទេរមុខងារ និងធនធាន តាមគោលការណ៍ **សាប់ស៊ីឌីយ៉ារិធី**

[4] បាឋកថា ស្តីពីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បោះពុម្ពផ្សាយ ខែវិច្ឆិកា ឆ្នាំ២០១៥ ទំព័រ ១៩។

(Subsidiarity) និងមានចក្ខុវិស័យឆ្ពោះទៅមុខជាបន្តបន្ទាប់ចាប់ពីការគ្រប់គ្រងតាមបែប **"មជ្ឈការ"** ទៅដល់ **"រដ្ឋបាលឯកភាព"** និងបន្តទៅដល់ **"វិមជ្ឈការ"** រហូតឈានដល់ការគ្រប់គ្រងរដ្ឋបាលតាមបែបប្រព័ន្ធ **"រដ្ឋបាលមូលដ្ឋាន"** នាថ្ងៃអនាគត។

## ២.អ្វីជាមុខងារ និងធនធាន?

**មុខងារ** សំដៅដល់អំពើ ឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។

**ធនធាន** សំដៅដល់ទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ ចំណូល បុគ្គលិក និងសមត្ថភាព។[5]

ចំពោះមុខងារ និងធនធានគឺជាកិច្ចការដ៏មានអាទិភាពមួយក្នុងការធ្វើកំណែទម្រង់តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។ ជាក់ស្តែងយើងបានដឹងហើយថា **វិមជ្ឈការ** គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមាន**គណនេយ្យភាព**ចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហានេះ។[6] ក្នុងន័យនេះរាល់កិច្ចការនានាដែលបានធ្វើវិមជ្ឈការទៅក្រុមប្រឹក្សា ក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញ ក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការរបស់ខ្លួននៅក្នុងមូលដ្ឋានផងដែរ ព្រមទាំងការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ទន្ទឹមគ្នានេះផងដែរក្រុមប្រឹក្សាក៏ត្រូវទទួលខុសត្រូវចំពោះកិច្ចការដែលខ្លួនបានធ្វើ និងត្រូវទទួលខុសត្រូវចំពោះស្ថាប័នផ្ទាល់ខ្លួនទៀតផង។ ចំណែកឯពាក្យថា **វិសហមជ្ឈការ** គឺជាការដែលរាជរដ្ឋាភិបាលឬក្រសួងស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅឲ្យអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តន៍ក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន។[7] អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នស្របទៅតាមតម្រូវការដែលបានធ្វើប្រតិភូកម្មនោះ។ ករណីនេះក្រុមប្រឹក្សាគឺអនុវត្តតាមការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នរបស់ខ្លួន ហើយចំពោះការទទួលខុសត្រូវចុងក្រោយគឺរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នសាមីផ្ទាល់ជាអ្នកទទួលខុសត្រូវគ្រប់ទង្វើទាំងអស់ ដែលក្រុមប្រឹក្សាបានអនុវត្តការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នសាមីនោះ។ ជាក់ស្តែងសព្វថ្ងៃនេះរាជរដ្ឋាភិបាល ឬក្រសួងកំពុងតែបានធ្វើនីតិវិធីនៃការប្រគល់នូវមុខងារ និងធនធានទៅឲ្យអង្គភាពនៅក្រោមបង្គាប់ដើម្បីឲ្យអង្គភាព

---

[5] អនុក្រឹត្យលេខ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១២ ស្តីពី ដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

[6] បាឋកថា ស្តីពីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បោះពុម្ពផ្សាយ ខែវិច្ឆិកា ឆ្នាំ២០១៥ ទំព័រ ១៧។

[7] សូមមើលចំណុចទី6

នៅក្រោមបង្គាប់នីមួយៗ អនុវត្តន៍តាមគោលការណ៍ដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ននោះបាន ដាក់ចេញ[8]។

កត្តាទាំងនេះអាចធ្វើទៅបានអាស្រ័យ ដោយនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាព សមត្ថភាព និងធនធានផ្ទាល់ខ្លួនទើបអាចសម្រេចបាន។ ពោលគឺជាជំហានដំបូងរដ្ឋបាលនៅថ្នាក់ក្រោមជាតិត្រូវតែមានលទ្ធភាពក្នុងការសម្រេច អនុវត្តនូវមុខងាររបស់ខ្លួនដែលទទួលបានឲ្យស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលចូលជាធរមាន ព្រមទាំងមានគណនេយ្យភាពបន្ថែមទៀតផង។

## ៣.មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ជាគោលការណ៍ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺសំដៅដល់ដំណើរការផ្ទេរមុខងារ និងសិទ្ធិអំណាច និងធនធានសមស្របទៅឲ្យស្ថាប័ន ឬអង្គភាព ដែលត្រូវបានធ្វើវិមជ្ឈការនោះ។ ក្នុងន័យនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានកំណត់អំពីគោលការណ៍ និងដំណើរការ នៃការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មានលទ្ធភាពសមស្របក្នុងការបង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យមូលដ្ឋាន។

### ក.ប្រភេទនៃមុខងារ

មុខងារដែលត្រូវបានផ្ទេរដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលបានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិមានមុខងារពីរប្រភេទ ដែលមុខងារទាំងពីរនេះគឺធ្វើឡើងដោយការប្រគល់ ឬដោយការធ្វើប្រតិភូកម្ម។

### ១.មុខងារជាកាតព្វកិច្ច

មុខងារជាកាតព្វកិច្ច គឺជាមុខងារដែលបានកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬដោយអនុក្រឹត្យ ឬដោយប្រកាសតាមសំណើ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសខាងលើនេះ ត្រូវចែងជាតម្រូវការច្បាស់លាស់ និងជាក់លាក់សម្រាប់ការគ្រប់គ្រង និងអនុវត្តមុខងារដោយបញ្ជាក់ច្បាស់អំពីក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តបទដ្ឋាន និងនីតិវិធី។ ពោលគឺមុខងារជាកាតព្វកិច្ចគឺជាមុខងារដែលរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានាបានចេញជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬលិខិតបទដ្ឋានគតិយុត្តនានាដែលបានចូលជាធរមាន ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តតាម ដោយមានក្រុមប្រឹក្សាជាអ្នកគ្រប់គ្រង

[8] សូមមើលឧបសម្ព័ន្ធទី០៧

ចាត់ចែង និងអនុវត្តនូវមុខងារដែលទទួលបានពីច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬលិខិតបទដ្ឋានគតិយុត្តនានា ដែលបានចូលជាធរមាននោះតាមរយៈការធ្វើប្រតិភូកម្ម ព្រមទាំងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងត្រូវមានគណនេយ្យភាពផ្ទៃក្នុងផងដែរ[9]។ មុខងារជាកាតព្វកិច្ច គឺជាមុខងារ ដែលមានលក្ខណៈជាតម្រូវការចាំបាច់ ហើយដែលត្រូវបានកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាដែលចូលជាធរមាន ដែលក្រសួង ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តនូវមុខងារទាំងនោះ។ ការអនុវត្តក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវជួយសម្រួលដល់ដំណើរការផ្ទេរ នៃមុខងារនេះតាមរយៈការផ្តល់ជាកញ្ចប់ថវិកា ធនធានមនុស្ស សម្ភារបច្ចេកទេស និងសមត្ថភាពសមស្របទៅដល់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដើម្បីឲ្យការអនុវត្តតួនាទី ភារកិច្ច របស់ស្ថាប័នផ្ទាល់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ដែលស្របទៅតាមផែនការជាយុទ្ធសាស្ត្រ នៃការធ្វើកំណែទម្រង់នៃប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ របស់រាជរដ្ឋាភិបាលកម្ពុជា។ មុខងារជាកាតព្វកិច្ច គឺជាមុខងារ ដែលមានលក្ខណៈជាតម្រូវការចាំបាច់ ហើយដែលត្រូវបានកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសជាសមត្ថភាពរបស់អង្គភាព ឬស្ថាប័នជាក់លាក់ណាមួយ។ មុខងារជាកាតព្វកិច្ចត្រូវបានប្រគល់ទៅឲ្យក្រុមប្រឹក្សាតាមរយៈការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័នដែលពាក់ព័ន្ធដើម្បីឲ្យក្រុមប្រឹក្សាអាចអនុវត្តគោលនយោបាយដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នរបស់ខ្លួនទទួលបានលទ្ធផលវិជ្ជមាន បន្ថែមដោយការយកចិត្តទុកដាក់ក្នុងការចូលរួមពីបណ្តាអភិបាល នៃគណៈអភិបាល នាយករដ្ឋបាល និងគ្រប់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សានៅពេលដែលអនុវត្តកិច្ចការណាមួយ ដែលក្រុមប្រឹក្សាបានអនុម័តរួច។

## ៣.មុខងារជាជម្រើស

មុខងារជាជម្រើស គឺជាមុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច ដែលត្រូវបានកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាដែលចូលជាធរមាន។ ការផ្ទេរមុខងារជាជម្រើសដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលទៅឲ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្រប ដែលត្រូវធ្វើឡើងដោយការប្រគល់[10]។ មានន័យថារាជរដ្ឋាភិបាល ក្រសួង ស្ថាប័នមើលតាមលទ្ធភាព សមត្ថភាព និងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ក្នុងការផ្តល់មុខងារដល់ទៅឲ្យអនុវត្ត ដោយក្រុមប្រឹក្សាអាចជ្រើសរើសនូវមុខងារណាដែលខ្លួនគិតថាអាចធ្វើបាន ឬមួយអាចធ្វើ

[9] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ មាត្រា២២២ដល់២២៦

[10] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ មាត្រា២២៧ និង២២៨

បានបន្តិចបន្តួចដោយអាចស្នើសុំមកថ្នាក់ជាតិ ក្នុងការគាំទ្រកិច្ចដំណើរការរបស់ខ្លួនដោយសុំផ្តល់ជាថវិកា ធនធានមនុស្ស ទៅតាមលទ្ធភាពរបស់ក្រសួង ស្ថាប័នសាមីនោះ។ ក្នុងការអនុវត្តមុខងាជាជម្រើស ក្រុមប្រឹក្សាត្រូវធ្វើការសម្រេចអំពីការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដែលទទួលបាន ក្នុងកម្រិតអតិបរមានៃលទ្ធភាព និងធនធានដែលក្រុមប្រឹក្សាមាន។

**៤.គោលការណ៍នៃការផ្ទេរមុខងារ**

ជាគោលការណ៍ ការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឡើងដោយផ្សារភ្ជាប់ជាមួយនឹងធនធានចាំបាច់ដោយមានការគ្រោងទុក មានសនិទានភាព មានការសម្របសម្រួល ការពិគ្រោះយោបល់ មានតម្លាភាព និងសំដៅដល់សេដ្ឋកិច្ចវិមាត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិមកដល់ស្ថាប័នថ្នាក់ជាតិ ក្រសួង និងរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងកិច្ចការងារអនុវត្តនូវមុខងារទាំងនោះឲ្យទទួលបានចេញជាលទ្ធផលផ្លែផ្កា។

បច្ចុប្បន្នមុខងារមួយចំនួននៃក្រសួងស្ថាប័ននីមួយៗ ដែលត្រូវបានកំណត់ជាវិស័យអាទិភាពត្រូវបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងារណាដែលចាំបាច់ និងមុខងារណាដែលត្រូវបានរក្សាទុកនៅជាការទទួលខុសត្រូវរបស់ថ្នាក់ជាតិ។ វិស័យអាទិភាពទាំងនោះរួមមាន៖

- កសិកម្ម
- អប់រំ
- ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន
- សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច
- ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច
- ការប្រើប្រាស់ដីធ្លី
- ការផលិត និងការចែកចាយអគ្គិសនី
- ការគ្រប់គ្រងទឹក
- ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយ សម្ភារចាំបាច់ ដើម្បីគាំទ្រ និងការទទួលខុសត្រូវទាំងនេះ
- និង តម្រូវការពិសេស ឬតម្រូវការដែលបានកំណត់ជាក់លាក់ សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរ្តិ៍ដំណែលវប្បធម៌ផងដែរ[11]។

[11] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ មាត្រា២១៥

ទន្ទឹមនេះ ក្នុងការពិនិត្យមើលមុខងារដើម្បីផ្ទេរទៅឲ្យរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន ត្រូវផ្តល់អាទិភាពទៅលើមុខងារជាមូលដ្ឋាន ដែលជួយគាំទ្រ ដល់ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយត្រូវផ្អែកលើគោលការណ៍ ដូចខាងក្រោម៖

**ទីមួយ៖** ការផ្ទេរមុខងារត្រូវផ្អែកទៅលើគោលការណ៍នៃ Subsidiarity ។ គឺមុខងារណាដែលពិនិត្យឃើញថា មានលក្ខណៈនៅកៀកប្រជាពលរដ្ឋ ហើយរដ្ឋបាលនៅថ្នាក់ក្រោមជាតិអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព ក្រសួង ស្ថាប័នថ្នាក់ជាតិត្រូវពិនិត្យទៅលើមុខងារណាដែលអាចផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិបាន។ មានន័យថាគោលការណ៍ Subsidiarity គឺជាគោលការណ៍មួយប្រភេទស្រដៀងនិងប្រព័ន្ធវិសហមជ្ឈការដែលរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នបានធ្វើប្រតិភូកម្មមុខងារ សិទ្ធិ អំណាច និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនាមជាក្រសួង ស្ថាប័ននោះព្រមទាំងមានគណនេយ្យភាពតាមលំដាប់ថ្នាក់ ក៏ដូចជាគោលការណ៍ Subsidiarity ដែលគេប្រៀបបានដូចជាការដឹកនាំការងារ ការប្រគល់នូវ មុខងារ និងធនធាន ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងារណាដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពអាចធ្វើបាន ហើយវាក៏ដូចជាការរែងគ្រួសនៅក្នុងកញ្ច្រែងដែលគេនឹងតម្រូវឲ្យគ្រាប់គ្រួសណាដែលគួរធ្លាក់ចុះត្រូវតែធ្លាក់ចុះ ហើយគ្រាប់ណាដែលធំមិនអាចធ្លាក់គេទុកវាសិន វាប្រៀបដូចជារាជរដ្ឋាភិបាលដែលបានផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងារមួយចំនួន ដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលយកបាន ព្រមទាំងអាចអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់សមស្របទៅតាមចក្ខុវិស័យនៃគោលការណ៍កំណែទម្រង់ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។

**ទីពីរ៖** ការផ្ទេរមុខងារឲ្យបានសមស្របរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននីមួយៗគួរតែពិនិត្យទៅលើលទ្ធភាពនៃប្រភេទក្រុមប្រឹក្សានីមួយៗ រួចហើយវិនិច្ឆ័យទៅតាមលក្ខណៈនៃមុខងារណាដែលប្រភេទក្រុមប្រឹក្សានោះអាចទទួលយកទៅអនុវត្តបានជោគជ័យ ដើម្បីសម្រេចថា មុខងារណាមួយដែលសមស្របក្នុងការប្រគល់ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ លក្ខណៈក្នុងការវិនិច្ឆ័យក្នុងការពិចារណាសម្រាប់ការផ្ទេរមុខងាររួមមាន៖

- ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
- អាចគ្រប់គ្រង និងអនុវត្តបានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
- បម្រើ ឬផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ

❖ មានផលប៉ះពាល់ជាចម្បងក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ[12]។

**ទីបី៖** ក្នុងការផ្ទេរមុខងារ ក្រសួង ស្ថាប័នថ្នាក់ជាតិដែលផ្ទេរមុខងារនោះត្រូវកំណត់ថា មុខងារនោះជាមុខងារកាតព្វកិច្ច ឬជាមុខងារជាជម្រើស ដើម្បីឲ្យរដ្ឋបាលនៅថ្នាក់ក្រោមជាតិអាចបំពេញនូវតួនាទី ភារកិច្ចរបស់ខ្លួនជាមួយនិងក្រុមប្រឹក្សារបស់ខ្លួនប្រកបដោយឆន្ទៈខ្ពស់ដើម្បីធានាដល់ការបម្រើសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ និងមានលក្ខណៈជិតស្និទ្ធ ជំនឿចិត្ត នឹងការឈានទៅរកការអភិវឌ្ឍសេដ្ឋកិច្ចជាតិ សំដៅដល់ការកម្ពស់នូវជីវភាពនៅថ្នាក់មូលដ្ឋានដែលជាយន្តការមួយនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន។

**ទីបួន៖** ការផ្ទេរមុខងារ និងធនធាន ឲ្យទៅប្រភេទក្រុមប្រឹក្សាណាមួយ ដែលសមស្របតាមរយៈការប្រគល់ ឬជាការធ្វើប្រតិភូកម្មនៃមុខងារ ដែលត្រូវធ្វើឡើងតាមគោលការណ៍នៃការប្រគល់ ឬជាការធ្វើប្រតិភូកម្មជាលក្ខណៈអចិន្ត្រៃយ៍ ដោយមិនត្រូវធ្វើការប្រគល់ ឬការធ្វើប្រតិភូកម្មដោយមានលក្ខណៈជាបណ្តោះអាសន្ននោះឡើយ។ ក្នុងកិច្ចនៃដំណើរការនៃការផ្ទេរមុខងារ និងធនធាន ក្រសួង ស្ថាប័នត្រូវយកចិត្តទុកដាក់ចំពោះការកំណត់នូវប្រភេទនៃមុខងារឲ្យបានច្បាស់លាស់ដោយយោងទៅតាមប្រភេទនៃក្រុមប្រឹក្សានីមួយៗបើប្រគល់នូវមុខងារជាកាតព្វកិច្ច ក្រសួង ស្ថាប័នគួរចេញជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬលិខិតបទដ្ឋានគតិយុត្តនានា ដែលសមស្របអាចឲ្យក្រុមប្រឹក្សាមានលទ្ធភាពអាចអនុវត្តទៅបាន បន្ថែមដោយមានការគាំទ្រពីសំណាក់ រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នក្នុងដំណើរការងារនានាដែលពាក់ព័ន្ធដល់មុខងារជាកាតព្វកិច្ចដែលស្ថាប័នថ្នាក់ជាតិបានប្រគល់ឲ្យ ឬប្រសិនបើរាជរដ្ឋាភិបាលបានប្រគល់នូវមុខងារជាជម្រើសទៅដល់ប្រភេទក្រុមប្រឹក្សាណាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានាគួរសិក្សាវិនិច្ឆ័យឲ្យបានច្បាស់អំពីសមត្ថភាពលទ្ធភាពរបស់ក្រុមប្រឹក្សាដែលមានទាំងធនធាន ហិរញ្ញវត្ថុ និងធនធានមនុស្ស។ ពោលគឺដំណើរការគាំទ្រនៃការផ្ទេរមុខងារជាជម្រើសត្រូវតែដើរទន្ទឹមគ្នាជាមួយនឹងថវិកា និងធនធានមនុស្ស ប្រសិនបើនៅរដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគាំទ្រនៃមុខងារនេះបានទេ រាជរដ្ឋាភិបាលក្រសួង ស្ថាប័នត្រូវគាំទ្រដំណើរការនេះដោយត្រូវផ្តល់ជាកញ្ចប់ថវិកា និងជួយបញ្ជូនអ្នកបច្ចេកទេសសម្រាប់ការបណ្តុះបណ្តាលដល់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទីប្រាំ៖** ការប្រគល់មុខងារ ឬការធ្វើប្រតិភូកម្មមុខងារត្រូវធ្វើជាលក្ខណៈស្របច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាដែលបានចូលជាធរមាន។ ក្រសួង ស្ថាប័ន ត្រូវ

[12] អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១២ ស្តីពី ដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ មាត្រា៧

គោរពដល់គោលការណ៍ខាងលើនេះដើម្បីគាំទ្រ ដល់ដំណើរការការងារលើកិច្ចការត្រួតពិនិត្យលើមុខងារដើម្បីផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៥.ដំណើរការផ្ទេរមុខងារ**

ដើម្បីគាំទ្រទៅដល់ស្ថាប័នថ្នាក់ក្រោមជាតិ ក៏ដូចជាការជួយសម្រួលនូវកិច្ចការសម្រាប់ដំណើរការផ្ទេរមុខងារពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណង ណែនាំកិច្ចការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់ការណែនាំទូទៅដល់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អំពីដំណើរការផ្ទេរមុខងារ និងធនធាន។ ផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ ក្រសួង ស្ថាប័នដែលស្ថិតក្នុងវិស័យអាទិភាពត្រូវរៀបចំបញ្ជីវិភាគមុខងារនៅក្នុងក្រសួង ស្ថាប័នរបស់ខ្លួន ហើយបន្ទាប់មកទៀតត្រូវពិនិត្យមើលមុខងារឡើងវិញ និងធ្វើបញ្ជីវិភាគមុខងារ ដើម្បីកំណត់អំពីមុខងារ និងធនធានដែលត្រូវផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយមានស្ថាប័ន គ.ជ.អ.ប ជាអ្នកសម្របសម្រួលក្នុងកិច្ចដំណើរការនេះ។

បច្ចុប្បន្ននេះ មានក្រសួងចំនួន០៦ បានបញ្ជីវិភាគមុខងាររួចហើយ ក្នុងនោះរួមមាន៖

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសុខាភិបាល
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអប់រំ យុវជន និងកីឡា និង
- ក្រសួងបរិស្ថាន។

ជាក់ស្តែងយោងតាមបញ្ជីវិភាគមុខងារ នៅឆ្នាំក្នុង២០១៧នេះ យ៉ាងហោចណាស់ មានក្រសួងចំនួន០៦ បាន និងកំពុងពិចារណាកំណត់អំពីការផ្ទេរមុខងារឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះរួមមាន៖

| ក្រសួង | មុខងារដែលគ្រោងនឹងផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | |
|---|---|---|
| | **ចំនួនមុខងារ** | **ចំនួនមុខងារដែលស្នើផ្ទេរ** |
| **ក្រសួងអប់រំ យុវជន និងកីឡា** | - មុខងារ៖១១<br>- មុខងាររង៖៨០<br>- អនុមុខងាររង/សកម្មភាព | - ការអប់រំកុមារតូច(ស្នើផ្ទេរមុខងាររងចំនួន០៦/៣៨)<br>- ការអប់រំក្រៅប្រព័ន្ធ(ស្នើផ្ទេរ |

| | | |
|---|---|---|
| | ៖៥៧៣ | មុខងាររងចំនួន១/៤២) |
| **ក្រសួងសុខាភិបាល** | - មុខងារ៖០៥<br>- មុខងាររង៖៣១<br>- អនុមុខងាររង/សកម្មភាព ៖៨០ | - ការគ្រប់គ្រងមន្ទីរពេទ្យបង្អែក ស្រុក<br>- ការគ្រប់គ្រងមណ្ឌលសុខភាព |
| **ក្រសួងអភិវឌ្ឍន៍ ជនបទ** | - មុខងារ៖០៩<br>- មុខងាររង៖៣៨ | - ការលើកកម្ពស់សន្តិសុខស្បៀង<br>- អនាម័យជនបទ<br>- ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត<br>- ដាក់ស្លាកសញ្ញាចរាចរណ៍លើផ្លូវ ជនបទ<br>- ជួសជុលផ្លូវជនបទមានលក្ខណៈ ជាប្រចាំ |
| **ក្រសួងបរិស្ថាន** | - មុខងារ៖០៨<br>- មុខងាររង៖៤០ | - ពង្រឹងការគ្រប់គ្រងសំណល់រឹង រាវតាមទីប្រជុំជន និងនៅតាមទី សាធារណៈ<br>- ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថាន នៃ គម្រោងវិនិយោគ<br>- ការគ្រប់គ្រងសហគមន៍តំបន់ ការពារធម្មជាតិ<br>- ការបញ្ជ្រាបភាពធន់ នឹងការ ប្រែប្រួលអាកាសធាតុ<br>- ការពង្រឹងការងារអប់រំបរិស្ថាន (ក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ) |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា** | - មុខងារ៖០៨<br>- មុខងាររង៖៣៧<br>- អនុមុខងាររង/សកម្មភាព ៖១៩២ | - ផ្តល់សេវាថែទាំកុមារកំព្រា និង ក្រុមកុមារងាយរងគ្រោះ នៅក្នុង មណ្ឌល<br>- ផ្តល់សេវាថែទាំកុមារកំព្រា និង |

| | | |
|---|---|---|
| | | ក្រុមកុមារងាយរងគ្រោះ នៅក្នុងគ្រួសារ និងសហគមន៍<br>- ផ្តល់នូវជំនួយ សង្គ្រោះបន្ទាន់សម្រាប់ជនរងគ្រោះ និងជនងាយរងគ្រោះ<br>- ស្រង់ទិន្នន័យជនរងគ្រោះ និងជនងាយរងគ្រោះ |

តារាងទី១៖ អំពីបញ្ជីវិភាគមុខងាររបស់ក្រសួងផ្សេងៗ។

ដែលក្នុងនោះក្រសួងអប់រំ យុវជន និងកីឡា បានចេញជាអនុក្រឹត្យលេខ១៩១ អនក្រ.បក ស្តីពី ការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឲ្យទៅដល់រដ្ឋបាល ក្រុង ស្រុក ហើយរដ្ឋបាលក្រុង ស្រុក ដែលបានប្រគល់មុខងារគឺរដ្ឋបាល ក្រុង ស្រុក នៃខេត្តបាត់ដំបង ព្រមទាំងអនុវត្តនូវការប្រគល់មុខងារនេះទៅដល់រដ្ឋបាលក្រុង ស្រុក នៃខេត្តនានាជាបន្តទៀត ដែលបច្ចុប្បន្ននេះ បាននឹងកំពុងរៀបចំប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុង ស្រុក ទាំងអស់ក្នុងខេត្តបាត់ដំបង។ ទន្ទឹមគ្នានេះផងដែរក្រសួងបានចុះសិក្សាប្រមូលទិន្នន័យដើម ក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រសួងបរិស្ថានបានចេញអនុក្រឹត្យមួយ ស្តីពី មុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនដោយបានប្រគល់ និងការធ្វើប្រតិភូកម្មទៅឲ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ដែលដំណើរការត្រូវបានគាំទ្រដោយសេចក្តីណែនាំអន្តរក្រសួងលេខ១៩១១ សជណ.ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងមានការឯកភាពគ្នាពីក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន លើសេចក្តីព្រាងប្រកាស ស្តីពីការប្រើប្រាស់ និងការចាត់ចែងចំណូលបានពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសកំណត់ក្នុងអនុក្រឹត្យលេខ១១៣ ប៉ុន្តែមិនទាន់មានការឯកភាពពីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុនៅឡើយ។ ជាមួយគ្នានេះផងដែរមុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិដែលបានធ្វើប្រតិភូកម្មដោយប្រកាសលេខ០៣៦ប្រក.បស្ក ទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅដែលបច្ចុប្បន្ននេះក្រសួងកំពុងពិនិត្យលើប្រកាសស្តីពី ការប្រើប្រាស់កញ្ចប់ថវិកាឧបត្ថម្ភធនធានរបស់ក្រសួងបរិស្ថាន សម្រាប់អនុវត្តសាកល្បងមុខងារដែលបានធ្វើប្រតិភូកម្មជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានមុខងារមួយចំនួនទៀតដូចជាមុខងារគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដែលចេញដោយប្រកាសលេខ ០៣៧ ប្រ.ក.ប.ស្ក មុខងារបញ្រ្ជាបភាពធន់នឹងអាកាសធាតុ ដោយ

ប្រកាសលេខ ០៣៨ប្រ.ក.ប.ស្ក ដោយការធ្វើប្រតិភូកម្មទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ។ លើសពីនេះទៅទៀតក្រសួងបានចេញប្រកាសលេខ ០៣៩ប្រ.ក.ប.ស្ក ស្តីពីមុខងារពង្រឹងការងារអប់រំបរិស្ថាន ទៅដល់រដ្ឋបាលរាជធានីខេត្ត និងមានមុខងារពីរបន្ថែមទៀតដែលនឹងកំពុងរៀបចំដោយក្រសួងដើម្បីជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក គោលដៅទទួលបាននូវមុខងារនេះដែលមានដូចជាមុខងារការគ្រប់គ្រងថង់ប្លាស្ទិក និងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ដែលក្រសួងកំពុងនឹងរៀបចំ ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យសម្រាប់នីតិវិធីក្នុងការអនុវត្តនូវមុខងារទាំងនោះទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបាននឹងកំពុងអនុវត្តនូវមុខងារសាកល្បងមួយចំនួនទៅដល់រដ្ឋបាលក្រុង ស្រុក និងខេត្តគោលដៅមួយចំនួនដូចជា មុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ដោយប្រកាសលេខ ០៤៣/១៥ ក.អ.ជ.ប្រក ដោយបានធ្វើប្រតិភូកម្មដោយអនុវត្តសាកល្បងពី ថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ទៅដល់រដ្ឋបាលគោលដៅក្នុងខេត្តកំពត និងខេត្តត្បូងឃ្មុំ ដែលបច្ចុប្បន្ននេះមុខងារទាំងនេះកំពុងបានអនុវត្ត។ មុខងារផ្តល់សេវាអនាម័យជនបទ ត្រូវបានអនុវត្តដោយប្រកាសលេខ១៥៣/១៥ ក.អ.ជ.ប្រក ដោយបានធ្វើប្រតិភូកម្មអនុវត្តន៍សាកល្បងពី ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០១៦ ទៅដល់រដ្ឋបាលស្រុកគោលដៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ ដែលមុខងារនេះត្រូវបានកំពុងនឹងអនុវត្តនាពេលបច្ចុប្បន្ន។

ក្រសួងសុខាភិបាល បានបញ្ចប់នូវការអនុវត្តនូវមុខងារសាកល្បងរួចរាល់ហើយដែលមុខងារនោះគឺជាមុខងារមួយចំនួននៃមណ្ឌលសុខភាព ដោយមានប្រកាសលេខ៩៥៤ ស.ន.ប ដោយបានធ្វើប្រតិភូកម្ម អនុវត្តសាកល្បង១៦ខែ គឺពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ទៅដល់រដ្ឋបាលគោលដៅក្នុងខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ប្រកបដោយភាពជោគជ័យ។ នាពេលបច្ចុប្បន្ននេះមុខងារមួយទៀត ដែលត្រូវបានក្រសួងសុខាភិបាលកំពុងរៀបចំអនុវត្តជូនទៅដល់រដ្ឋបាលក្រុង ស្រុក ខេត្តគោលដៅបន្ត គឺមុខងារគ្រប់គ្រងសេវាសំណុំសកម្មភាពអប្បបរមា ដែលមានសេចក្តីសម្រេចលេខ ៩៥០ ស.សនក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារអន្តរក្រសួងសម្រាប់ការរៀបចំ និងសម្រួលការងារផ្ទេរមុខងារ និងធនធាន។ ក្រសួងក៏បានជួបប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួងលើកដំបូង និងកំពុងពិនិត្យពិភាក្សាលើការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសេវាសំណុំសកម្មភាពអប្បបរមា។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយក្រសួងបានចេញជាអនុក្រឹត្យលេខ៣៤ អនក្រ.បក ដើម្បីប្រគល់នូវមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររដ្ឋជូនរដ្ឋបាលរាជធានី

ខេត្ត មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ជូនទៅរដ្ឋបាលរាជធានី ក្រុង ស្រុក និងមុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនៅក្នុងសហគមន៍ ជូនទៅរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ ដោយមុខងារទាំងនេះបានត្រូវអនុម័តផែនការសកម្មភាពរបស់ក្រុម ការងារអន្តរក្រសួង និងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យ សម្រាប់ផ្ទេរមុខងារនានាបន្ថែមទៀត សម្រាប់ឆ្នាំ២០១៧។

ក្រសួងទេសចរណ៍ បានធ្វើប្រតិភូកម្មទៅដល់រដ្ឋបាលរាជធានី ខេត្ត ដោយប្រកាសលេខ ០៦៩ ប្រ.ក ស្តីពីមុខងារនៃការគ្រប់គ្រងមណ្ឌលទេសចរណ៍មនុស្សពេញវ័យ ដោយក្រសួងមហាផ្ទៃ បានដាក់ចេញសេចក្តីសម្រេចលេខ៣៧៦៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង ការ ចាត់ចែង និងការអនុវត្តមុខងារការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យនៅរាជធានី ខេត្តក្រសួងទេសចរណ៍បានដាក់ចេញសេចក្តីណែនាំលេខ០២០ សណន ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការអនុវត្តប្រកាសលេខ០៦៩ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួង ទេសចរណ៍ ស្តីពីការធ្វើប្រតិភូកម្មមុខងារ "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេចរណ៍មនុស្សពេញវ័យ"។

ជារួមមកមុខងារដែលត្រូវបានផ្ទេរ ប្រគល់ និងការធ្វើប្រតិភូកម្មនានាពីរដ្ឋបាលថ្នាក់ជាតិទៅ ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តនូវមុខងារមកដល់ពេលនេះមានចំនួនសរុប១៨ មុខងារ ដោយមាន ០៦ក្រសួងស្ថាប័នខាងលើជាអ្នកអនុវត្ត។ ក្នុងដំណើរការប្រគល់មុខងារនេះរាជរដ្ឋាភិបាល កំពុងនឹងរៀបចំ ត្រួតពិនិត្យ និងពិភាក្សាបន្ថែមទៀតក្នុងការប្រគល់មុខងារណាដែលអាចឲ្យរដ្ឋបាល ថ្នាក់ក្រោមជាតិអាចមានសមត្ថភាពអាចអនុវត្តបានទៅមុនជាបណ្តើរៗទៅតាមនីតិវិធី។

សូមមើលឧបសម្ពន្ធ័ទី០៧

# ជំពូកទី២
# តួអង្គសំខាន់ៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ១.ទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានគេបែងចែកជារដ្ឋបាលថ្នាក់ជាតិដែលសំដៅទៅលើក្រសួងស្ថាប័នថ្នាក់ជាតិ រាជរដ្ឋាភិបាល ដែលជាក្បាលម៉ាស៊ីនក្នុងការដឹកនាំប្រទេសជាតិ ដោយមាននាយករដ្ឋមន្ត្រីជាតួអង្គនៃនីតិប្រតិបត្តិ ដែលអនុវត្តរាល់កិច្ចការនានា ដោយមានគណនេយ្យភាពចំពោះស្ថាប័ននីតិបញ្ញត្តិដែលមានព្រឹទ្ធសភា និងរដ្ឋសភាជាតួអង្គតាមដានត្រួតពិនិត្យរាល់សកម្មភាពអនុវត្តការងាររបស់រាជរដ្ឋាភិបាល ហើយរាជរដ្ឋាភិបាលនឹងត្រូវទទួលខុសត្រូវចំពោះមុខសភានៅពេលដែលខ្លួនបានប្រព្រឹត្តខុស។

ដោយឡែក តួអង្គនៅរដ្ឋបាលថ្នាក់ក្រោមជាតិវិញត្រូវបានគេរាប់បញ្ចូលចាប់ពីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំនិងសង្កាត់។ ដែលតួអង្គទាំងនោះមានដូចជាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ដែលមានតួនាទីជានីតិបុគ្គលដែលមានសិទ្ធិអនុម័តរាល់កិច្ចការនានាដាក់ឲ្យ អភិបាល នៃគណៈអភិបាលអនុវត្ត។ អភិបាល នៃគណៈអភិបាលមានភារកិច្ចអនុវត្តការងារនៅពេលដែលក្រុមប្រឹក្សាអនុម័តរួច ដោយមានការជួយសម្រួលពីនាយករដ្ឋបាល។ នៅក្នុងនេះផងដែរតួអង្គនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានដូចជានាយករដ្ឋបាល នាយករងរដ្ឋបាល ប្រធានហិរញ្ញវត្ថុ អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ស្មៀនឃុំ និងបុគ្គលិកជាមន្ត្រីរាជការ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

### I.ក្រុមប្រឹក្សា

នៅក្នុងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិក្រុមប្រឹក្សាមានតួនាទី ភារកិច្ចយ៉ាងសំខាន់ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវបានធានាគណនេយ្យភាពជូនប្រជាពលរដ្ឋ ព្រមទាំងចំពោះខ្លួនឯង និងចំពោះរាជរដ្ឋាភិបាល នៅសកម្មភាពដែលខ្លួនបានធ្វើ។

### ក.ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

#### ១.ការជ្រើសរើសសមាជិកក្រុមប្រឹក្សា

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សា ដែលត្រូវបានជ្រើសរើសឡើងដោយការបោះឆ្នោតមិនផ្ទាល់ ដោយយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកបោះឆ្នោត តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ។ ក្រុមប្រឹក្សាគឺជាតំណាងប្រជាពលរដ្ឋនិងជាអ្នកធ្វើសេចក្តីសម្រេចនានាក្នុងនាមប្រជាពលរដ្ឋ ក្នុងន័យផ្តល់សេវាសាធារណៈ និងអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីបម្រើផលប្រយោជន៍ និងតម្រូវការរបស់ប្រជាពលរដ្ឋ

នៅមូលដ្ឋានរបស់ខ្លួន។ ប្រជាពលរដ្ឋជាអ្នកបោះឆ្នោតដោយផ្ទាល់ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ ដោយឡែកក្នុងនាមប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងមុខតំណែង ត្រូវបោះឆ្នោតជ្រើសរើសសមាជិកនៃក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។ ការបោះឆ្នោតត្រូវធ្វើឡើងដោយប្រព័ន្ធសមាមាត្រ។ គណបក្សនយោបាយដែលមានបំណងចុះឈ្មោះបេក្ខជននៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ក្នុងការឈរឈ្មោះឲ្យគេបោះឆ្នោតជូន ត្រូវដាក់បញ្ជីឈ្មោះបេក្ខជនសមាជិកក្រុមប្រឹក្សារបស់គណបក្សនយោបាយរបស់ខ្លួនទៅឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត **(គ.ជ.ប)**។ បេក្ខជនដែលមានសិទ្ធិឈរឈ្មោះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាខណ្ឌ ត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដូចជា៖

១. មានសញ្ជាតិខ្មែរពីកំណើត

២. មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត

៣. មានសិទ្ធិបោះឆ្នោត និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា[13]។

តាមន័យនេះគឺថាប្រជាពលរដ្ឋត្រូវមានសិទ្ធិ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងមូលដ្ឋានរបស់ខ្លួនដែលខ្លួនពេញចិត្ត ហើយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ឆ្នោតនោះ នឹងត្រូវមានសិទ្ធិទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ក្នុងនាមជាតំណាងឲ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។
ឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាដែលជ្រើសរើសដោយតាមការបោះឆ្នោតដោយផ្ទាល់ តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់[14] ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមរយៈការបោះឆ្នោតជាទូទៅ ជាលក្ខណៈសកល ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់[15]។

[13] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ មាត្រា២១។
[14] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ មាត្រា៦ លេខ ២១៥អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩។
[15] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់មាត្រា២។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកាន់តំណែងដែលទទួលបានពីការឈ្នះពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រហូតផុតអាណត្តិដែលនឹងត្រូវបានមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីឡើងចូលកាន់តំណែងជំនួស។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតជូន ត្រូវបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវឲ្យមួយចំនួនដូចខាងក្រោម៖

១. មានសញ្ជាតិខ្មែរ

២. មានអាយុ១៨(ដប់ប្រាំបី) ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត

៣. មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត

៤. មិនត្រូវស្ថិតនៅក្នុងស្ថានភាពជាប់នៅសក្នុងពន្ធធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត

៥. ពុំមែនជាជនវិកលចរិក ឬស្ថិតនៅក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច[16]។

## ២.អាណត្តិរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សានីមួយៗមានអាណត្តិ០៥ ឆ្នាំ ហើយផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាដែលជាប់ឆ្នោតចូលកាន់តំណែងជំនួស។ ក្រុមប្រឹក្សាត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលចូលជាធរមាន។ នៅក្នុងក្រុមប្រឹក្សានីមួយៗដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួនមានសមាសភាពប្រែប្រួលទៅតាមបរិបទនៃក្រុមប្រឹក្សានីមួយនោះ។ ដែលមានសមាសភាពដូចខាងក្រោម៖

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពី២១(ម្ភៃមួយ)រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពី០៩ (ប្រាំបួន) រូប ដល់២១ (ម្ភៃមួយ) រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពី០៧ (ប្រាំពីរ) រូប ដល់១៥ (ដប់ប្រាំ) រូប
- ក្រុមប្រឹក្សាស្រុក ខណ្ឌ មានចំនួនសមាជិកពី០៧ (ប្រាំពីរ) រូប ដល់១៩ (ដប់ប្រាំបួន) រូប
- ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ មានចំនួនសមាជិកពី០៥ (ប្រាំ) រូប ដល់១១ (ដប់មួយ) រូប។

ចំនួនជាក់ស្តែង នៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវបានកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[17]។

[16] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់មាត្រា១២។

ប្រធានក្រុមប្រឹក្សា ជាបេក្ខជនដែលមានឈ្មោះនៅលំដាប់លេខរៀងទី១ នៃបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលទទួលបានអាសនៈច្រើនជាងគេ។

នៅក្នុងឆ្នាំ២០១៥ នៅទូទាំងប្រទេស សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញមានចំនួន២១រូប សមាជិកក្រុមប្រឹក្សាខេត្តមានចំនួន៣៧២រូប សមាជិកក្រុមប្រឹក្សាក្រុងមានចំនួន៣២៧រូប សមាជិកក្រុមប្រឹក្សាស្រុកមានចំនួន២.៣៨៨រូប សមាជិកក្រុមប្រឹក្សាខណ្ឌមានចំនួន២១៦រូប សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួន១១.៤៥៩រូប។

តារាងខាងក្រោមនេះ ជាតារាងដែលបង្ហាញពីទិន្នន័យមធ្យមភាគនៃអត្រាតំណាងប្រជាពលរដ្ឋរបស់សមាជិកក្រុមប្រឹក្សាម្នាក់ៗតាមប្រភេទក្រុមប្រឹក្សានីមួយៗក្នុងឆ្នាំ២០១៥៖

| ល.រ | ប្រភេទក្រុមប្រឹក្សា | ចំនួនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចតាមប្រភេទក្រុមប្រឹក្សា | ចំនួនសមាជិកក្រុមប្រឹក្សា | អត្រាតំណាង ប្រជាពលរដ្ឋក្នុងសមាជិកក្រុមប្រឹក្សាម្នាក់ |
|---|---|---|---|---|
| ១ | ក្រុមប្រឹក្សារាជធានី | ១,៣៩៦,៨០៦ | ២១ | ៦៦,៥១៤ |
| ២ | ក្រុមប្រឹក្សាខេត្ត | ១៣,៣៧៣,៥៦៨ | ៣៧២ | ៣៥,៩៥០ |
| ៣ | ក្រុមប្រឹក្សាក្រុង | ១,៤៧៤,៤៨២ | ៣២៧ | ៤,៥០៩ |
| ៤ | ក្រុមប្រឹក្សាស្រុក | ១១,៨៩៩,០៨៦ | ២,៣៨៨ | ៤,៩៨២ |
| ៥ | ក្រុមប្រឹក្សាខណ្ឌ | ១,៣៩៦,៨០៦ | ២១៦ | ៦,៤៦៦ |
| ៦ | ក្រុមប្រឹក្សាឃុំ សង្កាត់ | ១៤,៧៧០,៣៧៤ | ១១,៤៥៩ | ១,២៨៨ |

តារាងទី ២៖អត្រាតំណាងប្រជាពលរដ្ឋរបស់សមាជិកក្រុមប្រឹក្សា[18]

## ៣.តួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

ក្នុងនាមជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងចាត់ចែងរាល់កិច្ចការផ្សេងៗ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយ តម្លាភាព គណនេយ្យភាព សមធម៌ និងបរិយាបន្ន ដើម្បីឆ្លើយតបទៅនិងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដើម្បីជាស្នូលនៃការអភិវឌ្ឍមូលដ្ឋាន សំដៅដល់ការលើកកម្ពស់គុណភាពជីវិតរបស់

[17] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ មាត្រា១៨។

[18] បាឋកថា ស្តីពីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បោះពុម្ពផ្សាយ ខែវិច្ឆិកា ឆ្នាំ២០១៥ ទំព័រ៣៥

ប្រជាពលរដ្ឋ ប្រកបដោយវិបុលភាព ផាសុកភាព និងសុខុមាលភាព។ ដើម្បីសម្រេចបាននូវបេសកកម្មដ៏ចម្បងនេះ ក្រុមប្រឹក្សាត្រូវបានផ្តល់សិទ្ធិអំណាចមួយចំនួនដូចជាការធ្វើដីការបស់ក្រុមប្រឹក្សា មានសិទ្ធិអំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ ទន្ទឹមនេះ ក្រុមប្រឹក្សាត្រូវធានាថា រាល់សេចក្តីសម្រេចរបស់ខ្លួន ត្រូវបានយកទៅអនុវត្តយ៉ាងពេញលេញនៅក្នុងដែនសមត្ថកិច្ចនៃក្រុមប្រឹក្សា រួមទាំងអភិបាល នៃគណៈអភិបាល និងបុគ្គលិកនៃរដ្ឋបាលរបស់ខ្លួន និងដោយមេឃុំ ចៅសង្កាត់ចំពោះរដ្ឋបាលឃុំ សង្កាត់។

កិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ក្នុងការធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា មានដូចខាងក្រោម៖

- ការរៀបចំទទួលមុខងារ ភារកិច្ច និងធនធាន
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងៗ
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនដល់ប្រជាពលរដ្ឋ។

ក្រៅពីកិច្ចការខាងលើនេះ ក្រុមប្រឹក្សាត្រូវបំពេញកិច្ចការផ្សេងៗទៀត ដែលបានកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានាដែលបានចូលជាធរមាន។

នៅក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ក្រុមប្រឹក្សានៅគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិមានគណៈកម្មាធិការជំនាញរបស់ខ្លួនមួយចំនួន(សូមមើលរូបភាពទី១១) ដើម្បីផ្តល់ការគាំទ្រចាំបាច់ផ្សេងៗដល់ក្រុមប្រឹក្សាក្នុងការសិក្សា ស្រាវជ្រាវដោយមានការចូលរួម ការពិគ្រោះយោបល់ក្នុងចំណោមអ្នកពាក់ព័ន្ធនានារួចហើយត្រូវលើកយោបល់ ឬការផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សា ដើម្បីឲ្យក្រុមប្រឹក្សាមានលទ្ធភាពធ្វើសេចក្តីសម្រេចដោយមានព័ត៌មានគ្រប់គ្រាន់ និងមានការវិនិច្ឆ័យច្បាស់លាស់។

(សូមមើលរចនាសម្ព័ន្ធ១២)

**II.អង្គប្រតិបត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រៅពីក្រុមប្រឹក្សានីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាអ្នកមានសិទ្ធិអំណាចក្នុងការចេញដីកា សេចក្តីសម្រេចនានាដើម្បីដាក់ឲ្យអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្រុមប្រឹក្សានៅមានអង្គប្រតិបត្តិផ្សេងៗទៀត ដែលគាំទ្រក្នុងដំណើរការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដូចជា៖ អភិបាល នៃគណៈអភិបាល នាយករដ្ឋបាល មេឃុំ ចៅសង្កាត់ និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកតួនាទី ភារកិច្ច និងមានគណនេយ្យភាពទៅតាមតួនាទី ភារកិច្ច រៀងៗខ្លួន ដែលជាយន្តការមួយជួយជំរុញនូវការគាំទ្រគោលនយោបាយ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន។

**១.គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឲ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ គណៈអភិបាល រួមមានប្រធានមួយរូបដែលហៅថា អភិបាល និងមានអភិបាលរងមួយចំនួន ដោយយោងតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានកំណត់អំពីសមាសភាពនៃចំនួនគណៈអភិបាលដូចខាងក្រោម៖

- គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧) រូប។
- គណៈអភិបាលខេត្តមានចំនួនពីរបី(០៣) រូប ទៅប្រាំពីរ(០៧) រូប។
- គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣) រូប ទៅប្រាំ(០៥) រូប។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុកខណ្ឌ ត្រូវបានកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយតាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ចំពោះអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។ អភិបាលរងរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌត្រូវតែងតាំងដោយអនុក្រឹត្យ។ អភិបាលរងក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលរាជធានីខេត្ត ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរដ្ឋបាលជាន់ខ្ពស់ដែលស្ថិតក្នុងក្របខ័ណ្ឌទាំងពីរភេទរបស់ក្រសួងមហាផ្ទៃ។ លើសពីនេះទៅទៀត បច្ចុប្បន្នការលើកកម្ពស់សមភាព យ៉េនឌ័រ ដើម្បីឲ្យស្ត្រីបានចូលរួមយ៉ាងសកម្មនៅក្នុងបណ្តាថ្នាក់ដឹកនាំ រាជរដ្ឋាភិបាលបានខិតខំរៀបចំឲ្យមានស្ត្រីចូល

រួមយ៉ាងហោចណាស់មានស្ត្រី០១រូប នៅក្នុងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

| មុខតំណែង | ឋានន្តរស័ក្តិ | អាយុ អប្បបរមា(ឆ្នាំ) | បទពិសោធន៍ ការងារ(ឆ្នាំ) | សញ្ញាបត្រ |
|---|---|---|---|---|
| អភិបាល រាជធានី ខេត្ត | ឧត្តមមន្ត្រី | ៣៥ | ០៧ | បរិញ្ញាបត្រ |
| អភិបាលរង រាជធានី ខេត្ត | វរមន្ត្រី | ៣៥ | ០៥ | បរិញ្ញាបត្រ |
| អភិបាល ក្រុង ស្រុក ខណ្ឌ | អនុមន្ត្រី | ៣០ | ០៥ | បរិញ្ញាបត្រ |
| អភិបាលរង ក្រុង ស្រុក ខណ្ឌ | នាយក្រមការ | ២៥ | ០៣ | បរិញ្ញាបត្ររង |

តារាងទី៣៖ តារាងលក្ខណៈសម្បត្តិរបស់អភិបាល អភិបាលរងក្នុងការតែងតាំង[19]

លក្ខណសម្បត្តិក្នុងការតែងតាំងខាងលើ បទពិសោធន៍ការងារសំដៅលើបទពិសោធន៍ផ្នែករដ្ឋបាលសាធារណៈ។ ចំពោះលក្ខណខណ្ឌនៃបទពិសោធន៍ការងារ និងកម្រិតសញ្ញាបត្រ បេក្ខជនត្រូវមានមួយណាក៏បាន ឬមានទាំងពីរកាន់តែប្រសើរ។ ក្រៅពីលក្ខណសម្បត្តិដូចចែងក្នុងតារាងខាងលើនេះ បេក្ខជនត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងរយៈពេលនៃការតែងតាំង និងមិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។ អភិបាល អភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានអាណត្តិការងារមិនលើសពីបួនឆ្នាំ(០៤) ឆ្នាំ និងអាចបន្តនៅអាណត្តិទីពីរបានរយៈពេលបួន(០៤) ឆ្នាំបន្ថែមទៀត នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដដែល។ អភិបាល អភិបាលរងមិនមែនជាសមាជិករបស់ក្រុមប្រឹក្សាឡើយ អភិបាល អភិបាលរងអាចចូលរួមគ្រប់អង្គប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាបាន ប៉ុន្តែមិនអាចធ្វើការបោះឆ្នោតបានឡើយ[20]។

[19] ព្រះរាជក្រឹត្យ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ជំពូកទី ៣ និងទី៤ ស្តីពីការរៀបចំមុខតំណែង និងក្របខណ្ឌ។

[20] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា១៣៩ ដល់ ១៤៩។

## ២.តួនាទី ភារកិច្ចរបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គណៈអភិបាលមានតួនាទី ភារកិច្ចចម្បងៗដូចខាងក្រោមៈ

- ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនដល់ក្រុមប្រឹក្សាអំពីកិច្ចការផ្សេងៗ ដែលពាក់ព័ន្ធនឹងសិទ្ធិអំណាចខាងបញ្ញត្តិ និងមានសិទ្ធិអំណាចខាងប្រតិបត្តិ ដើម្បីឲ្យក្រុមប្រឹក្សាធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹងៈ
    - ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឲ្យក្រុមប្រឹក្សា និងអំពីរបៀប បែបបទ នីតិវិធីការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ។
    - ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយក មុខងារ ភារកិច្ច និងធនធាន ដែលបានប្រគល់ ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
    - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ។
    - គម្រោងថវិកាប្រចាំឆ្នាំ។
    - ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យនានា។
    - ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក។
    - ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក។
    - ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់បៀវត្ស និងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សា។
    - ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិក របស់ក្រុមប្រឹក្សា។
    - ការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា។
    - ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការចាំបាច់ដើម្បីជួយសម្រួលដល់ដំណើរការអនុវត្តការងាររបស់ក្រុមប្រឹក្សា។
    - ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានទៅដល់សាធារណជន នៅលើក្តាព័ត៌មាន និងការស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនដល់ប្រជាពលរដ្ឋដើម្បីឲ្យប្រជាពលរដ្ឋទទួលបានព័ត៌មានគ្រប់គ្នា នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានានិងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

**២.១.តួនាទីជាតំណាងក្រសួងស្ថាប័ន**

ក្រៅពីបំពេញតួនាទីក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាតំណាងរបស់ ក្រសួង ស្ថាប័ន របស់ខ្លួនដែលដឹកនាំដោយរាជរដ្ឋាភិបាល ក្នុងការសម្រប សម្រួល តម្រង់ទិស មន្ទីរអង្គភាព ខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារផ្សេងៗ របស់រាជរដ្ឋាភិបាល ដែលមានសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះ អភិបាល ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងឲ្យ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុវត្តជាតំណាងរាជរដ្ឋាភិបាល និងតំណាង ក្រសួង ស្ថាប័ន លើកិច្ចការដូចខាងក្រោម៖

- ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងអំពី ច្បាប់ និងធានាឲ្យមានកាអនុវត្តច្បាប់ ព្រមទាំងធានាឲ្យមានការការពារ និងការគោរពសិទ្ធិ មនុស្សចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពក្នុងការដឹកនាំ សម្របសម្រួលមន្ទីរ ការិយាល័យ អង្គភាពពាក់ព័ន្ធនានា ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយ សាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ណែនាំដល់មន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឲ្យអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវស្រប តាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនិងមន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ។
- សម្របសម្រួលតម្រង់ទិសដល់មន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅក្នុងដែនសមត្ថកិច្ច ដើម្បីឆ្លើយតបដែលជាតម្រូវការជាអាទិភាពនៅ មូលដ្ឋាន។ ករណីមានកិច្ចការពាក់ព័ន្ធច្រើនវិស័យ អភិបាលត្រូវធ្វើការសម្របសម្រួល ជាមួយមន្ទីរ ការិយាល័យអង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា នៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អភិបាលត្រូវធ្វើការសម្រប

សម្រួល តម្រង់ទិសដល់មន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដើម្បីធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សា។

- ធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ ការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវ នៃទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលបំពេញការងារនៅក្នុងដែនដីរបស់ខ្លួនឲ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់ នៅពេលដែលពិនិត្យឃើញថាមានភាពមិនប្រក្រតី នៅក្នុងមន្ទីរ ការិយាល័យ និងទីភ្នាក់ងារនានាណាមួយ ឬមានការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរ ការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវ នៃទីភ្នាក់ងារណាមួយ។
- រាយការណ៍ជាលាយលក្ខអក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងប្រធានមន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារសាមី ក្នុងករណីដែលប្រធានមន្ទីរ អង្គភាព ការិយាល័យ និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងសភាពមិនប្រក្រតី ឬមានការប្រព្រឹត្តខុសក្នុងលក្ខណៈធ្ងន់ធ្ងរ។
- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងប្រធានមន្ទីរ ការិយាល័យ អង្គភាព ឬអ្នកទទួលខុសត្រូវទីភ្នាក់ងារណាដែលប្រព្រឹត្តខុសឆ្គង ហើយដែលមិនអាចធ្វើយុត្តិកម្មបាន[21]។

## ៣.តួនាទី និងភារកិច្ចរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ

- អភិបាល មានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដើម្បីណែនាំ សម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាព ខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។
- អភិបាល ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ច្បាប់ សិទ្ធិមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានា។

### ៣.១.សិទ្ធិរបស់ក្រុមប្រឹក្សាជាមួយគណៈអភិបាល

ក្រុមប្រឹក្សា អាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីមុខដំណែង ដោយផ្អែកទៅកំហុសណាមួយរបស់អភិបាល អភិបាលរងទាំងនោះដោយមូលហេតុដូចជា៖

[21] បបកថាស្តីពីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាខែវិច្ឆិកា ឆ្នាំ២០១៥ ទំព័រ ៣១ដល់ទំព័រ ៤២។

- អភិបាល អភិបាលរង បានដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរ ជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬត្រូវបានដកហូតមុខដំណែង។
- បាត់បង់លក្ខណជាអភិបាល ឬអភិបាលរង
- អសមត្ថភាព
- បំពេញការងារមិនបានល្អ
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
- បោះបង់ចោលការងារ
- ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។

នៅពេលមានករណីនេះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នឹងធ្វើការស៊ើបអង្កេតជាបន្ទាន់នូវសំណើខាងលើរបស់ក្រុមប្រឹក្សា ស្តីពី ការដកហូតមុខដំណែងណាមួយ ដើម្បីធ្វើសេចក្តីសម្រេច ជូនទៅរាជរដ្ឋាភិបាល ដើម្បីពិនិត្យ សម្រេច ចំពោះបញ្ហានេះ។

### ៣.២.តួនាទីអភិបាលជាមួយក្រុមប្រឹក្សា

អភិបាល មានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំសម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាព ខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

អភិបាល ត្រូវធ្វើជាតំណាងឲ្យរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាល ត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានា។

## ៤.នាយករដ្ឋបាល

នាយករដ្ឋបាលនីមួយៗត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទៅក្នុងក្រុមប្រឹក្សានីមួយៗ ដែលត្រូវមាននាយករដ្ឋបាលមួយរូប មានតួនាទីជាជំនួយការក្នុងការចាត់ចែងការងារកិច្ចការរដ្ឋបាលជាប្រចាំ និងធានានិរន្តរភាពការងាររដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលរបស់ខ្លួន។

### ៤.១.ភារកិច្ចរបស់នាយករដ្ឋបាល

នាយករដ្ឋបាល មានភារកិច្ច ដូចខាងក្រោមៈ

- អនុវត្តកិច្ចការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- ធានាឲ្យអង្គភាព មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន

- អនុវត្តដីការបស់ក្រុមប្រឹក្សា
- ចូលរួម និងផ្តល់យោបល់ផ្សេងៗក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតឡើយ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ផ្តល់យោបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

គណៈអភិបាល អាចធ្វើប្រតិភូកម្មការងារទៅឲ្យនាយករដ្ឋបាល នូវកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពការងាររបស់គណៈអភិបាល ដើម្បីលើកជូនគណៈអភិបាលសម្រេច។

### ៤.២.តួនាទី និងគណនេយ្យភាព

នាយករដ្ឋបាល មានតួនាទីជាជំនួយការក្នុងការងារចាត់ចែង កិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។ នាយករដ្ឋបាលត្រូវធ្វើសេចក្តីរាយការណ៍ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

## ៥.បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### ក.ថ្នាក់ឃុំ សង្កាត់

នៅសាលាឃុំ សង្កាត់ បុគ្គលិកក្របខ័ណ្ឌមានស្មៀនឃុំ សង្កាត់តែមួយរូបតែប៉ុណ្ណោះ។ ស្មៀន ឃុំ សង្កាត់ គឺជាមន្ត្រីរាជការក្របខ័ណ្ឌក្រសួងមហាផ្ទៃ ដែលត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីឲ្យទៅបំពេញការងារនៅសាលាឃុំ សាលាសង្កាត់ ដើម្បីជួយកិច្ចការរបស់ឃុំ សង្កាត់ និងធានានិរន្តរភាពការងាររដ្ឋបាលនៅក្នុងឃុំ សង្កាត់។ ករណីសម្រេចពីក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់អាចស្នើសុំផ្លាស់ប្តូរស្មៀនឃុំ សង្កាត់បាន។ ក្រៅពីនេះ ឃុំ សង្កាត់មានសិទ្ធិជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដែលជាបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមការចាំបាច់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់។

### ខ.ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ

ក្រៅពីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលនីមួយៗមានបុគ្គលិកផ្សេងៗទៀតដែលមានគណនេយ្យភាពតាមឋានានុក្រមរបស់ខ្លួនចំពោះក្រុមប្រឹក្សា។ បុគ្គលិកទាំងនោះមានតួនាទីផ្តល់ការគាំទ្រផ្នែកច្បាប់ រដ្ឋបាល បច្ចេកទេស និងការគាំទ្រផ្សេងៗទៀត ដល់

គណៈអភិបាល ដើម្បីឲ្យគណៈអភិបាលអាចបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ដែលស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលចូលជាធរមាន។ បុគ្គលិកទាំងនេះ មានបីប្រភេទរួមមានដូចខាងក្រោមៈ

- បុគ្គលិកដែលតែងតាំងដោយក្រុមប្រឹក្សា
- បុគ្គលិកដែលតែងតាំងឲ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា និង
- បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញទៅឲ្យក្រុមប្រឹក្សា។

បុគ្គលិកប្រភេទទីមួយ គឺជាបុគ្គលិកដែលត្រូវបានជ្រើសរើសដោយការប្រកួតប្រជែង និង មានតម្លាភាព ផ្អែកតាមតម្រូវការចាំបាច់ក្នុងការបំពេញតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ស្របតាមគោលការណ៍នៃលក្ខន្តិកៈដោយឡែករបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិកក្រុមប្រឹក្សាប្រភេទទីពីរ គឺជាបុគ្គលិកដែលតែងតាំងឲ្យទៅបំពេញការងារជាមួយ ក្រុមប្រឹក្សា ក្នុងនោះរួមមាន គណៈអភិបាល និងនាយករដ្ឋបាល។ ការតែងតាំងគណៈអភិបាល ដើម្បីឲ្យទៅបម្រើការងារជាមួយក្រុមប្រឹក្សា ត្រូវធ្វើឡើងដោយស្របលក្ខខ័ណ្ឌ និងលក្ខណសម្បត្តិ ដូចមានរៀបរាប់ក្នុងតារាងខាងលើ[22]។ ដោយឡែកចំពោះការតែងតាំងនាយករដ្ឋបាល ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នាយករដ្ឋបាល មានតួនាទី ជាជំនួយការក្នុងការ ចាត់ចែងការងាររដ្ឋបាល និងធានានិរន្តភាពផ្នែកការងាររដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និង គណៈអភិបាលរបស់ខ្លួន និងជាអ្នកដែលធានាឲ្យអង្គភាព និងបុគ្គលិកដែលបំពេញការងារក្នុង អង្គភាពនានាដែលចំណុះឲ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗអនុវត្តការងារប្រកបដោយ ប្រសិទ្ធភាពនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។

បុគ្គលិកក្រុមប្រឹក្សាប្រភេទទីបី គឺជាបុគ្គលិកដែលត្រូវបានផ្ទេរទៅឲ្យក្រុមប្រឹក្សា នៅពេល ដែលមុខងារនៅថ្នាក់ជាតិត្រូវបានផ្ទេរទៅឲ្យក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមបញ្ញត្តិ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្រៅពីនេះក៏មានបុគ្គលិកដែល ត្រូវបានធ្វើសមាហរណកម្មឡើងវិញទៅក្នុងរចនាសម្ព័ន្ធថ្មីនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បន្ទាប់ពីក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតឲ្យបានចូលកាន់មុខតំណែងរបស់ខ្លួន នៅតាម រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ នៅក្រោយពេលបោះឆ្នោតនៅឆ្នាំនីមួយៗ។ បុគ្គលិកទាំងនោះនិងត្រូវបំពេញការងារប្រចាំថ្ងៃរបស់ខ្លួនទៅតាមរចនាសម្ព័ន្ធសាលារាជធានី ខេត្ត

[22] សូមមើលតារាងទី២ អំពីលក្ខណសម្បត្តិក្នុងការតែងតាំងអភិបាល

ក្រុង ស្រុក ខណ្ឌ ហើយនិងត្រូវផ្ទេរបញ្ចូលក្នុងបុគ្គលិកប្រភេទទីមួយ បន្ទាប់ពីមានព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែករបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិចូលជាធរមាន(23)។

ក្រុមប្រឹក្សានីមួយៗ ត្រូវធ្វើសេចក្តីសម្រេចនានាពាក់ព័ន្ធទៅនឹងការងារចាត់ចែងគ្រប់គ្រងបុគ្គលិកខាងលើ ស្របតាមបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមានការធ្វើសេចក្តីសម្រេចអំពីការតែងតាំង ការបណ្តេញចេញពីតំណែង ការកម្រិតប្រាក់បៀវត្សនិងអត្ថប្រយោជន៍ផ្សេងៗទៀតសម្រាប់បុគ្គលិករបស់ខ្លួន។ បច្ចុប្បន្ន ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ ដោយមានការសម្របសម្រួលពី លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងបំណងផ្តល់អំណាចដល់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ក្នុងការចាត់ចែង និងគ្រប់គ្រងបុគ្គលិករបស់ខ្លួន(24)។

## ៦. គណនេយ្យភាព

ការផ្តល់សេវាសាធារណៈ ដល់ក្រុមប្រឹក្សាតាមរយៈការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ បានធ្វើឲ្យផ្លាស់ប្តូរខ្សែគណនេយ្យភាពក្នុងការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ពីមុនមានតែសាលារាជធានី ខេត្តប៉ុណ្ណោះដែលត្រូវមានគណនេយ្យភាពចំពោះថ្នាក់ជាតិក្នុងការបំពេញការងាររបស់ខ្លួន។ ប៉ុន្តែតាមរយៈកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការនានា ក្រុមប្រឹក្សានីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានទំនាក់ទំនងគណនេយ្យភាពចំនួន០៣ប្រភេទដូចខាងក្រោម៖

ទីមួយ៖ គឺជាខ្សែគណនេយ្យភាពពីលើចុះក្រោម(ចំពោះប្រជាពលរដ្ឋ)។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ពីព្រោះក្រុមប្រឹក្សានីមួយៗនៅថ្នាក់ក្រោមជាតិជាតំណាងឲ្យសំឡេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ និងជាអ្នកដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ និងដោយមិនផ្ទាល់។ ក្នុងន័យនេះ ក្រុមប្រឹក្សានីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវគិតគូរ និងពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយក្នុងការធ្វើសេចក្តីសម្រេចក្នុងនានាពាក់ព័ន្ធ នឹងការប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួន ដើម្បីធានាឲ្យការសម្រេចរបស់ក្រុមប្រឹក្សាអាចឆ្លើយតបបានជាអតិបរមាទៅនឹងសេចក្តីត្រូវការជាអាទិភាព របស់ប្រជាពលរដ្ឋទូទៅនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយតម្លាភាព សមធម៌ និងបរិយាបន្ន។

ទីពីរ៖ គឺជា គណនេយ្យភាពពីក្រោមឡើងលើ(គណនេយ្យភាពចំពោះថ្នាក់ជាតិ)។ ទោះបីជា រដ្ឋបាលនីមួយៗទទួលបាននូវស្វ័យភាព និងសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងចាត់ចែង

[23] *សូមមើលរូបភាព និង ស្តីពីរចនាសម្ព័ន្ធនៅរដ្ឋបាលស្រុក និងខេត្ត។*

[24] ព្រះរាជក្រឹត្យ ស្តីពី លក្ខន្តកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

ធនធានរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងអភិវឌ្ឍមូលដ្ឋានយ៉ាងណាក្តី ក៏រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅតែមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន។ មានន័យថារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ពុំមានអធិបតេយ្យដោយឡែកនៅក្រៅការគ្រប់គ្រង នៃច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋនោះឡើយ។ ក្រុមប្រឹក្សានីមួយៗមានកាតព្វកិច្ចត្រូវគោរព ទៅតាមគោលការណ៍ នីតិវិធី និងស្តង់ដារនៃការផ្តល់សេវាដែលកំណត់ដោយក្រសួងស្ថាប័ននានា។ ក្នុងនេះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិ និងធ្វើការត្រួតពិនិត្យទៅលើនីត្យានុកូលភាព លើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថារាល់សេចក្តីសម្រេចនានា របស់ក្រុមប្រឹក្សាគឺធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដែលចូលជាធរមាន។ បើរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទាំងនោះ ត្រូវបានគេមើលឃើញថាផ្ទុយ នឹងបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលចូលជាធរមាននោះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំដើម្បីឲ្យកែសម្រួលនូវសេចក្តីសម្រេចនោះឡើងវិញ។ ទន្ទឹមគ្នានេះផងដែរ ប្រសិនបើក្រុមប្រឹក្សាមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំសាយក្រុមប្រឹក្សានោះ នឹងត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្មីមួយទៀតឡើងវិញ[25]។

ទន្ទឹមនេះ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ និងចៅសង្កាត់ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានា ក្នុងការបំពេញតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង និងស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

ទីបី៖ ជាគណនេយ្យភាពផ្ទៃក្នុងក្របខ័ណ្ឌនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ នេះគឺជាទំនាក់ទំនងរវាងអ្នកធ្វើសម្រេច ដែលបានកើតពីការបោះឆ្នោត(ក្រុមប្រឹក្សា) និងអង្គប្រតិបត្តិ។ ក្នុងនាមជាអ្នកអនុវត្ត នូវរាល់សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា គណៈអភិបាលត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សា។ ក្នុងន័យនេះ ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យរាល់ការអនុវត្តការងាររបស់គណៈអភិបាល ដើម្បីធានាថា រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវបានយកទៅអនុវត្តបានត្រឹមត្រូវ និងពេញលេញប្រកបដោយប្រសិទ្ធភាព ព្រមទាំងបំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ព្រមទាំងអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន ដែលជាយន្តការមួយជួយលើកកំពស់ដល់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

គណនេយ្យភាពសង្គម គឺជាការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះទង្វើរបស់ខ្លួនដែលបានអនុវត្តនូវមុខងារណាមួយដែលថ្នាក់ជាតិបានប្រគល់ឲ្យ ឬតាមរយៈការធ្វើប្រតិភូកម្មឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិសម្រេចនូវរាល់កិច្ចការទាំងនោះក្នុងនាមជាក្រសួងស្ថាប័នផ្ទាល់ខ្លួន។

---

[25] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា២៤ និង២៥)

ដោយឡែកប្រសិនបើការអនុវត្តនូវតួនាទី ភារកិច្ច និងមុខងារទាំងនោះរបស់បុគ្គលិកមន្ត្រីរាជការមេឃុំ ចៅសង្កាត់ នៅតាមមូលដ្ឋាននីមួយៗ នៅពេលដែលប្រជាពលរដ្ឋយល់ឃើញថាការអនុវត្តនោះមានភាពមិនប្រក្រតី ឬផ្ទុយស្រឡះពីច្បាប់ ដូចជាការធ្វើអត្រានុកូលដ្ឋាន ដោយយកកម្រៃលើសពីច្បាប់កំណត់ ឬមិនអនុវត្តនូវមុខងារណាមួយជាក់លាក់ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិប្តឹងទៅក្រុមការងារគណនេយ្យភាពខេត្ត ដោយក្រុមការងារនេះត្រូវប្រជុំរកដំណោះស្រាយអំពីបណ្តឹងនានារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលបានដាក់ពាក្យបណ្តឹងតាមរយៈការសរសេរជាលិខិតដាក់នៅតាមប្រអប់សំបុត្រគណនេយ្យភាពសង្គម យោងតាមរយៈនេះផងដែរក្រុមការងារគណនេយ្យភាពខេត្តនិងប្រជុំពិនិត្យសម្រេចនៅភស្តុតាងដែលបានចុះស៊ើបអង្កេត និងប្រមូលទិន្នន័យពីប្រជាពលរដ្ឋចំពោះប្រជាពលរដ្ឋដែលបានរាយការណ៍ គេមិនបានបញ្ចេញពីអត្តសញ្ញាណរបស់ពួកគាត់ឡើយ។ នៅពេលដែលក្រុមគណនេយ្យភាពខេត្តរកឃើញថាបណ្តឹងណាមួយមានប្រសិទ្ធភាពដោយមើលឃើញថា ថ្នាក់ដឹកនាំក្នុងរដ្ឋបាលមូលដ្ឋាននោះមានកំហុសហើយក្រុមការងារគណនេយ្យភាពខេត្ត និងសម្រេចដាក់ទណ្ឌកម្មទៅដល់រដ្ឋបាលនៅតាមមូលដ្ឋានដែលបានប្រព្រឹត្តនូវកំហុសទាំងនោះ ដោយបានបិទផ្សាយនូវសេចក្តីសម្រេចរបស់ក្រុមការងារគណនេយ្យភាពខេត្តជាសាធារណៈ។

## ៧.ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ

### ៧.១.និយមន័យភូមិ

ភូមិ គឺជាកន្លែងប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន។ ភូមិជាច្រើនរួមផ្តុំគ្នាបង្កើតបានឃុំ ឬសង្កាត់មួយ។ ភូមិមិនមែនជាថ្នាក់រដ្ឋបាលដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ។

ភូមិនីមួយៗ ត្រូវគ្រប់គ្រងដោយមេភូមិម្នាក់ អមដោយអនុប្រធានភូមិម្នាក់ និងសមាជិកភូមិម្នាក់ជាជំនួយការ[26]។

អាណត្តិការងាររបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ។ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងមុខតំណែង ត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មីមកជំនួស។

### ៧.២.បែបបទ និង នីតិវិធីនៃការជ្រើសរើសមេភូមិ

អនុលោមតាមមាត្រា ៣០ និងមាត្រា ៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសមេភូមិម្នាក់សម្រាប់ភូមិនីមួយៗចំណុះឃុំ សង្កាត់

[26] សេចក្តីណែនាំ លេខ២០០៤ ស.ណ.ន ស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង ជំនួយការភូមិ និងតួនាទី ភារកិច្ច របៀបរបបការងាររបស់ភូមិ ចំណុច ១ អំពីភូមិ

របស់ខ្លួន។ ការជ្រើសរើសមេភូមិត្រូវមានការទទួលស្គាល់ពីក្រសួងមហាផ្ទៃជាផ្លូវការ។ ដើម្បីធ្វើការជ្រើសរើសមេភូមិសម្រាប់ភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវចាត់ឲ្យមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងរបស់ខ្លួន រៀបចំជ្រើសរើសបេក្ខជនមេភូមិយ៉ាងតិច ០៣រូប សម្រាប់ភូមិនីមួយៗ ក្នុងឃុំ សង្កាត់របស់ខ្លួន។
- បេក្ខជនមេភូមិទាំងពីរភេទត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖
  - មានសញ្ជាតិខ្មែរ
  - មានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
  - មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
  - ចេះអាន និងសរសេរអក្សរខ្មែរ
  - មានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិដែលបានដាក់ស្នើបេក្ខជននោះ យ៉ាងតិច ០៦ខែជាប់ៗគ្នា។
- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ត្រូវពិគ្រោះពិភាក្សាគ្នាខិតខំដើម្បីឲ្យមានបេក្ខជនជាស្ត្រីនៅក្នុងភូមិនីមួយៗ។
- ក្រោយពីបានរៀបចំបេក្ខជនជាមេភូមិរួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័តបង្កើតគណៈកម្មាធិការបោះឆ្នោតដែលមានសមាជិកយ៉ាងច្រើន ០៣រូប ដោយមានស្មៀនឃុំ សង្កាត់ចូលរួមផងដែរ។ គណៈកម្មាធិការបោះឆ្នោត ត្រូវរៀបចំសន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗ ដោយប្រើក្រដាសពណ៌ស ដែលមានទំហំប៉ុនគ្នា ដោយសរសេរនូវឈ្មោះបេក្ខជន (សរសេរដោយដៃ ឬតាមប្រព័ន្ធកុំព្យូទ័រ) ដែលបានដាក់ស្នើដោយមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ទៅតាមលំដាប់អក្សរក្រមនៃឈ្មោះរបស់បេក្ខជនម្នាក់ៗ។ សន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗនោះ ត្រូវបានរៀបចំឡើងស្មើនឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សាមី។ សន្លឹកឆ្នោតសម្រាប់បេក្ខជននៃភូមិនីមួយៗត្រូវមានត្រារបស់ឃុំ សង្កាត់ដែលបោះនៅលើខ្នងនៃសន្លឹកឆ្នោតនោះ។
- បន្ទាប់ពីបានរៀបចំសន្លឹកឆ្នោតតាមភូមិនីមួយៗ រួចហើយ គណៈកម្មាធិការបោះឆ្នោតតាមរយៈមេឃុំ ចៅសង្កាត់ ត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសម្តងៗមួយ នៅតាមភូមិរបស់ខ្លួន ក្នុងរយៈពេលមិនលើសពី ០៧ថ្ងៃ បន្ទាប់ពីការដាក់ស្នើបេក្ខជន។
- ចំពោះនីតិវិធីចាប់ផ្តើមបោះឆ្នោតជ្រើសរើសត្រូវប្រព្រឹត្តទៅតាមដំណាក់កាលនីមួយៗ ដែលមានចែងក្នុងសេចក្តីណែនាំលេខ ០០៤ ស.ណ.ន ស្តីអំពីនីតិវិធី នៃការជ្រើសរើសមេភូមិ

ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបការងាររបស់ភូមិ[27]។

### ៧.៣.នីតិវិធីក្នុងការបញ្ឈប់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិពីមុខតំណែង

ក្នុងតួនាទីជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ គឺជាបុគ្គលដែលត្រូវបានគេបោះឆ្នោតជ្រើសរើសដោយមានការទទួលស្គាល់ពីក្រសួងមហាផ្ទៃ។ យ៉ាងណាមិញមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ ជាអ្នកដែលនៅជិតស្និតជាមួយនឹងប្រជាពលរដ្ឋជាងគេបំផុតនៅថ្នាក់មូលដ្ឋាន ដោយប្រជាពលរដ្ឋភាគច្រើនពេលមានបញ្ហាផ្សេងៗ ពួកគាត់តែងតែទៅជួបជាមួយមេភូមិរបស់ខ្លួនដើម្បីឲ្យជួយដោះស្រាយនូវបញ្ហាដែលពួកគាត់កំពុងប្រឈម។

ទន្ទឹមនឹងនេះផងដែរប្រសិនបើមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាមួយដែលបានប្រព្រឹត្តខុសឆ្គងក្នុងការងារ មេឃុំ ចៅសង្កាត់សាមីត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរ ឲ្យសាមីខ្លួនកែលម្អចំណុចខុសឆ្គងទាំងនោះ និងធ្វើសេចក្តីរាយការណ៍ជូនក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ ប្រសិនបើជាការធ្វើសេចក្តីព្រមាន រំលឹកដាស់តឿននេះពុំមានលទ្ធផលនោះទេ មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ជាបន្តទៀត ដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះអញ្ជើញសាមីខ្លួន និងដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំអំពីការណែនាំឲ្យធ្វើការកែលម្អនូវកំហុសឆ្គង។ ប៉ុន្តែប្រសិនបើនៅតែគ្មានលទ្ធផលទៀតនោះមេឃុំ ចៅសង្កាត់នឹងស្នើសុំឲ្យក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចអនុម័តបញ្ឈប់ជននោះចេញពីមុខតំណែង តាមសំឡេងលើសពីពាក់កណ្តាល នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។ ក្នុងករណីនេះផងដែរក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការជ្រើសរើសមេភូមិសម្រាប់កន្លែងដែលទំនេរនោះក្នុងរយៈពេល ០៧ថ្ងៃយ៉ាងយូរ[28]។

ចំពោះលក្ខខ័ណ្ឌនានានៃការបាត់បង់មុខតំណែងនេះមានដូចជា៖

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរ
- សាមីខ្លួនបាត់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត នៃឃុំ សង្កាត់របស់ខ្លួន
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ
- សាមីខ្លួនផ្លាស់ទីលំនៅទៅកន្លែងផ្សេងទៀត

[27] សូមមើលឧបសម្ព័ន្ធទី១៦ ចំណុច ច

[28] សូមមើលឧបសម្ព័ន្ធទី ១៦

- សាមីខ្លួនមានកំហុងធ្ងន់ក្នុងការងារ ហើយត្រូវបានបញ្ឈប់ពីមុខតំណែងដោយក្រុមប្រឹក្សាក្នុងឃុំ សង្កាត់របស់ខ្លួន។

មេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិត្រូវអនុវត្ត តួនាទី ភារកិច្ច និងរបៀបរបបការងារឲ្យស្របតាមសេចក្តីណែនាំលេខ០០៤ ស.ណ.ន ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពី បែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ។

# ជំពូកទី៣
# ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## I.ថវិកានៅថ្នាក់ក្រោមជាតិ

នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ច្បាប់ស្ដីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងធនធានផ្ទាល់ខ្លួន ដែលសមស្របដើម្បីបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព មានតម្លាភាព និងមានគណនេយ្យភាព។ ដោយឡែកប្រភពចំណូលដែលរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានរួមមានៈ

- ប្រភពចំណូលនៅមូលដ្ឋាន
- ប្រភពពីថ្នាក់ជាតិ និង
- ប្រភពផ្សេងៗទៀត។

ចំណូលពីប្រភពមូលដ្ឋានរួមមានៈ

- ពន្ធនៅមូលដ្ឋាន
- ឈ្នួល កម្រៃ និងចំណូលមិនមែនជាសារពើពន្ធផ្សេងទៀត
- ចំណូលរបស់ក្រុមប្រឹក្សាស្រុក បានមកពីពន្ធ ឈ្នួល និងកម្រៃដែលត្រូវចែករំលែក រវាងក្រុមប្រឹក្សាស្រុក ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក
- អំណោយស្ម័គ្រចិត្ត
- ប្រភពផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ឬអនុក្រឹត្យ។

ចំណូលពីថ្នាក់ជាតិ រួមមានៈ

- ចំណូលចែករំលែក
- មូលនិធិផ្ទេរពីថវិការដ្ឋ និង
- ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមជាក្រសួងស្ថាប័ន[29]។

ផ្អែកលើបទប្បញ្ញត្តិនៃច្បាប់រៀបចំអង្គការ បានតម្រូវឲ្យរៀបចំច្បាប់ស្ដីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

[29] មាត្រា២៤៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ដើម្បីធានាដល់ការរៀបចំឲ្យប្រព័ន្ធផ្ទេរថវិកាជាតិ ទៅឲ្យថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព គណនេយ្យភាព និងសមធម៌ ដែលសំដៅឲ្យរដ្ឋបាលនៅថ្នាក់ក្រោមជាតិមានលទ្ធភាពអាចសម្រេចបានដោយប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលបានចាប់ផ្តើមបង្កើតមូលនិធិឃុំ សង្កាត់ បន្ទាប់មកគឺមូលនិធិក្រុង និងស្រុក និងបានធ្វើការកែសម្រួលខ្លះៗនូវការរៀបចំថវិការាជធានី ខេត្ត។ ចាប់តាំងពីឆ្នាំ២០០៣ មកដល់ឆ្នាំ២០១៧នេះ រាជរដ្ឋាភិបាលបានវិភាជន៍ថវិកា និងមូលនិធិដល់រដ្ឋបាលថ្នាក់ក្រោមជាតិសរុប ៥.០៩៧.៥៩៦.៨១៨.០០០រៀល (ប្រាំលានប្រាំបួនម៉ឺនប្រាំពីរពាន់ប្រាំរយកៅប្រាំមួយពាន់លានប្រាំបីសែនមួយម៉ឺនដប់ប្រាំពាន់រៀល) សមមូលនឹង ១.២៧៤.៣៩៩.២០៥ដុល្លារអាមេរិក (មួយពាន់ពីរយចិតសិបបួនពាន់លានបីសែនប្រាំបួនម៉ឺនប្រាំបួនពាន់ពីរយប្រាំដុល្លារអាមេរិក) ដែលក្នុងនោះ៖

- មូលនិធិរាជធានី ខេត្ត៖ ចំនួន ៣.៣៦៥.៧១៦.០០០.០០០ រៀល (បីលានបីសែនប្រាំមួយប្រាំពាន់ប្រាំពីររយដប់ប្រាំមួយពាន់លានរៀល) សមមូលនឹង ៨៤១.៤២៩.០០០ដុល្លារអាមេរិក) ចាប់ពីឆ្នាំ២០០៩ ដល់ ២០១៥។
- មូលនិធិក្រុង ស្រុក៖ ចំនួន ៣៧៥.៤០៤.០០០.០០០រៀល(ទិន្នន័យក្នុងឆ្នាំ២០១៧)។
- មូលនិធិឃុំ សង្កាត់៖ ចំនួន ៩៣.៨៥១.០០០ ដុល្លារអាមេរិក(ទិន្នន័យក្នុងឆ្នាំ២០១៧)។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានគៀរគរថវិកាពីដៃគូអភិវឌ្ឍន៍នានាសម្រាប់គាំទ្រដល់កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលមានចំនួនសរុប។

ដើម្បីធានាឲ្យមានតម្លាភាព គណនេយ្យភាព និងសមធម៌ក្នុងការទទួលបានធនធានពីថ្នាក់ជាតិ ការផ្ទេរមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ទៅឲ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវធ្វើឡើងតាមរូបមន្តកំណត់ជាក់លាក់មួយដូចខាងក្រោម៖

- សម្រាប់ឃុំ សង្កាត់៖ ចំណែកស្មើគ្នា ចំនួនប្រជាពលរដ្ឋ និងសន្ទទស្សន៍ភាពក្រីក្រ
- សម្រាប់ក្រុង ស្រុក៖ ចំណែកស្មើគ្នា

ជារួមមកយើងសង្កេតឃើញថាមូលនិធិ ដែលត្រូវបានផ្តល់ជូនទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិចាប់តាំងពីឆ្នាំ២០០២ រហូតមកដល់ឆ្នាំ២០១៧នេះមានចំនួនសរុបទាំងផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍គឺប្រមាណ ១៩៨,៥៧៩,០០០,០០០រៀល ជាមូលនិធិរបស់រដ្ឋបាលក្រុង ស្រុក និងមានចំនួន ៣៧,១៩៣,៥០០ដុល្លារអាមេរិក ជាមូលនិធិរបស់រដ្ឋបាលឃុំ សង្កាត់សរុបក្នុងឆ្នាំ២០១៧[30]។

[30] សូមមើលឧបសម្ព័ន្ធទី១៥

## II.របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ១.សមត្ថកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន រាជរដ្ឋាភិបាលអនុវត្តតាមគោលការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈស្ថាប័ន គ.ជ.អ.ប ដើម្បីអនុវត្តនូវការផ្ទេរធនធាន ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមជាប្រជាពលរដ្ឋដើម្បីចាត់ចែង ទ្រព្យសម្បត្តិ ធនធាន និងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជួយជម្រុញឲ្យដំណើរការអនុវត្តបាន ប្រសើរឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងមានគណនេយ្យ ភាពចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជា សេនាធិការ។

### ក.គណនេយ្យភាពរបស់ក្រុមប្រឹក្សា

នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ នីមួយៗត្រូវមានទំនួលខុសត្រូវដូចខាងក្រោម៖

- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងក្របខ័ណ្ឌចំណាយ រយៈពេលមធ្យម(ផអ៣)
- ពិនិត្យ និងអនុម័តផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំដែលដាក់ជូនដោយ អភិបាល និងមានសិទ្ធិក្នុងការផ្លាស់ប្ដូរថវិកា ក្នុងករណីក្នុងការផ្លាស់ប្ដូរមិនមែនការរំលោភ បំពានច្បាប់ បទបញ្ញា ឬគោលការណ៍នៃការរៀបចំថវិកា
- ពិនិត្យ និង អនុម័តការកែសម្រួលថវិកាទៅតាមសំណើរបស់អភិបាល
- ពិនិត្យ និង អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យ និង អនុម័តការជម្រះបញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមវិធាន និង បទបញ្ញាជាធរមាន
- តាមដានត្រួតពិនិត្យការអនុវត្តហិរញ្ញវត្ថុ និងថវិការបស់អភិបាល
- ពិនិត្យ និង អនុម័តកិច្ចសន្យាកិច្ចព្រមព្រៀងដែលបង្កើតកិច្ចសន្យាហិរញ្ញវត្ថុ ឬអត្ថប្រយោជន៍ លើសពីឆ្នាំថវិកាកំពុងអនុវត្ត។

**ខ.គណនេយ្យភាពរបស់អភិបាល នៃគណៈអភិបាល**

អភិបាល នៃគណៈអភិបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីជាតំណាងឲ្យក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។ នៅក្នុងវិស័យហិរញ្ញវត្ថុ អភិបាល នៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ជាអ្នកប្រតិបត្តិផ្ទាល់តាមដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តច្បាប់ដែលចេញដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងសេចក្តីសម្រេចផ្សេងៗទៀតដែលមានលក្ខណៈគតិយុត្តដើម្បីឲ្យអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

អភិបាល នៃគណៈអភិបាលរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវរាល់កិច្ចការរបស់ខ្លួនដូចជា៖

- រៀបចំផែនការអភិវឌ្ឍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ។
- អនុវត្តផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំ ដែលគម្រោងក្រុមប្រឹក្សាបានអនុម័តស្របទៅតាមវិធាន និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុជាធរមាន។
- រាយការណ៍ជាទៀងទាត់ជូនក្រុមប្រឹក្សាអំពីការអនុវត្តផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំ។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍អនុវត្តចំណូលចំណាយថវិកាប្រចាំឆ្នាំ និងរបាយការណ៍ផ្សេងៗទៀត ដែលបានដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តតាមកាលកំណត់។
- រាយការណ៍ជាទៀងទាត់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នដែលជាប់ពាក់ព័ន្ធដល់ដំណើរការអនុវត្ត និងស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោយពេលដែលរបាយការណ៍នានាដែលបានអនុម័តដោយក្រុមប្រឹក្សារួចហើយ។
- គ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងទ្រព្យសម្បត្តិរបស់ថ្នាក់ជាតិដែលទទួលបានដោយក្របខ័ណ្ឌច្បាប់ និងបទបញ្ញាជាធរមាន។

ប្រធានហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការជួយក្រុមប្រឹក្សា និង អភិបាល នៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យសម្រេចបាននូវរាល់ភារកិច្ចដែលបានដាក់ចេញ ព្រមទាំងមានការសម្របសម្រួលពីនាយករដ្ឋបាល និងមានការ

សហាការពីបណ្តាអង្គភាពនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះទៅទៀតប្រធានហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅក្រោមសិទ្ធិអំណាចរបស់អភិបាល នៃគណៈអភិបាល នៃរដ្ឋបាលនៅថ្នាក់ក្រោមជាតិនោះ។ ប្រធានហិរញ្ញវត្ថុត្រូវបានតែងតាំងដោយក្រុមប្រឹក្សា បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ បែបបទនៃការជ្រើសរើស តែងតាំង និងការកំណត់លក្ខណៈសម្បត្តិប្រធានហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## III.ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ក.គោលការណ៍គ្រប់គ្រងថវិកា

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានធនធានហិរញ្ញវត្ថុ និងថវិកាសមស្រប ដើម្បីអនុវត្តរាល់មុខងារ ភារកិច្ចសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពស្របតាមផែនការណ៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នីតិកាលទី៥នៃរដ្ឋសភាដែលមានអភិបាលកិច្ចល្អជាស្នូលនៃយុទ្ធសាស្ត្រ និងមានទិសដៅធ្វើកំណែទម្រង់នូវការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការកែទម្រង់ច្បាប់នឹងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់កងកម្លាំងប្រដាប់អាវុធ[31] ដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីគាំទ្រដល់កិច្ចដំណើការនៃការធ្វើកំណែទម្រង់ខាងផ្នែករដ្ឋបាលក៏ដូចជាផ្នែកផ្សេងៗទៀត ទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងការអភិវឌ្ឍនៅតាមមូលដ្ឋាន ដូចបណ្តាលប្រទេសមួយចំនួន ដែលរីកចម្រើនក្លាយជាប្រទេស ដែលមានការគ្រប់គ្រងរដ្ឋបាលឈានដល់ដំណាក់កាលនៃប្រភេទ**រដ្ឋបាលមូលដ្ឋាន**។ ជាក់ស្តែងប្រទេសថៃគឺជាប្រទេសមួយដែលប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមូលដ្ឋានបានល្អ ដែលគេអាចនិយាយបានថាជាប្រទេសគ្រប់គ្រងរដ្ឋបាលតាមរយៈរដ្ឋបាលមូលដ្ឋានយើងឃើញថា៖ រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រថៃឆ្នាំ១៩៩៧ បានចែងថា "រដ្ឋត្រូវធ្វើវិមជ្ឈការ ដើម្បីឲ្យបង្កើតឲ្យមានការពឹងផ្អែកលើខ្លួនឯង និងប្តេជ្ញាចិត្តដោយខ្លួនឯងចំពោះកិច្ចការថ្នាក់មូលដ្ឋាន ព្រមទាំងបង្កើតរដ្ឋបាលថ្នាក់ខេត្ត ឬលើថ្នាក់ខេត្ត ដើម្បីគាំទ្រឲ្យបានម៉ត់ចត់ និងស្មើភាពគ្នាដល់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ផលប្រយោជន៍សាធារណៈ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងប្រព័ន្ធព័ត៌មានសំខាន់ៗនៅទូទាំងប្រទេស ដើម្បីឆ្លើយតបចំពោះតម្រូវការនៅតាមមូលដ្ឋាន"។ ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសថៃធ្វើឡើងតាមរយៈប្រព័ន្ធទ្វេរ(Dual System) គឺជាប្រព័ន្ធរដ្ឋបាលមូលដ្ឋាន និងប្រព័ន្ធស្វ័យភាពមូលដ្ឋាន។[32] ដោយឡែកនៅក្នុងប្រព័ន្ធគ្របគ្រងរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ព្រះរាជាណាចក្រកម្ពុជាយើងវិញមិនទាន់ដល់កម្រិតមួយ ដែលគេហៅថា **"រដ្ឋបាលមូលដ្ឋាន"** ដូចព្រះរាជាណាចក្រថៃនៅឡើយទេ ដោយហេតុថាប្រទេសកម្ពុជាត្រូវបានជួបប្រទះនឹងបញ្ហាសង្គ្រាមផ្ទៃក្នុងរាំរ៉ៃអស់ជាង៣ទសវត្សន៍ ដែលជាហេតុបង្អាក់ដល់ដំណើរការអភិវឌ្ឍប្រទេសជាតិ។

[31] សូមមើលឧបសម្ព័ន្ធទី១០

[32] វិមជ្ឈការ និងវិសហមជ្ឈការ បោះពុម្ពដោយនាយកដ្ឋានបណ្តុះបណ្តាល អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ឆ្នាំទី១ លេខ១ ខែធ្នូ ឆ្នាំ២០១៥ ទំព័រ៥១

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុម័តប្រចាំឆ្នាំនីមួយៗ។ ការិយបរិច្ឆេទនៃឆ្នាំថវិការដ្ឋបាលថ្នាក់ក្រោមជាតិចាប់ផ្តើមនៅថ្ងៃទី ០១ ខែមករា ហើយបញ្ចប់ទៅវិញនៅថ្ងៃទី ៣១ ខែធ្នូ។[33] ថវិកាត្រូវរៀបចំ និងអនុម័តដោយមានតុល្យភាពពិតប្រាកដរវាងចំណូល និងចំណាយទៅតាមទម្រង់ និងចំណាត់ថ្នាក់ថវិកា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ និងអនុម័តទៅតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវផ្សព្វផ្សាយព័ត៌មានឲ្យបានពេញលេញអំពីការរៀបចំ និងអនុម័តថវិកា
- រាល់ចំណូល និងចំណាយទាំងអស់ត្រូវតែជាផ្នែកនៃថវិកាឯកភាពតែមួយគត់
- ថវិកាត្រូវបញ្ចូលចំណូល និងចំណាយទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចំណូលត្រូវប្រមូល និងបង្ហាញជាទឹកប្រាក់សរុបដោយគ្មានការកាត់កងចំណាយណាមួយឡើយ
- គ្មានចំណូលណាមួយត្រូវបានកំណត់សម្រាប់ការចំណាយជាក់លាក់ណាមួយឡើយ លើកលែងតែមានកាអនុញ្ញាតដោយបទប្បញ្ញត្តិដោយឡែក
- សរុបគម្រោងចំណាយត្រូវធានាទាំងស្រុងដោយសរុបគម្រោងចំណូល
- គ្មានចំណូល ឬចំណាយណាមួយត្រូវប្រមូល ឬប្រើប្រាស់ក្រៅពីខ្ទង់ថវិកាដែលបានអនុម័តបានឡើយ។

នៅក្នុងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិអភិបាល នៃគណៈអភិបាល អាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនទៅអភិបាលរងណាម្នាក់ទទួលបន្ទុកក្នុងការសម្រេចលើថវិកា ជាអាណាប័កផ្ទេរសិទ្ធិដែលធ្វើសកម្មភាពដោយស្ថិតក្នុងការទទួលខុសត្រូវ និង ត្រួតពិនិត្យរបស់អភិបាល។ អាណាប័ក និងអាណាប័កផ្ទេរសិទ្ធិត្រូវតម្កល់ហត្ថលេខាជាផ្លូវការដល់គណនេយ្យករសាធារណៈ។

ចំពោះចំណូលរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិគឺទទួលបានពី ចំណូលពីប្រភពមូលដ្ឋាន ចំណូលដែលទទួលបានពីថ្នាក់ជាតិ និងចំណូលផ្សេងៗទៀតដែលទទួលបានពីច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានាទៀត។ ដោយឡែកចំពោះការចំណាយថវិការដ្ឋបាលនៅថ្នាក់ក្រោមជាតិ រួមមាន៖ ចំណាយប្រតិបត្តិការរដ្ឋបាល បុគ្គលិក ចំណាយលើការអនុវត្តមុខងារជាកាតព្វកិច្ច ការចំណាយក្នុងអនុវត្តមុខងារជាជម្រើស និងការចំណាយក្នុងការអនុវត្តតួនាទី ភារកិច្ចផ្សេងៗទៀតដែលកំនត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត។ អភិបាល ឬអភិបាលរងដែលបានទទួលសិទ្ធិក្នុងការសម្រេចលើគម្រោងថវិកាត្រូវធ្វើរបាយការណ៍អំពីគម្រោងចំណូល ចំណាយ

[33] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មាត្រា១៨

ដោយមាននាយករដ្ឋបាលជួយសម្រួល ដើម្បីដាក់ជូនក្រុមប្រឹក្សាអនុម័តជារៀងរាល់ឆ្នាំ ដែលការអនុម័តនោះមាន០៣ ដំណាក់កាល គឺៈ

ដំណាក់កាលទី០១ គឺជាការរៀបចំផែនការយុទ្ធសាស្ត្រថវិកា(ពីខែមីនា ដល់ខែឧសភា)

ដំណាក់កាលទី០២ គឺជាការរៀបចំកញ្ចប់ថវិកា (ពីខែមិថុនា ដល់ខែកញ្ញា)

ដំណាក់កាលទី០៣ គឺជាការអនុម័តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(ពីខែតុលា ដល់ខែធ្នូ)

**ខ.ចំណូល និងចំណាយរបស់រដ្ឋបាលក្រុង ស្រុក**

ថវិការបស់រដ្ឋបាលក្រុង ស្រុកជាឯកសារគតិយុត្តដែលគ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុកដែលត្រូវចំណាយរបស់រដ្ឋបាលក្រុង ស្រុក និងមានចរិតលក្ខណៈតុល្យភាព។ ឆ្នាំថវិការបស់រដ្ឋបាលក្រុង ស្រុកចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ។

ថវិកាថវិការបស់រដ្ឋបាលក្រុងត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយរបស់រដ្ឋបាលស្រុកដោយមិនគិតដល់ប្រភពដើម ឬចរិតលក្ខណៈឡើយ។ ថវិការបស់រដ្ឋបាលក្រុងត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយទាំងអស់របស់រដ្ឋបាលក្រុង និងសង្កាត់នានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយមិនគិតដល់ប្រភពដើម ឬ ចរិតលក្ខណៈឡើយ។

ថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវឆ្លុះបញ្ចាំងរាល់ការចំណាយជាអាទិភាព នៃផែនការអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុករួមទាំងតម្រូវការចាំបាច់របស់ឃុំ សង្កាត់នៅក្នុងក្រុង ស្រុក។ ថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានរៀបចំឡើងជាពីរផ្នែកគឺៈ

ទីមួយៈ ចំណូល និងចំណាយចរន្ត

ទីពីរៈ ចំណូល និងចំណាយមូលធន។

ចំណូលសរុបត្រូវមានតុល្យភាពទៅនឹងចំណាយសរុប។ ក្នុងពេលរៀបចំ និងកែតម្រូវថវិកាដែលអតិរេកនៃចំណុចទី០១ ត្រូវបានប្រើជាគុណប្រយោជន៍ក្នុងចំណុចទី០២។ លើសពីនេះទៅ ចំណូលមូលធនមិនត្រូវបានប្រើប្រាស់សម្រាប់ធ្វើហិរញ្ញប្បទានបានឡើយ លើកលែងមានករណីមានការអនុញ្ញាតដោយឡែកណាមួយ។ ការរៀបចំគម្រោងចំណូលចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវធ្វើឡើងដោយផ្អែកតាមទម្រង់ និងចំណាត់ថ្នាក់ថវិកាដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការរៀបចំគម្រោងចំណូលចំណាយនេះផងដែរនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័តដោយក្រុមប្រឹក្សា ស្តីអំពី ការរៀបចំផែនការថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានធ្វើឡើងអភិបាល ឬអភិបាលរងណាម្នាក់ដែលទទួលបន្ទុក

នេះ ព្រមទាំងមានការជួយសម្រួលដោយ នាយករដ្ឋបាល ដើម្បីដាក់ជូនក្រុមប្រឹក្សាអនុម័ត ហើយចំពោះនីតិវិធីក្នុងការអនុម័តវិញគឺប្រព្រឹត្តទៅជាបីដំណាក់កាលដូចជា៖

១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែមីនា ដល់ខែឧសភា) ក្នុងដំណាក់កាលនេះរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាអ្នកចេញនូវសេចក្តីប្រកាសណែនាំស្តីអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដល់ក្រសួង ស្ថាប័ន អង្គភាពទាំងអស់ដើម្បីជូនដំណឹងដល់ក្រុមប្រឹក្សានីមួយៗនូវកម្មវិធី និងថវិកាក្នុងវិស័យរបស់ខ្លួន ដែលបានអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងនាមជាក្រុមប្រឹក្សា អភិបាល នៃគណៈអភិបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ធ្វើផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ផ.អ.៣.ទី២ (PILAC3) ជូនទៅក្រុមប្រឹក្សាពិនិត្យសម្រេច និងពិភាក្សាព្រមទាំងដាក់ជូនទៅមន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុ ដើម្បីបូកសរុបផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែឧសភា។

២. ការរៀបចំកញ្ចប់ថវិកា(ពីខែមិថុនា ដល់ខែកញ្ញា) នៅសប្តាហ៍ទីមួយ នៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំសារាចរណ៍ណែនាំស្តីពីបច្ចេកទេស នៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ពីទម្រង់បែបបទនីតិវិធីនៃការរៀបចំគម្រោងបែបបទថវិកា និងឯកសារនានាដែលពាក់ព័ន្ធផ្ញើជូនទៅឲ្យរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំគម្រោងស្តីពីចំណូល ចំណាយថវិកាលំអិតរបស់ខ្លួន។

៣. ការអនុម័តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(ពីខែតុលា ដល់ខែធ្នូ) នៅសប្តាហ៍ទី ១ នៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជូនគម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រី ពិនិត្យ សម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទី ១ នៃ ខែ វិច្ឆិកា ដើម្បីពិនិត្យអនុម័ត និង ដាក់ជូនព្រឹទ្ធសភានៅសប្តាហ៍ទី ១ នៃ ខែ ធ្នូ ដើម្បីសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ។

## IV.ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

### ១.ប្រភពចំណូលឃុំ សង្កាត់

នៅក្នុងការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ របស់រដ្ឋបាលឃុំ សង្កាត់គឺមានប្រភពចំណូលមាន៣ សំខាន់ៗ គឺ៖

- ប្រភពចំណូលផ្ទាល់ ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ[34]។ ប៉ុន្តែបច្ចុប្បន្ននេះ តាមប្រភេទ កម្រិត និងរបៀបនៃការប្រមូលផ្តុំចំណូលផ្ទាល់នេះនឹងត្រូវកំណត់ដោយច្បាប់ដោយឡែក ដែលបច្ចុប្បន្ន ឃុំ និងសង្កាត់មិនអាចអនុវត្តការប្រមូលចំណូលពីសារពើពន្ធដោយខ្លួនឯងបាននៅឡើយទេ ដោយហេតុថា មិនទាន់មានច្បាប់ស្តីពីការប្រមូលចំណូលនេះ។
- ចំណូលពីមូនិធិឃុំ សង្កាត់ គឺជាចំណូលដែលបានមកពីការផ្ទេរធនធានពីមូនិធិឃុំ សង្កាត់ឲ្យទៅឃុំ សង្កាត់នីមួយៗ ដែលក្នុងនោះមានចំណែកសម្រាប់ចំណាយផ្នែករដ្ឋបាល និងចំណាយផ្នែកអភិវឌ្ឍន៍ឃុំ សង្កាត់។
- ចំណូលបានមកពីភ្នាក់ងារ គឺជាចំណូល ដែលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ ដែលជំនួសដោយក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋ ទៅតាមការព្រមព្រៀងគ្នា។ ក្រៅពីចំណូលសំខាន់ៗទាំង០៣ នេះរដ្ឋបាលឃុំ សង្កាត់ទទួលបានចំណូលផ្សេងៗទៀតដូចជា៖
  - ចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន
  - ចំណូលពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានា។

ឃុំ សង្កាត់ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិទាំងនោះឲ្យបានម៉ត់ចត់ ត្រឹមត្រូវ ដើម្បីធានាថាការប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់មានប្រសិទ្ធភាព និងតម្លាភាព។

### ១.២.ថវិកាឃុំ សង្កាត់

នៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់ ត្រូវមានកញ្ចប់ថវិកាដែលទទួលបានពីចំណូលនានាដើម្បីអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនប្រកបដោយភាពល្អប្រសើ។ ម៉្យាងវិញទៀត ថវិកា គឺជាលិខិតគតិយុត្តដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិពេញលេញក្នុងការគ្រោងចំណូលចំណាយ និងអនុវត្តចំណូល ចំណាយ តាមថវិកាគ្រោង។

[34] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ មាត្រា៧៣

**ក.គោលការណ៍ថវិកាសំខាន់ៗ នៃការរៀបចំគម្រោងថវិកាឃុំ សង្កាត់**

- គម្រោងថវិកាឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តប្រចាំឆ្នាំ(ឆ្នាំថវិកាចាប់ពីថ្ងៃទី០១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ)។
- ថវិកាត្រូវតែតុល្យភាព ផែនការចំណាយសរុបត្រូវតែរ៉ាប់រងពេញលេញដោយផែនការចំណូលសរុប។
- ថវិកាឃុំ សង្កាត់ត្រូវតែឆ្លុះបញ្ចាំងចំណាយជាអាទិភាពរបស់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

**ខ.ការរៀបចំ ការអនុម័តនិងការបញ្ជាក់ទទួលស្គាល់គម្រោងថវិកា**

- មេឃុំ ចៅសង្កាត់ត្រូវធានាថា ដំណើរការនៃការរៀបចំថវិកាមានការចូលរួមពីប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។
- គណៈកម្មាធិការកសាងផែនការ និងថវិកាជួយមេឃុំ ចៅសង្កាត់ ក្នុងការរៀបចំគម្រោងថវិកាឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ ពិនិត្យនិងអនុម័តគម្រោងថវិកាឃុំ រួចបញ្ជូនទៅអភិបាលខេត្តដើម្បីត្រួតពិនិត្យនិងអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកានេះ។
- ក្រុមប្រឹក្សាសង្កាត់ចំណុះក្រុង ពិនិត្យ និងអនុម័តគម្រោងថវិកា សង្កាត់ រួចបញ្ជូនទៅអភិបាលក្រុងដើម្បីបញ្ចូលជាមួយថវិកាក្រុង។
- ក្រុមប្រឹក្សាសង្កាត់ចំណុះរាជធានី ពិនិត្យ និងអនុម័តគម្រោងថវិកាសង្កាត់រួចបញ្ជូនទៅអភិបាលរាជធានី ដើម្បីបញ្ចូលជាមួយគម្រោងថវិការាជធានី។
- អភិបាលខេត្ត ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិការបស់ឃុំ។
- អភិបាលខេត្ត ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិការបស់ក្រុង ដែលមានបញ្ចូលថវិកាសង្កាត់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិការបស់រាជធានី ដែលមានបញ្ចូលថវិកាសង្កាត់ចំណុះរាជធានី។

**គ.ការអនុវត្តថវិកាឃុំ សង្កាត់**

- **ការកែតម្រូវថវិកា ៖** ថវិកាឃុំ សង្កាត់អាចនឹងកែតម្រូវក្នុងឆ្នាំថវិកាដោយសារមានការផ្លាស់ប្តូរសភាពការណ៍សេដ្ឋកិច្ច និហិរញ្ញវត្ថុ ដែលជះឥទ្ធិពលដល់ការព្យាករណ៍ដំបូងនៃចំណូល និងចំណាយ។

- **ការកំណត់តម្លៃ និងប្រមូលចំណូល ៖** ការកំណត់នេះត្រូវបានចែងដោយបទប្បញ្ញត្តិដោយឡែកមួយ ដែលស្តីពីចំណូលចំណាយរបស់ឃុំ សង្កាត់។
- **ខ្ទង់នៃការចំណាយ ៖** រួមមាន ការសន្យាចំណាយ ការជម្រះបញ្ជី ការចេញអាណត្តិបើកប្រាក់ និងការទូទាត់ដូចដែលបានបញ្ជាក់ក្នុង ប្រកាសណែនាំស្តីពីនីតិវិធីចំណាយ និងលទ្ធកម្មរបស់ឃុំ សង្កាត់។ របាយការណ៍អំពីលទ្ធផលនៃការអនុវត្តថវិកា ឃុំ សង្កាត់ ត្រូវធ្វើតាមប្រតិទិន និងនីតិវិធីដែលបានបញ្ជាក់ក្នុងប្រកាសណែនាំស្តីពីប្រព័ន្ធទូទាត់ និងគណនេយ្យរបស់ឃុំ សង្កាត់។
- **ការបិទបញ្ជីថវិកា ៖**
    - នៅដំណាច់ឆ្នាំថវិកាឃុំ សង្កាត់ត្រូវបិទបញ្ជីថវិកា។
    - គណនេយ្យករឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍បិទបញ្ជីគណនេយ្យជូនមេឃុំ ចៅសង្កាត់។
    - ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័តរបាយការណ៍បិទបញ្ជីគណនេយ្យ។
    - អភិបាលរាជធានី ខេត្តពិនិត្យ និងបញ្ជាក់ទទួលស្គាល់លើសេចក្តីសម្រេចស្តីពីការបិទបញ្ជីថវិកា។

## ១.៣.ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់

### ក.គោលការណ៍ទូទៅ

- ឃុំ សង្កាត់ត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគាររាជធានី ខេត្ត។
- មេឃុំ ចៅសង្កាត់ជាអាណាប័ក និងមានសិទ្ធិពេញលេញលើការប្រមូល ឬការទទួលចំណូល ការអនុវត្តចំណាយ និងការចេញអាណត្តិបើកប្រាក់ ដោយផ្អែកលើថវិកាដែលបានអនុម័តរួច។
- មេឃុំ ចៅសង្កាត់អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាទៅឲ្យជំទប់ចៅសង្កាត់រងរបស់រដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពស្ថិតក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់។
- មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិត្រូវតម្កល់គំរូហត្ថលេខាជាផ្លូវការនៅរតនាគាររាជធានី ខេត្ត។
- មេឃុំ ចៅសង្កាត់ អ្នកទទួលសិទ្ធិ និងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ជាទូទៅ មិនត្រូវបានអនុញ្ញាតឲ្យកាន់កាប់មូលនិធិ ឬធ្វើការទូទាត់ចំណាយ លើកលែងតែករណីទូទាត់រដ្ឋទេយ្យបុរេប្រទាន និងចំណូលដែលប្រមូលបានដោយភ្នាក់ងារប្រមូលចំណូល។

- សិទ្ធិបញ្ជាចំណាយ និងការទូទាត់មិនត្រូវប្រគល់ឲ្យមនុស្សតែម្នាក់បានឡើយ។
- រតនាគាររាជធានី ខេត្តត្រូវបំពេញមុខងារជាគណនេយ្យករឲ្យឃុំ សង្កាត់[35]។

លើសពីនេះទៅទៀតនៅក្នុងរដ្ឋបាលឃុំ សង្កាត់នីមួយៗការគ្រប់គ្រងប្រព័ន្ធថវិកា ហរិញ្ញវត្ថុឃុំ សង្កាត់បានប្រព្រឹត្តទៅដោយមានប្រព័ន្ធទូទាត់ដែលជាប្រព័ន្ធទូទាត់ដោយផ្ទាល់ ជាការទូទាត់តាមរយៈរតនាគាររាជធានី ខេត្ត។

មួយវិញទៀតការទូទាត់តាមរយៈរជ្ជទេយ្យបុរេប្រទាន ដោយគិតជាចំនួនទឹកប្រាក់សម្រាប់មួយគោលការណ៍ចំណាយ ឬមួយប័ណ្ណចំណាយនៃរជ្ជទេយ្យបុរេប្រទានយ៉ាងច្រើនបំផុតត្រឹម ៥០០.០០០រៀល(ប្រាំរយពាន់រៀល)។

ប្រព័ន្ធគណនេយ្យ គឺជាប្រព័ន្ធគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុនានារបស់រដ្ឋបាលឃុំ សង្កាត់ ប្រព័ន្ធនេះត្រូវតែម៉ត់ចត់ និងត្រឹមត្រូវជានិច្ច។ ប្រព័ន្ធគណនេយ្យនៅក្នុងរដ្ឋបាលឃុំ សង្កាត់ត្រូវបានគេចែកជាពីរប្រភេទគឺ៖

**១.គណនេយ្យហិរញ្ញវត្ថុ ៖** គណនេយ្យករនៅរតនាគាររាជធានី ខេត្ត មានភារកិច្ចអនុវត្តគណនេយ្យហិរញ្ញវត្ថុ។ គណនេយ្យហិរញ្ញវត្ថុគឺជាកិច្ចបញ្ជីការរាល់ចំណូល ចំណាយទៅគណនេយ្យ។

**២.គណនេយ្យថវិកា ៖** មេឃុំ ចៅសង្កាត់មានភារកិច្ចទទួលខុសត្រូវចំពោះការអនុវត្តគណនេយ្យថវិកា។ គណនេយ្យថវិកា គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្ត ចំណូល ចំណាយ ថវិកាដែលបានអនុម័ត។

របាយការណ៍នៅក្នុងឃុំ សង្កាត់មាន០៣ប្រភេទគឺ៖

១.របាយការណ៍ស្តីពីចំណូល ចំណាយរបស់រដ្ឋបាលឃុំ សង្កាត់ប្រចាំខែ

២.របាយការណ៍ស្តីពីចំណូល ចំណាយរបស់រដ្ឋបាលឃុំ សង្កាត់ប្រចាំឆមាស

៣.របាយការណ៍ស្តីពីចំណូល ចំណាយរបស់រដ្ឋបាលឃុំ សង្កាត់ប្រចាំឆ្នាំ។

## ១.៤.ការកសាងផែនការឃុំ សង្កាត់

### ១.៤.១.គោលការណ៍សំខាន់ៗ នៃការកសាងផែនការឃុំសង្កាត់

ការកសាងផែនការឃុំ សង្កាត់ត្រូវផ្អែកលើគោលការណ៍សំខាន់ៗដូចខាងក្រោម៖

[35] ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ តាមបែបវិមជ្ឈការ បោះពុម្ពផ្សាយដោយ ន.ប.ប នាខែកក្កដា ឆ្នាំ២០១៧ ទំព័រ៣៧ ដល់ទំព័រ៤១។

- **ការចែករំលែកព័ត៌មាន ៖** ក្នុងកិច្ចដំណើរការការងារការកសាងផែនការនៅឃុំ សង្កាត់ ត្រូវមានការចែករំលែកព័ត៌មានរវាងរដ្ឋបាលថ្នាក់ផ្សេងៗគ្នា រវាងប្រជាពលរដ្ឋ រវាងការិយាល័យ អង្គភាព អង្គការជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល (NGO)ព្រមទាំងវិស័យឯកជននានា ដែលមានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។
- **តម្លាភាព ៖** ការកសាងផែនការត្រូវបានធ្វើឡើងស្របតាមបែបបទនីតិវិធី គោលការណ៍ណែនាំ មិនមានការលាក់លៀម គ្រប់ភាគីដែលមានការពាក់ព័ន្ធ នឹងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវរាល់សេចក្តីសម្រេចចិត្តនោះ។
- **សង្គតិភាព និងសុខដុមនីយកម្ម ៖** ផែនការត្រូវរៀបចំឡើងដោយមានភាពស៊ីសង្វាក់គ្នា មានលំដាប់លំដោយ និងមានលក្ខណៈសមស្របសម្រាប់ភាគីដែលពាក់ព័ន្ធដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ផែនការឃុំ សង្កាត់ត្រូវធ្វើឡើងឲ្យសមស្របទៅតាមគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងផែនការអភិវឌ្ឍន៍ក្រុង ស្រុក។
- **ការចូលរួមពិគ្រោះយោបល់ទូទៅ ៖** នៅក្នុងដំណើរការកសាងផែនការឃុំ សង្កាត់ ការចូលរួមរបស់ប្រជាពលរដ្ឋ ជាកត្តាមួយយ៉ាងសំខាន់សម្រាប់អភិវឌ្ឍន៍គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍន៍ឃុំ សង្កាត់ ស្របតាមផែនការយុទ្ធសាស្ត្រជាតិ។
- **ការឆ្លើយតប និងតម្រូវការ ៖** ការកសាងផែនការឃុំ សង្កាត់ គឺជាការឆ្លើយតបនូវតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដោយមានគោលបំណង គោលដៅជាក់លាក់សម្រាប់ការអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន ដើម្បីជួយសម្រួល ពន្លឿនដល់កិច្ចការងាររដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់ ក៏ដូចជាការទទួលបាននូវសេវាឆាប់រហ័សរបស់ប្រជាពលរដ្ឋ។
- **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ៖** ការកសាងផែនការឃុំ សង្កាត់ ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋដោយមានគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់(គ.ផ.ថ)។
- **ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម ៖** ក្នុងដំណើរការកសាង និងអនុវត្តផែនការត្រូវធានានូវប្រសិទ្ធភាព ដោយមានការចូលរួមពីប្រជាពលរដ្ឋ ដែលជាចំណែកមួយជួយជំរុញនូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ដើម្បីឲ្យធានាឲ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវកំណត់ឲ្យមានតម្រូវការដែលមានអាទិភាពខ្ពស់បំផុត និងត្រូវសម្រេចប្រើប្រាស់ធនធានសម្រាប់

ឆ្លើយតបចំពោះតម្រូវការជាអាទិភាពទាំងនេះ ប្រកបដោយការសន្សំសំចៃខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន។

- **ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន ៖** ក្នុងកិច្ចដំណើរការកសាងផែនការឃុំ សង្កាត់ត្រូវធានាដល់ចីរភាព ធនធានធម្មជាតិ បរិស្ថាន សំដៅធានាបាននូវនិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន ដែលមិនប៉ះពាល់ដល់ផលវិជ្ជមាននៃធនធានទាំងនោះនៅក្នុងឃុំ សង្កាត់ឡើយ។
- **ការធានាសមធម៌ ៖** ក្នុងកិច្ចដំណើរការកសាងផែនការឃុំ សង្កាត់ ត្រូវបានធានាឲ្យមានការចូលរួមប្រកបដោយសមធម៌ ស្មើភាព តម្លាភាព និងផ្តល់ផលប្រយោជន៍គ្រប់ភាគីដែលពាក់ព័ន្ធ ជាពិសេស ស្ត្រី កុមារ ជនក្រីក្រ ជនពិការ ក្រុមជនជាតិភាគតិច និងក្រុមជនងាយរងគ្រោះដែលមាននៅក្នុងដែនសមត្ថកិច្ចឃុំ សង្កាត់។

## ១.៤.២.អត្ថន័យនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

### ក.ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់មានរយៈពេល០៥ ឆ្នាំ ដូចអាណត្តិរបស់ក្រុមប្រឹក្សាដែរ។ ផែនការគឺជាទឡ្ហីករណ៍មួយយ៉ាងសំខាន់សំដៅដល់ការអភិវឌ្ឍន៍ឃុំ សង្កាត់ ជាមធ្យោបាយដោះស្រាយបញ្ហារបស់ឃុំ សង្កាត់ តម្រូវការនានា និងយុទ្ធសាស្ត្រផ្សេងៗសម្រាប់ដោះស្រាយបញ្ហាទាំងនោះប្រកបដោយប្រសិទ្ធភាព សំដៅដល់ការឆ្លើយតបនូវតម្រូវការនានាជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គឺជាការធ្វើឲ្យខ្លឹមសារនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជាគម្រោងសកម្មភាព ឬសេវាកម្មជាក់ស្តែង ដោយមានភ្ជាប់នូវចំណាយមូលនិធិ សំដៅដល់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍន៍សម្រាប់រយៈពេលបីឆ្នាំ។ កម្មវិធីនេះត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

## ១.តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់ ការចូលរួម និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមានដូចជា៖

- ក្រុមប្រឹក្សាឃុំ សង្កាត់ ៖ ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដោយធានាឲ្យមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋជាពិសេស ស្ត្រី កុមារ ជនពិការ ជនជាតិដើមភាគតិច ជនក្រីក្រ ក្រុមងាយរងគ្រោះជាដើម។ ក្រៅពីកិច្ចការងារនេះក្រុមប្រឹក្សាត្រូវពិនិត្យអនុម័ត រាល់ការធ្វើវិសោធនកម្មនានា និងតាមដានត្រួតពិនិត្យ វាយតម្លៃអំពីលទ្ធផលដែលសម្រេចបាននូវផែនការអភិវឌ្ឍន៍ នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- មេឃុំ ចៅសង្កាត់ ៖ មេឃុំ ចៅសង្កាត់គឺជាអ្នកដឹកនាំក្នុងការប្រមូលទិន្នន័យភូមិ ឃុំ សង្កាត់ និងដឹកនាំការងារកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ម៉្យាងវិញទៀតមេឃុំ ចៅសង្កាត់គឺជាអ្នកដាក់នូវសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។
- ក្រៅពីនេះមានគណៈកម្មាធិការមួយចំនួនដែលពាក់ព័ន្ធ និងទទួលបន្ទុកក្នុងការគាំទ្រអនុវត្តនូវកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដូចជា៖ គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់(គ.ផ.ថ) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(គ.ក.ន.ក) ក្រៅពីនេះនៅមានមន្ទីរផែនការរាជធានី ខេត្ត ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត។ ជាងនេះទៅទៀតនៅមានការិយាល័យមួយចំនួនទៀតដូចជា ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ឬការិយាល័យផែនការ និងអភិវឌ្ឍន៍ ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនានានៅថ្នាក់រាជធានីខេត្ត NGO និងមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋផ្ទាល់នៅតាមមូលដ្ឋាន។

សូមបញ្ជាក់ថាកិច្ចដំណើរការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់មាន០៣ជំហានដូចជា៖

១.ជំហានទី១ ៖ ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់ គ.ផ.ថ ត្រូវជួបប្រជុំនៅឃុំ សង្កាត់ ដើម្បីធ្វើការវិភាគទិន្នន័យភូមិ ទិន្នន័យឃុំ សង្កាត់ ឯកសារព័ត៌មានស្ថានភាពឃុំ សង្កាត់ និងទិន្នន័យឬព័ត៌មាន ឬប្រើប្រាស់ឧបករណ៍វិភាគផ្សេងៗក្នុងការកំណត់ អំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយ ដែលកិច្ចប្រជុំនេះអាចវិភាគរាល់បញ្ហានានាដែលកើតមាននៅក្នុងឃុំ សង្កាត់កំពុងជួបប្រទះ។ ទន្ទឹមគ្នានេះផងដែរ តំណាងភូមិដែលជាសមាជិក គ.ផ.ថ ស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយទាំងឡាយនៅក្នុងភូមិរបស់ខ្លួន នៅពេលដែលប្រជុំនៅតាមភូមិជាមួយប្រជាពលរដ្ឋ។ បន្ទាប់កិច្ចប្រជុំនៅតាមភូមិត្រូវបានបញ្ចប់ ដោយសមាជិក គ.ផ.ថ បានកំណត់បញ្ហា បូកសរុបបញ្ហា រួចហើយគេនឹងប្រជុំគ្នានៅឃុំ សង្កាត់បន្តទៀតដើម្បីរកដំណោះស្រាយ និងរកភាពបន្សុីគ្នានូវរាល់បញ្ហានានានៅតាមភូមិទូទាំងឃុំ សង្កាត់។

២.ជំហានទី២ ៖ ការរៀបចំ និងចងក្រងសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាដំណាក់កាលនៃការរៀបចំស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ឃុំ សង្កាត់ ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាព របស់ គ.ផ.ថ ត្រូវរៀបចំអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ឃុំ សង្កាត់ ព្រមទាំងមានសេចក្ដីព្រាងក្របខ័ណ្ឌ ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេល០៥ឆ្នាំ ការពិនិត្យសម្រេច ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តផែនការចងក្រងសេចក្ដីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ ដោយមានកិច្ចប្រជុំពិគ្រោះយោបល់ និងមានការពិនិត្យ និងការផ្ដល់យោបល់។

៣.ជំហានទី៣៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាការអនុម័តផែនការអភិវឌ្ឍន៍ ការពិនិត្យអនុលោមភាព ការដាក់ចេញសេចក្ដីសម្រេច និងការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍។

# សន្និដ្ឋាន

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវជាច្រើនចំណុច រួមមានទាំងនីតិវិធី និងការអនុវត្តជាក់ស្តែង ការងារនៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ក៏ដូចជា មុខងារ និងធនធានផ្សេងៗ ដែលរដ្ឋបាលនៅថ្នាក់ក្រោមជាតិបាននឹងកំពុងអនុវត្ត បានបង្ហាញឲ្យយើងឃើញថាចំពោះការអនុវត្តនូវមុខងារ របស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្នមិនទាន់អាចឆ្លើយតបបានពេញលេញជាមួយនឹងតម្រូវការរបស់គោលនយោបាយដែលរាជរដ្ឋាភិបាលបានដាក់ចេញនៅឡើយទេ។ យើងឃើញថានៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅត្រូវការជំនួយជាច្រើនពីថ្នាក់ជាតិ ដូចជា ធនធាន មិនទាន់មានលទ្ធភាព នឹងស្វ័យភាព ដោយខ្លួនឯងបាននៅឡើយ ដែលគោលបំណងរបស់រាជរដ្ឋាភិបាលបានដាក់ចេញដើម្បីឲ្យថ្នាក់ក្រោមជាតិស្វ័យភាពខាងធនធាន ថវិកា និងហិរញ្ញវត្ថុផ្ទាល់ខ្លួន។ ម៉្យាងវិញទៀតចំពោះការអនុវត្តនូវមុខងារ គឺត្រូវដើរទន្ទឹមគ្នាជាមួយនឹងថវិកា ប្រសិនបើរដ្ឋបាលនៅថ្នាក់ក្រោមជាតិមិនមានថវិកាក្នុងការចំណាយផ្សេងនោះទេ រដ្ឋបាលទាំងនោះមិនអាចមានលទ្ធភាពក្នុងការបំពេញមុខងាររបស់ខ្លួនបានដោយជោគជ័យឡើយ។

ការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ និងថវិកានៅថ្នាក់ក្រោមជាតិដែលមានប្រភពចំណូលទាំង៣ប្រភេទ ដូចជា៖ ចំណូលផ្ទាល់ពីមូលដ្ឋាន ចំណូលពីថ្នាក់ជាតិ និងចំណូលពីប្រភពផ្សេងៗ។ប៉ុន្តែបច្ចុប្បន្នយើងឃើញថានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអាចអនុវត្តនៅនីតិវិធីនៃការប្រមូលចំណូលទាំងនោះបាននៅឡើយ ដែលបច្ចុប្បន្ននេះរដ្ឋបាលនៅថ្នាក់ក្រោមជាតិអាចទទួលបានចំណូលតែពី ថ្នាក់ជាតិ និងចំណូលពីប្រភពផ្សេងៗតែប៉ុណ្ណោះ ដោយឡែកប្រភពចំណូលសំខាន់ដែលជាចំណូលផ្ទាល់ខ្លួននោះពុំទាន់មានលទ្ធភាព និងសមត្ថភាពអាចអនុវត្តបាននៅឡើយ ព្រោះការប្រមូលធនធាននោះត្រូវបានចែកដោយ លិខិតបទដ្ឋានគតិយុត្តមួយដោយឡែក ប៉ុន្តែបច្ចុប្បន្នមិនទាន់ឃើញមានវិធានណាមួយបានកំណត់ អំពីការគ្រប់គ្រងធនធានផ្ទាល់ខ្លួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

ដូច្នោះហើយប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ របស់ប្រទេសកម្ពុជាយើងសព្វថ្ងៃនៅមិនទាន់អាចក្លាយជារដ្ឋបាលមូលដ្ឋានបាននៅឡើយទេ គឺវាជាប្រភេទនៃការគ្រប់គ្រងរដ្ឋបាលមួយប្រភេទក្នុងដំណាក់កាលនៃការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ និងវិសហមជ្ឈការតែប៉ុណ្ណោះនាពេលបច្ចុប្បន្ន។

## អនុសាសន៍

ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវនេះយើងខ្ញុំមាននូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

១. គួរពង្រីកទំហំ នៃការផ្សព្វផ្សាយ បណ្តុះបណ្តាល សមត្ថភាពរបស់មន្ត្រីរាជការ បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យបានទូលំទូលាយ។

២. រដ្ឋបាលថ្នាក់ជាតិគួរចាត់មន្ត្រីជំនាញ ទៅជួយដល់ដំណើរការគាំទ្រ នៃនីតិវិធីការប្រគល់ ឬការធ្វើប្រតិភូកម្មមុខងារ និងធនធានជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៣. នៅថ្ងៃអនាគតរដ្ឋបាលគ្រប់លំដាប់ថ្នាក់ទាំងអស់គួរតែគ្រប់គ្រងទិន្នន័យ មន្ត្រីរាជការតាមរយៈប្រព័ន្ធអេឡិចត្រូនិច។

៤. រដ្ឋបាលនៅថ្នាក់ក្រោមជាតិត្រូវមានលទ្ធភាពក្នុងការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ និងថវិកាផ្ទាល់ខ្លួន។

៥. ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវចូលរួមពិគ្រោះយោបល់ និងគួរចេញសេចក្តីប្រកាស សេចក្តីសម្រេចនានា ដែលពាក់ព័ន្ធនិងការងារ អភិវឌ្ឍន៍សមត្ថភាព ក៏ដូចជាការអភិវឌ្ឍក្នុងវិស័យសេដ្ឋកិច្ច ធ្វើយ៉ាងណាឲ្យឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

# ឯកសារពិគ្រោះ

<u>ឯកសារជាភាសាខ្មែរ ៖</u>

១.រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣

២.ព្រះរាជក្រម នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៣.អនុក្រឹត្យ លេខ១៩១ អនក្រ.បក ស្តីពី ការប្រគល់មុខងារពាក់ព័ន្ធនានានឹងការគ្រប់គ្រង ការអប់រំកុមារតូច ការអប់បឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឲ្យទៅដល់រដ្ឋបាល ក្រុង ស្រុក

៤.អនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក។

៥.អនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពី ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

៦.អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក

៧.អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពី ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ

៨.អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១២ ស្តីពី ដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

៩.អនុក្រឹត្យលេខ ៤៩៧ អនក្រ.បក ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការ ធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

១០.អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

១១.អនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

១២.អនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

១៣.ប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១០ ស្តីពី ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

១៤.ប្រកាសលេខ ២៨០៩ ប្រក ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៣ ស្តីពី ការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្នុងការផ្ទៀងផ្ទាត់លក្ខខ័ណ្ឌនានានៃសំណើសុំផ្ទេរមូលនិធិក្រុងស្រុក

១៥.ប្រកាសណែនាំ ស្តីពី ការរៀបចំ ការអនុម័ត និងអនុវត្តថវិកាក្រុង ស្រុក

១៦.ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

១៧.ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

១៨.សេចក្តីណែនាំ លេខ០០៤ ស.ណ.ន ស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង ជំនួយការភូមិ និងតួនាទី ភារកច្ចិ របៀបរបបការងាររបស់ភូមិ

១៩.ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ បោះពុម្ពផ្សាយនាខែកក្កដា ឆ្នាំ២០១៧

២០.ព្រឹត្តិបត្រ ស្តីពី វិមជ្ឈការ និងវិសហមជ្ឈការ ចេញផ្សាយដោយ ន.ប.ប ក្រសួងមហាផ្ទៃ ឆ្នាំទី១ លេខ១ ខែធ្នូ ឆ្នាំ២០១៦

២១.បឋកថា ស្តីពី កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ សម្តេចក្រឡាហោម **ស ខេង**

២២.ប្រវត្តិនៃអភិបាលកិច្ចមូលដ្ឋាន វិមជ្ឈការ និងវិសហមជ្ឈការ និងក្របខ័ណ្ឌច្បាប់សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ដោយឯកឧត្តម **សក់ សេដ្ឋា**

២៣.ឯកសារដែលពាក់ព័ន្ធនឹងប្រធានបទផ្សេងៗទៀត។

**<u>វែបសាយ៖</u>**

១.www.ncdd.gov.kh

# សន្ទានុក្រម

LEXICON

## ក.ខ.គ.ឃ.ច

- **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម**(Medium Term Expenditure Framework) : ការធ្វើផែនការចំណាយសាធារណៈដែលមានរយៈពេលពីបី(០៣) ដល់ប្រាំ(០៥)ឆ្នាំ ដែលកំណត់តម្រូវការធនធាននាពេលអនាគត សម្រាប់សេវាកម្ម និងអភិវឌ្ឍដែលស្ថិតក្នុងបរិបទនៃការប៉ាន់ស្មានធនធានសរុបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីក្នុងប្រភពមូលដ្ឋាន និងពីប្រភពខាងក្រៅ។
- **កាតព្វកិច្ច ៖** គឺជាតួនាទី ភារកិច្ចរបស់មន្ត្រីរាជការស៊ីវិល បុគ្គលិក ដែលត្រូវតែគោរព និងអនុវត្តតាមបទបញ្ញត្តិនានា និងត្រូវតែធ្វើការផ្តល់សេវាដល់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។
- **ការកសាងសមត្ថភាព(Capacity Building) ៖** គឺជាការអភិវឌ្ឍចំណេះដឹង ជំនាញ សមត្ថភាពរបស់បុគ្គលិក ឬស្ថាប័ន ដើម្បីបំពេញកិច្ចការឲ្យមានប្រសិទ្ធភាព។ ការកសាងសមត្ថភាពអាចធ្វើឡើងតាមរយៈការអប់រំ វគ្គបណ្តុះបណ្តាល(Training Courses)ជាផ្លូវការ ឬតាមរយៈការរៀនបណ្តើរធ្វើបណ្តើរ(On-job-training)។
- **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(Democratic Development)៖** គឺជាការអភិវឌ្ឍដែលមានដំណើរការ០៨ចំណុចដូចខាងក្រោមៈ

  ១. **ភាពជាតំណាងសាធារណៈ**(Public Representation) : ក្រុមប្រឹក្សាអនុវត្តការងារក្នុងនាម និងធ្វើជាតំណាងឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

  ២. **ស្វ័យភាពរបស់មូលដ្ឋាន**(Local Autonomy) : ស្ថានភាពដែលក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែង គ្រប់គ្រងនូវកិច្ចការដែលបានប្រគល់ ឬធ្វើប្រតិភូកម្មឲ្យ ដោយច្បាប់ប្រកបដោយប្រសិទ្ធភាព។

  ៣. **ការពិគ្រោះយោបល់ និងការចូលរួម**(Consultation and Participation) : ជាដំណើរការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដែលក្រុមប្រឹក្សាត្រូវ៖ **ជួប** និងពិគ្រោះយោបល់ផ្សេងៗជាមួយប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងធ្វើ**ការលើកទឹកចិត្ត** និងការសម្របសម្រួលឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន

នៅគ្រប់ផ្នែកទាំងអស់ នៃអភិបាលកិច្ច ដើម្បីស្វែងយល់ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។

៤. **ការឆ្លើយតប និងគណនេយ្យភាព**(Responsiveness and Accountability): ក្នុងនាមជាតំណាងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ក្រុមប្រឹក្សាត្រូវឆ្លើយតបជាមួយប្រជាពលរដ្ឋនៅក្នុងការអនុវត្តនៅគោលនយោបាយនានារបស់ខ្លួន ក៏ដូចជាត្រូវទទួលខុសត្រូវជាមួយរាជរដ្ឋាភិបាល ក្នុងការអនុវត្តការងាររបស់ខ្លួន ដែលការអនុវត្តនោះមិនផ្ទុយពីរដ្ឋធម្មនុញ្ញ ឬច្បាប់នានា។

៥. **ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន**(Promotion of Life Quality of the Local Residents) : សំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បី : បង្កើត និងធ្វើឲ្យមាននិរន្តរភាព នូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខមាលភាព។ លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និង ការលើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

៦. **ការលើកស្ទួយសមធម៌**(Promotion of Equity) : ការគិតគូរ និងយកចិត្តទុកដាក់ពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន កុមារ និងជនងាយរងគ្រោះ ដោយរាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច។

៧. **តម្លាភាព និងសុចរិតភាព**(Transparency and Integrity) : គឺជាការចាត់ចែង និងការគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុចរិតភាព និងច្បាប់ ក្នុងលក្ខណៈបើកចំហ តម្លាភាព ការចូលរួម និងការឆ្លើយតប។

៨. **វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច**(Measures to Fight Corruption and Abuse of Power) : គឺជាប្រកាន់យកនូវវិធានច្បាប់ ព្រមទាំងការប្រឆាំង និងរាយការណ៍អំពើពុករលួយ និងការរំលោភអំណាច។

- **ការប្រគល់មុខងារ**(Assignment of Function) : គឺជាការប្រគល់ភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ ដើម្បីគ្រប់គ្រង និងអនុវត្តចាត់ចែងមុខងារនោះក្នុងនាមជាម្ចាស់។
- **ការធ្វើប្រតិភូកម្មមុខងារ**(Functional of Delegates) : គឺជាការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម

ដោយផ្អែកតាមតម្រូវការ នៃប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ។

- **ក្រុមប្រឹក្សា**(council) : ត្រូវបានបង្កើតឡើង ដោយការបោះឆ្នោតជាអសកល ដោយត្រូវបានបោះឆ្នោតជ្រើសរើស ដោយមានអាណត្តិ០៥ ឆ្នាំ ក្រុមប្រឹក្សាទាំងអស់ គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **ក្រុង**(Municipality) : គឺជារដ្ឋបាលក្រុង ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង។
- **ខេត្ត**(Province) : គឺជារដ្ឋបាលខេត្ត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។
- **ខណ្ឌ**(Khan) : គឺជារដ្ឋបាលខណ្ឌ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ។
- **គណនេយ្យភាព**(Accountability) : សំដៅដល់ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា ចំពោះប្រជាពលរដ្ឋនៅបញ្ហាណាមួយ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៅតាមមូលដ្ឋាន។
- **គុណភាពល្អ**(Good Quality) : សេវាដែលមន្ត្រីរាជការ បុគ្គលិកផ្តល់ជូនប្រជាពលរដ្ឋត្រូវបានសម្រេច ទៅតាមពេលវេលាដែលបានកំណត់។
- **ឃុំ**(Commune) : គឺជារដ្ឋបាលឃុំ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ។
- **ចៅហ្វាយខេត្ត**(Provincial governor) : ពាក្យថា ចៅហ្វាយខេត្ត ត្រូវបានគេយកមកប្រើប្រាស់ក្រោយពីក្រឹត្យច្បាប់ឆ្នាំ១៩០៨ ស្តីពី ការគ្រប់រដ្ឋបាលឃុំ ដែលបានចូលជាធរមាននៅថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ១០៩៨ ដោយប្តូរពីពាក្យថា ចៅហ្វាយស្រុក មកជាចៅហ្វាយខេត្ត ហើយបច្ចុប្បន្នពាក្យនេះត្រូវបានគេប្រើជំនួសដោយពាក្យថា **អភិបាល** វិញ។
- **ចៅហ្វាយស្រុក**(District governor) : ពាក្យថា ចៅហ្វាយស្រុក ត្រូវបានប្រើប្រាស់នៅមុនឆ្នាំ ១៩០៨ ដែលពាក្យមានន័យស្មើនឹងពាក្យថា ចៅហ្វាយខេត្ត នាឆ្នាំ១៩០៨។

**ជ.ឆ.ឍ.ន**

- **ដែនសមត្ថកិច្ច**(Jurisdiction) : គឺជាតំបន់ ជាមុខងារ និងជាភារកិច្ច ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា។
- **ដីការ**(By-Law) : គឺជាវិធានច្បាប់ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សា ក្នុងព្រំដែននៃសមត្ថកិច្ចរបស់ខ្លួន ដើម្បីអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **ទ្រព្យសម្បត្តិ**(Asset) : ក្នុងន័យទូទៅគឺសំដៅលើ សម្ភារបរិក្ខា គ្រឿងអេឡិចត្រូនិចការិយាល័យ លិខិតស្នាម ឯកសារ និងដីកាសាធារណៈ អចលទ្រព្យសាធារណៈ សំណង់សា

ធារណៈ ឬហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ស្ពាន អាគារ ផ្លូវ ឬវត្ថុប្រហាក់ប្រហែលគ្នានេះ។ ដែលទ្រព្យសម្បត្តិទាំងនោះអាចជាទ្រព្យសកម្ម និងទ្រព្យអកម្ម។

១. **ទ្រព្យសកម្ម**(Asset) : គឺជាការកត់ត្រាក្នុងផ្នែកគណនេយ្យ សំដៅទៅលើទ្រព្យសម្បត្តិនានា ជាកម្មសិទ្ធិរបស់ក្រុមប្រឹក្សាដែលមានតម្លៃរួមពិតប្រាកដ រួមទាំងប្រាក់កាសផងដែរ។

២. **ទ្រព្យអកម្ម**(Liability) : គឺជាការកត់ត្រាក្នុងផ្នែកគណនេយ្យ ដែលសំដៅលើកាតព្វកិច្ចទូទាត់ ដែលត្រូវបានកត់ត្រា។ ការទូទាត់នោះមិនទាន់បានធ្វើនៅឡើយ។

- **ធនធាន**(Resources) : រួមមានទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ ចំណូល បុគ្គលិក និងសមត្ថភាព។
- **នីតិបុគ្គល**(Legal Entity) : សំដៅដល់អង្គភាព ស្ថាប័នដែលមានមូលដ្ឋានគតិយុត្តគាំពារ។

**ប.ផ.ម.រ**

- **ប្រសិទ្ធភាព**(Effective) : គឺជាការធ្វើកិច្ចការអ្វីៗ ដែលបានសម្រេចដូចបំណង ដែលសម្រេចបានជាលទ្ធផលល្អស្របតាមច្បាប់ និងគោលការណ៍ដែលបានដាក់ចេញ។
- **ប្រសិទ្ធផល**(Efficient) : គឺជាលទ្ធផល ដែលទទួលពីប្រសិទ្ធិភាព ប្រកបដោយគុណភាពខ្ពស់។
- **ផលប្រយោជន៍** (Interest) : គឺជាផលដែលទទួលបានដោយគុណប្រយោជន៍ សម្រាប់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលការទទួលបាននោះអាចជាការបណ្តុះបណ្តាល ការងារវិជ្ជាជីវៈ។
- **មុខងារ**(Function) :
- **មជ្ឈការ**(Centralization) : ជារបៀបគ្រប់គ្រងបែបប្រមូលផ្តុំ។ ប្រព័ន្ធនេះគឺសំដៅទៅលើការពង្រឹងអំណាចរបស់រដ្ឋបាលកណ្តាលឲ្យខ្លាំង និងឯកភាពជាតិ។
- **រដ្ឋបាលថ្នាក់ក្រោមជាតិ**(Sub National Administration) : គឺសំដៅដល់ការគ្រប់គ្រងដែនដីដែលរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាខ្សែបណ្តោយរបស់ក្រសួងមហាផ្ទៃ ដែលចាប់ពីថ្នាក់រាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ និងសង្កាត់ គឺជារដ្ឋបាលថ្នាក់ក្រោមជាតិ។
- **រដ្ឋបាលឯកភាព**(Unified Administration) : គឺសំដៅដល់ការគ្រប់គ្រងរដ្ឋបាលមួយប្រភេទដែលមានស្វ័យភាពក្នុងការសម្រេចចិត្ត ដោយមានភាពម្ចាស់ការ សម្រុះសម្រួល និងមានគណនេយ្យភាពធានាឲ្យខ្សែបណ្តោយរបស់ក្រសួងស្ថាប័នមានប្រសិទ្ធិភាព និងនិរន្តភាព។
- **រដ្ឋបាលមូលដ្ឋាន**(Local Administration) : គឺសំដៅទៅលើប្រភេទរដ្ឋបាលដែលមានការគ្រប់គ្រងបែបទំនើប ដោយជាប្រព័ន្ធគ្រប់គ្រងមួយដែលស្ថិតនៅជិតប្រជាពលរដ្ឋជាងគេ។
- **រាជធានី**(Capital) : គឺជារដ្ឋបាលរាជធានី ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី។

# ឧ.ស.ហ.អ

- **វិមជ្ឈការ**(Decentralization) : គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់ លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាណាមួយ។
- **វិសហមជ្ឈការ**(De-concentration) : គឺជាការដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅប្រភេទក្រុមប្រឹក្សាណាមួយ ដើម្បីអនុវត្តក្នុងនាមជារាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។
- **សាប់ស៊ីឌីយ៉ារិធី**(Subsidiarity) : គឺជាគោលការណ៍នៃផ្ទេរមុខងារណាទៅឲ្យថ្នាក់ទាបបំផុតណាដែលមានសមត្ថភាពអាចបំពេញបាន។
- **សេដ្ឋកិច្ចវិមាត្រ** (Economy of Scale) : សំដៅទៅលើការផ្ទេរមុខងារ ការទទួលខុសត្រូវ និងសិទ្ធិអំណាច ទៅឱ្យរដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចអនុវត្តមុខងារនោះប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ។
- **អព្យាក្រឹត្យ**(Neutral) : ជាការអនុវត្តទៅតាមច្បាប់ ឈរលើទស្សនៈមិនលំអៀង ភាពជាកណ្តាល ជាគោលការណ៍កណ្តាល។
- **ស្រុក**(District) : ជារដ្ឋបាលស្រុក ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាស្រុក។

# តារាងឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ ព្រះរាជក្រម ស្តីពី ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិនៅថ្នាក់ក្រោមជាតិ
- ឧបសម្ព័ន្ធទី២ អនុក្រឹត្យ ស្តីពី ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- ឧបសម្ព័ន្ធទី៣ អនុក្រឹត្យ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- ឧបសម្ព័ន្ធទី៤ អនុក្រឹត្យ ស្តីពី ដំណើរការនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ឧបសម្ព័ន្ធទី៥ អនុក្រឹត្យ ស្តីពី ការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ
- ឧបសម្ព័ន្ធទី៦ អនុក្រឹត្យ ស្តីពី ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ឧបសម្ព័ន្ធទី៧ អនុក្រឹត្យ ស្តីពី ការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក
- ឧបសម្ព័ន្ធទី៨ ប្រកាសអន្តរក្រសួង ស្តីពី ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ឧបសម្ព័ន្ធទី៩ យុទ្ធសាស្ត្រចតុកោណ
- ឧបសម្ព័ន្ធទី១០ អំពីក្រុមប្រឹក្សា ខេត្ត ស្រុក
- ឧបសម្ព័ន្ធទី១១ រចនាសម្ព័ន្ធរដ្ឋបាលខេត្ត
- ឧបសម្ព័ន្ធទី១២ ក្រុមប្រឹក្សាក្រុង
- ឧបសម្ព័ន្ធទី១៣ ក្រុមប្រឹក្សាឃុំ សង្កាត់
- ឧបសម្ព័ន្ធទី១៤ តារាងស្តីពីមូលនិធិថវិកាឃុំ សង្កាត់ឆ្នាំ២០១៧
- ឧបសម្ព័ន្ធទី១៥ នីតិវិធីនៃការជ្រើសរើសមេភូមិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៧៦.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភាឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក ដែលបាន បង្កើតឡើងដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ក្របខ័ណ្ឌគតិយុត្ត សម្រាប់ផ្តល់ធនធានហិរញ្ញវត្ថុមួយចំណែក ប្រកបដោយសមធម៌ ចីរភាព និងអាចព្យាករណ៍បានដល់រដ្ឋបាលក្រុង ស្រុក ដើម្បីជួយទ្រទ្រង់និងអភិវឌ្ឍ មូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងមូលនិធិក្រុង ស្រុក ក្នុងការផ្តល់មូលនិធិផ្ទេរ គ្មានភ្ជាប់លក្ខខ័ណ្ឌពីថវិកាជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់រួមចំណែកក្នុងការអនុវត្តចំណាយបម្រើឱ្យ សកម្មភាពទាំងឡាយដូចតទៅ ៖

- ការបំពេញភារកិច្ចតាមផ្លូវច្បាប់
- ការបំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា ។

## ជំពូកទី២

## ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិក្រុង ស្រុក

**មាត្រា ៤.-**

ប្រភពធនធាននៃមូលនិធិក្រុង ស្រុករួមមាន ៖

- ការចូលរួមចំណែកពីចំណូលចរន្តនៃថវិការដ្ឋ
- ការរួមចំណែកពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ក្រោមក្របខ័ណ្ឌហិរញ្ញប្បទាន សហប្រតិបត្តិការ និង
- ការចូលរួមធនធានពីប្រភពផ្សេងៗទៀតដែលកំណត់ដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ។

**មាត្រា ៥.-**

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុកត្រូវកំណត់សម្រាប់ថេរៈវេលាចំនួនបីឆ្នាំ

លើមូលដ្ឋានក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃថវិកាទូទៅរបស់រដ្ឋ។

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុក សម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ មានដូចខាងក្រោម៖

- សម្រាប់ឆ្នាំថវិកា២០១២មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័ត ឆ្នាំ២០១១
- សម្រាប់ឆ្នាំថវិកា២០១៣ មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលនឹងត្រូវអនុម័ត នៅឆ្នាំ២០១២ និង
- សម្រាប់ឆ្នាំថវិកា២០១៤ មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលនឹងត្រូវអនុម័ត នៅឆ្នាំ២០១៣។

**មាត្រា ៦.-**

ក្នុងករណីមានការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ ឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ឬសប្បុរសជននានាតាមរយៈប្រព័ន្ធថវិការដ្ឋដើម្បីជួយទ្រទ្រង់ការអភិវឌ្ឍមូលដ្ឋានក្រុង ស្រុក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចាត់នីតិវិធីបង់ចំណូលថវិការដ្ឋតាមរយៈរតនាគារជាតិគ្រង់តែម្តង។ ព្រមជាមួយនេះ ឥណទានបន្ថែមដែលមានទឹកប្រាក់ដូចគ្នាទៅនឹងចំណូលដែលបានបង់ចូលថវិការដ្ឋនេះ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវបានផ្ទេរចូលគណនីដោយឡែកនៃមូលនិធិក្រុង ស្រុក តាមរយៈអាណត្តិឧបត្ថម្ភកធនស្របតាមគោលដៅរបស់ភាគី ឬដៃគូអភិវឌ្ឍន៍។

**មាត្រា ៧.-**

ធនធាននៃមូលនិធិក្រុង ស្រុកត្រូវបានចាត់ចែង និងគ្រប់គ្រងតាមរយៈគណនីដោយឡែកមួយនៅរតនាគារជាតិ។ គណនីនេះត្រូវឆ្លុះបញ្ចាំងនូវរាល់ប្រតិបត្តិការចំណូលដែលបានមកពីគ្រប់ប្រភពធនធានទាំងអស់នៃមូលនិធិក្រុង ស្រុក ដូចបានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ និងប្រតិបត្តិការចំណាយដែលបានផ្ទេរពីមូលនិធិក្រុង ស្រុកប្រចាំឆ្នាំសម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលក្រុង ស្រុកនីមួយៗដូចបានកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ។

សមតុល្យចុងឆ្នាំនៃគណនីមូលនិធិក្រុង ស្រុកត្រូវបានយោងទៅដើមឆ្នាំបន្ទាប់។

**មាត្រា ៨.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគ្រប់គ្រងមូលនិធិក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំវិភាជន៍ធនធានមូលនិធិក្រុង ស្រុកជូនដល់រដ្ឋបាលក្រុង ស្រុកនីមួយៗដូចដែលបានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ
- ជូនដំណឹងដល់រដ្ឋបាលក្រុង ស្រុកអំពីចំនួនធនធានមូលនិធិក្រុង ស្រុកដែលត្រូវទទួលបានពីការវិភាជន៍ប្រចាំឆ្នាំមុនពេលរៀបចំថវិកា និងធនធានមូលនិធិដែលរដ្ឋបាលក្រុង ស្រុកត្រូវទទួលបានពីការវិភាជន៍សម្រាប់រយៈពេលមធ្យម និង

- រៀបចំរបាយការណ៍នៃការអនុវត្តមូលនិធិក្រុង ស្រុក ប្រចាំខែ ប្រចាំត្រីមាសនីមួយៗ និងប្រចាំឆ្នាំ នៃការអនុវត្តមូលនិធិក្រុង ស្រុក ជូនរាជរដ្ឋាភិបាលតាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**មាត្រា ៩.-**

ក្រោយពីបានសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវ ៖

- ពិនិត្យ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីការផ្លាស់ប្តូរនានា ដែលត្រូវកែសម្រួលពាក់ពន្ធ័នឹងគោលបំណង វិធាន និងគោលការណ៍ផ្សេងៗនៃមូលនិធិក្រុង ស្រុក
- ផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីកម្រិតជាភាគរយនៃចំណែកចូលរួមពីថវិការដ្ឋទៅក្នុងធនធានមូលនិធិក្រុង ស្រុក
- កំណត់គោលដៅនានាដើម្បីកៀរគរធនធានពីខាងក្រៅចូលក្នុងធនធានមូលនិធិក្រុង ស្រុក
- កំណត់រូបមន្ត លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រជាក់លាក់ ដើម្បីបែងចែកធនធាននៃមូលនិធិក្រុង ស្រុក
- អនុញ្ញាតឱ្យមានការវាយតម្លៃឯករាជ្យលើការអនុវត្តមូលនិធិក្រុង ស្រុក ដោយអាជ្ញាធរសវនកម្មមានសមត្ថកិច្ច
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីដំណើរការមូលនិធិក្រុង ស្រុករៀងរាល់៦ខែ
- ធ្វើកិច្ចអន្តរាគមន៍លើការផ្ទេរធនធានមូលនិធិក្រុង ស្រុកក្នុងករណីចាំបាច់ ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងតំណាងក្រុមប្រឹក្សាក្រុង ស្រុកត្រូវពិភាក្សាពិគ្រោះយោបល់នូវរាល់បញ្ហាពាក់ព័ន្ធនឹងគោលនយោបាយ និងប្រតិបត្តិផ្សេងៗលើការអនុវត្តមូលនិធិក្រុង ស្រុក ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីកំណត់នីតិវិធីនិងបែបបទលើការជ្រើសរើសតំណាងក្រុមប្រឹក្សាក្រុង ស្រុក និងចូលរួមពិភាក្សាពិគ្រោះយោបល់ក្នុងការរៀបចំគោលនយោបាយដែលពាក់ព័ន្ធដល់ការអនុវត្តមូលនិធិក្រុង ស្រុក ។

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវមានតួនាទីជាអ្នកទទួលខុសត្រូវផ្ទាល់ ក្នុងការជួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវ ៖

- តាមដានការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកលើការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក
- រាយការណ៍ជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លើការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុកដោយរដ្ឋបាលក្រុង ស្រុក
- ស្នើកិច្ចអន្តរាគមន៍ពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការផ្ទេរធនធានមូលនិធិក្រុង ស្រុកទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងករណីចាំបាច់។

## ជំពូកទី៣
## ការបែងចែក ការផ្ទេរ និងការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក

**មាត្រា ១១.-**

ធនធានដែលបែងចែកប្រចាំឆ្នាំទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវផ្អែកតាមរូបមន្តសមស្របដើម្បីធានាសមធម៌ និងប្រកបដោយតម្លាភាព។ លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រដែលប្រើក្នុងរូបមន្តដើម្បីបែងចែកធនធាន ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយជាសាធារណៈ។ ធនធានមូលនិធិដែលបានបែងចែកទៅឱ្យរដ្ឋបាលក្រុង ស្រុក គឺជាចំណែកមួយនៃគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រខាងលើនេះ ត្រូវបានកំណត់សម្រាប់រយៈពេលយ៉ាងតិចបីឆ្នាំ។ ការកែសម្រួលលក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រត្រូវតែធ្វើឡើងដោយផ្អែកតាមលក្ខណៈបច្ចេកទេសសមស្រប ឬក្រោមហេតុផលនៃយុត្តិកម្មគោលនយោបាយ ដើម្បីធានាបាននូវសមធម៌នៃការបែងចែកធនធានដល់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

**មាត្រា ១២.-**

ធនធានមូលនិធិក្រុង ស្រុក ត្រូវចែកចេញជាពីរសមាសភាគដូចខាងក្រោម ៖

- សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និង
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

ទំហំធនធាននៃសមាសភាគនីមួយៗនៃមូលនិធិក្រុង ស្រុកត្រូវកំណត់ដូចខាងក្រោម ៖

ក). ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ ត្រូវបានកំណត់ដោយផ្អែកលើឯកតា រង្វាស់ និងនិយាមដូចខាងក្រោម ៖

- ចំនួនសរុបនៃសមាជិកក្រុមប្រឹក្សាក្រុងស្រុក និងប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក
- ចំនួនសរុបនៃអភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក និងប្រាក់បៀវត្សសម្រាប់ប្រភេទនីមួយៗ និង

- គម្រោងចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗទៀត មិនឱ្យលើសពី២៤ភាគរយនៃធនធានមូលនិធិសរុប *ដក* ចំនួនសរុបប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់បៀវត្សរបស់អភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។

ខ). ទំហំធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងធនធានវិភាជន៍សរុប *ដក* ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ។

**មាត្រា ១៣.-**

ធនធាននៃសមាសភាគទាំងពីរនៃមូលនិធិក្រុង ស្រុក ត្រូវបានបែងចែកទៅរដ្ឋបាលក្រុង ស្រុកនីមួយៗស្របតាមវិធានដូចខាងក្រោម ៖

១. ធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅត្រូវបានវិភាជន៍ទៅរដ្ឋបាលក្រុង ស្រុកនីមួយៗដោយអនុលោមតាមនិយាមដូចខាងក្រោម ៖

ក). ចំណាយប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាក្រុង ស្រុក

ខ). ចំណាយប្រាក់បៀវត្សរបស់អភិបាល អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក

គ). ចំណាយប្រាក់បៀវត្សរបស់បុគ្គលិករដ្ឋបាលក្រុង ស្រុក ផ្អែកតាមចំនួនបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដែលកំណត់ដោយក្រសួងមហាផ្ទៃ

ឃ). ធនធានសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗត្រូវបែងចែកទៅរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖

- ចំណែកស្មើគ្នាមានចំនួន៤០ភាគរយ ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ
- សមាជិកក្រុមប្រឹក្សាមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- គណៈអភិបាលមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាសភាពគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- មន្ត្រីបុគ្គលិកមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនមន្ត្រីបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ។

២. ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានត្រូវបានវិភាជន៍ទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗតាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖

ក). ចំណែកស្មើគ្នាជាមូលដ្ឋានមានចំនួន៤០ភាគរយ ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ

ខ). ប្រជាពលរដ្ឋមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាជន

នៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ

គ). សន្ទស្សន៍ភាពក្រីក្រមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ និង

ឃ). ឃុំ សង្កាត់មានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុកនីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងមហាផ្ទៃ។

លក្ខណៈវិនិច្ឆ័យ និងចំនួនភាគរយនៃសន្ទស្សន៍នីមួយៗសម្រាប់ធ្វើការបែងចែកធនធានឱ្យសមាសភាគអភិវឌ្ឍន៍មូលដ្ឋានអាចត្រូវបានពិនិត្យ និងកែលម្អឡើងវិញនាពេលមួយសមស្របដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ។

**មាត្រា ១៤.-**

រដ្ឋបាលក្រុង ស្រុកអាចប្រើប្រាស់ធនធានដែលផ្ទេរពីមូលនិធិក្រុង ស្រុកដើម្បីផ្តល់ហិរញ្ញប្បទានដល់ចំណាយ ចំណែកណាមួយដូចខាងក្រោមនេះបាន លុះត្រាតែចំណាយទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិកាក្រុង ស្រុកដែលបានអនុម័ត និងមិនផ្ទុយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងច្បាប់និងលិខិតបទដ្ឋាននានាដទៃទៀតដែលមានជាធរមាន។

១. ការប្រើប្រាស់ធនធានមូលនិធិនៃសមាភាគរដ្ឋបាលទូទៅ ៖

ក). ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងកិច្ចប្រតិបត្តិការរដ្ឋបាលក្រុង ស្រុក

ខ). ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងកិច្ចអភិវឌ្ឍន៍ ឬលទ្ធកម្មលើអចលនទ្រព្យ ដូចជាអគារ បរិក្ខារការិយាល័យ គ្រឿងសង្ហារិម មធ្យោបាយដឹកជញ្ជូនសម្រាប់ប្រើប្រាស់ក្នុងបុព្វហេតុរដ្ឋបាល។

២. ការប្រើប្រាស់ធនធានមូលនិធិនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ៖

ក). ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាមូលដ្ឋាន កិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននិងបរិក្ខារផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់សេវាទាំងនោះ។

ខ). ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងការវិនិយោគក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន។

**មាត្រា ១៥.-**

ផ្អែកលើមូលនិធិដែលត្រូវផ្ទេរប្រចាំឆ្នាំទៅឱ្យរដ្ឋបាលក្រុង ស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបោះផ្សាយអាណត្តិផ្ទេរពីគណនីថវិការដ្ឋ ទៅគណនីដោយឡែករបស់មូលនិធិក្រុង ស្រុកនៅរតនាគារជាតិតាមការកំណត់ដូចខាងក្រោម ៖

- ៥០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែឧសភា
- ៨០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែសីហា

• ១០០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែតុលា ។

ការផ្ទេរធនធានមូលនិធិក្រុង ស្រុកជូនទៅរដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវធ្វើឡើងជាបួនដំណាក់កាល ដោយកំណត់ប្រចាំត្រីមាសនីមួយៗ។ នៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបញ្ជាផ្ទេរចំណាយ ចំនួនមួយភាគបួន(១/៤)នៃមូលនិធិប្រចាំឆ្នាំរបស់ក្រុងស្រុកនីមួយៗដោយស្វ័យប្រវត្តិ ។ ដោយឡែកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ រដ្ឋបាលក្រុង ស្រុកត្រូវធ្វើសំណើសុំផ្ទេរមូលនិធិមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ នៅដើមខែទីបីនៃត្រីមាសមុន ដើម្បីធ្វើការផ្ទៀងផ្ទាត់ល័ក្ខខ័ណ្ឌនានានៃការផ្ទេរធនធានមូលនិធិក្រុង ស្រុកដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណូល ចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងរបាយការណ៍ប៉ាន់ស្មានអនុវត្តចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់ដោយមានឯកសារគាំទ្រជាមូលដ្ឋាន ។

នីតិវិធីក្នុងការផ្ទៀងផ្ទាត់នៃការបំពេញល័ក្ខខ័ណ្ឌសម្រាប់ការផ្ទេរទម្រង់របាយការណ៍ចំណូល ចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងទម្រង់របាយការណ៍ប៉ាន់ស្មានអនុវត្តចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់ និងឯកសារគាំទ្រជាមូលដ្ឋានខាងលើនេះត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.-**

នៅក្នុងឆ្នាំ២០១២ ក្នុងករណីដែលរដ្ឋបាលក្រុង ស្រុកពុំទាន់មានថវិកាផ្ទាល់របស់ខ្លួន ការផ្ទេរមូលនិធិទៅឱ្យក្រុង ស្រុកនីមួយៗត្រូវបានកត់ត្រានៅក្នុងគម្រោងថវិការបស់ខេត្តសាមីដោយលម្អិតទៅតាមក្រុង ស្រុកនីមួយៗ និងត្រូវបានអភិបាលនៃគណៈអភិបាលខេត្តធ្វើប្រតិភូកម្មជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុកនីមួយៗ ជាអាណាប័កផ្ទេរសិទ្ធិទាំងចំណូល ទាំងចំណាយនៅពេលដំណើរការអនុវត្តថវិកាដែលមានគណនីប្រាក់បញ្ញើថវិកាដោយឡែកពីគណនីប្រាក់បញ្ញើថវិការបស់ខេត្តសាមី ។

នៅក្នុងឆ្នាំ២០១២ ប្រសិនបើមានការចូលរួមធនធានពីដៃគូអភិវឌ្ឍន៍ទៅក្នុងមូលនិធិក្រុង ស្រុកធនធាននោះនឹងត្រូវបានវិភាជន៍ និងផ្ទេរជូនក្រុង ស្រុកត្រង់ចូលទៅគណនីប្រាក់បញ្ញើថវិការបស់រដ្ឋបាលក្រុង ស្រុកដើម្បីអនុវត្តដោយផ្ទាល់តែម្តង ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក និងអភិបាលក្រុង ស្រុកទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ[illegible] ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធានានូវការផ្ទេរមុខងារនិងធនធាននានាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានលក្ខណៈជាប្រព័ន្ធ តាមដំណាក់កាល មានសនិទានភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព និងប្រកបដោយសមធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីដំណើរការទូទៅនិងពេលវេលានៃការរៀបចំផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការផ្ទេរមុខងារនិងធនធាននានាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **មុខងារ** សំដៅដល់អំពើឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ បញ្ញើរចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។

- **ធនធាន** សំដៅដល់ទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ ចំណូល បុគ្គលិក និងសមត្ថភាព។
- **ក្រុមប្រឹក្សា** សំដៅដល់ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់។
- **ទ្រព្យសម្បត្តិ** សំដៅដល់គ្រឿងម៉ាស៊ីន យានយន្ត ឧបករណ៍ គ្រឿងសង្ហារិម សម្ភារៈការិយាល័យ លិខិតស្នាម ឯកសារ និងដីសាធារណៈ អចលនទ្រព្យសាធារណៈ សំណង់សាធារណៈ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ស្ពាន អគារ ព្រែក ផ្លូវ ឬវត្ថុប្រហាក់ប្រហែលគ្នានេះ។
- **រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- **មុខងារជាកាតព្វកិច្ច** សំដៅដល់មុខងារដែលត្រូវបានគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិអនុលោមទៅតាមបទដ្ឋាននិងនីតិវិធីដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬលិខិតបទដ្ឋានគតិយុត្តនានា។
- **មុខងារជាជម្រើស** សំដៅដល់មុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច ហើយរដ្ឋបាលថ្នាក់ក្រោមជាតិអាចជ្រើសរើសអនុវត្តឬមិនអនុវត្ត។
- **ផ្ទេរ** សំដៅដល់ការប្រគល់ឬការធ្វើប្រតិភូកម្មមុខងារ។
- **ការប្រគល់មុខងារ** សំដៅដល់ការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងធនធានុសិទ្ធិទាំងអស់ដែលចាំបាច់ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារ។
- **ប្រតិភូកម្មមុខងារ** សំដៅដល់ការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងធនធានុសិទ្ធិ ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។
- **ការផ្ទេរដែលមានលក្ខណៈជាប្រព័ន្ធ** សំដៅដល់ការផ្ទេរមុខងារដែលត្រូវភ្ជាប់មកជាមួយនូវការផ្ទេរធនធានសមស្រប។

## ជំពូកទី២
## ដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធាន
### ផ្នែកទី១
### គោលការណ៍

**មាត្រា ៥.-**

ការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងជាដំណាក់កាល មានសនិទានភាព លក្ខណៈជាប្រព័ន្ធ ការសម្របសម្រួល ការពិគ្រោះយោបល់ ផែនការសម្ភារៈនិងប្រកបដោយសមធម៌។

**មាត្រា ៦.-**

ការពិនិត្យមើលមុខងារឡើងវិញ ត្រូវផ្ដល់អាទិភាពចំពោះកិច្ចការចាំបាច់ដែលជះឥទ្ធិពលដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ ការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន។

**មាត្រា ៧.-**

ការផ្ទេរមុខងារតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- អាចគ្រប់គ្រងនិងអនុវត្តបានប្រកបដោយប្រសិទ្ធភាពនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- បម្រើឬផ្ដល់ផលប្រយោជន៍ជាចម្បងដល់ប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និង
- មានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

ការផ្ទេរមុខងារតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងដោយធានាថា៖

- ការផ្ទេរមុខងារត្រូវផ្សារភ្ជាប់ជាមួយការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងទៀតដែលចាំបាច់និងសមស្រប
- មានតម្លាភាព ការពិគ្រោះយោបល់ និងការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងតំណាងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលមុខងារ ដោយមានការសម្របសម្រួលពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សរសេរជាអក្សរកាត់ថា "**គ.ជ.អ.ប.**" អនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** និង
- មានការរំខានជាអប្បបរមាទៅលើប្រតិបត្តិការដែលកំពុងដំណើរការរបស់រាជរដ្ឋាភិបាល។

**មាត្រា ៨.-**

**គ.ជ.អ.ប.** ត្រូវពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវនិងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារនិងធនធានសម្រាប់ផ្ទេរឲ្យទៅដល់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

**មាត្រា ៩.-**

**គ.ជ.អ.ប.** ដោយមានជំនួយពីអនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** ត្រូវដឹកនាំសម្របសម្រួល គាំទ្រ និងតាមដានកិច្ចដំណើរការផ្ទេរមុខងារនិងធនធានដែលអនុវត្តដោយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

## ផ្នែកទី២
## ការរៀបចំបញ្ជីវិភាគមុខងារ

**មាត្រា ១០.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំបញ្ជីវិភាគមុខងារ ដើម្បីកំណត់ពី៖

- មុខងារទាំងអស់ដែលកំពុងអនុវត្តជាក់ស្តែងនិងអង្គភាពដែលគ្រប់គ្រងនិងទទួលខុសត្រូវលើការអនុវត្តមុខងារទាំងនេះ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានសម្រាប់បំពេញមុខងារទាំងនេះ
- ធនធានហិរញ្ញវត្ថុជាក់ស្តែងនាពេលបច្ចុប្បន្នដែលបានប្រើប្រាស់ដើម្បីអនុវត្តមុខងារទាំងនេះ
- ធនធានមនុស្សជាក់ស្តែងនាពេលបច្ចុប្បន្នដែលទទួលខុសត្រូវក្នុងការអនុវត្តមុខងារទាំងនេះ និង
- មធ្យោបាយ សម្ភារៈ បរិក្ខារ និងធនធានផ្សេងទៀតដែលចាំបាច់សម្រាប់អនុវត្តមុខងារទាំងនេះ។

**មាត្រា ១១.-**

**គ.ជ.អ.ប.** ត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងារ សម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ធ្វើជាមូលដ្ឋានក្នុងការរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន។

បន្ទាប់ពីបានរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន ក្រសួង ស្ថាប័នត្រូវផ្ញើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារនេះ ជូន **គ.ជ.អ.ប.** ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី៣
## ការពិនិត្យមើលមុខងារឡើងវិញ

**មាត្រា ១២.-**

បន្ទាប់ពីទទួលបានការឯកភាពពី **គ.ជ.អ.ប.** លើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ ក្រសួង ស្ថាប័ន ត្រូវពិនិត្យមើលឡើងវិញនូវមុខងារ ធនធាន លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការទទួលខុសត្រូវក្នុងការអនុវត្តមុខងារ ដើម្បីកំណត់អំពីមុខងារ និងធនធាន ដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៣.-**

ការពិនិត្យមើលមុខងារឡើងវិញ ត្រូវធ្វើឡើងស្របទៅនឹង៖

- មាត្រា២១៥ដល់មាត្រា២២១នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- របាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារដែលបានឯកភាពដោយ **គ.ជ.អ.ប.**
- គោលការណ៍នានាដែលមានចែងនៅក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ និង
- សេចក្តីសម្រេចនិងសេចក្តីណែនាំនានារបស់ **គ.ជ.អ.ប.**។

**មាត្រា ១៤.-**

**គ.ជ.អ.ប**. និងក្រសួង ស្ថាប័ននានាត្រូវធានាឲ្យមានសង្គតិភាពក្នុងការពិនិត្យមើលមុខងារឡើងវិញនៅក្នុងវិស័យទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងក្រសួង ស្ថាប័នលើសពីមួយ និងត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទាំងនេះ ព្រមទាំងជាមួយនឹងអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិនានាផ្សេងទៀត។

**មាត្រា ១៥.-**

នៅពេលដែលមុខងារណាមួយ ត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ ដំណើរការពិនិត្យមើលមុខងារឡើងវិញក៏ត្រូវកំណត់ផងដែរពីធនធានដែលត្រូវផ្ទេរជាមួយនឹងមុខងារ ព្រមជាមួយនឹងផែនការអភិវឌ្ឍន៍សមត្ថភាព ដែលអាចជាតម្រូវការចាំបាច់ដើម្បីធានាដល់ការចាត់ចែង ការគ្រប់គ្រង និងការអនុវត្តមុខងារនិងធនធានទាំងនោះ។

**មាត្រា ១៦.-**

ក្រសួង ស្ថាប័ននានាត្រូវកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួន បន្ទាប់ពីមុខងារត្រូវបានផ្ទេរ។

ការកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួនទាំងនេះ រួមមានការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ ការរៀបចំបទដ្ឋាន ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ ព្រមទាំងការកំណត់ពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពនានាដែលពាក់ព័ន្ធនឹងតួនាទីនិងការទទួលខុសត្រូវទាំងនេះ។

**មាត្រា ១៧.-**

**គ.ជ.អ.ប**. ត្រូវចេញសេចក្តីណែនាំស្តីពីការពិនិត្យមើលមុខងារឡើងវិញសម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ធ្វើជាមូលដ្ឋានក្នុងការពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញ។

បន្ទាប់ពីបានពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួន ក្រសួង ស្ថាប័នត្រូវធ្វើរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ ព្រមទាំងផែនការអភិវឌ្ឍន៍សមត្ថភាពនានាជូន **គ.ជ.អ.ប**. ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី៤

## ការអភិវឌ្ឍសមត្ថភាពដើម្បីទទួលមុខងារនិងធនធាន

**មាត្រា ១៨.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវទទួលខុសត្រូវក្នុងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនិងធនធានក្នុងពេលវេលាមួយសមស្រប ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ **គ.ជ.អ.ប**. ស្របតាមមាត្រា២៣៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៩.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបាននូវមុខងារ មានសមត្ថភាពក្នុងការគ្រប់គ្រង

ចាត់ចែង និងអនុវត្តមុខងារនិងធនធានទាំងនោះឲ្យបានស្មើឬលើសកម្រិតបទដ្ឋានដែលមាននាពេលបច្ចុប្បន្ន។

**មាត្រា ២០.-**

ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពទាំងនេះ ត្រូវធ្វើឡើងដោយមានកិច្ចសហការ និងមានការពិគ្រោះយោបល់រវាងក្រសួងស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ផ្នែកទី៥

## ការផ្ទេរមុខងារ ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

**មាត្រា ២១.-**

ការប្រគល់មុខងារឬការធ្វើប្រតិភូកម្មមុខងារ ត្រូវធ្វើឡើងដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ស្របតាមមាត្រា២៣៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២២.-**

ការផ្ទេរមុខងារឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមមាត្រា២៣៣ ដល់មាត្រា២៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជំពូកទី៣ ផ្នែកទី២នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការផ្ទេរទ្រព្យសម្បត្តិសម្រាប់ការអនុវត្តមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៤នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ២៣.-**

**គ.ជ.អ.ប.** ត្រូវពិនិត្យមើលសេចក្តីព្រាងច្បាប់ សេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលកំណត់អំពីការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថាសេចក្តីព្រាងច្បាប់ សេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តទាំងនេះ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យនេះ។

**មាត្រា ២៤.-**

ការផ្ទេរមុខងារឲ្យទៅដល់ឃុំ សង្កាត់ ត្រូវលើកលែងចំពោះវិស័យទាំងឡាយដូចមានចែងនៅក្នុងមាត្រា៤៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ការផ្ទេរមុខងារឲ្យទៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលើកលែងចំពោះវិស័យនិងមុខងារទាំងឡាយដែលត្រូវបានបម្រុងទុកផ្តាច់មុខសម្រាប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ។

**មាត្រា ២៥.-**

ដំណើរការនិងនីតិវិធីនៃការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលត្រូវផ្ទេរ ត្រូវកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាសស្តីពីការផ្ទេរមុខងារនោះ។

## ផ្នែកទី៦

## ស្ថាប័នទទួលបន្ទុកអនុវត្ត

**មាត្រា ២៦.-**

**គ.ជ.អ.ប.** ដោយមានជំនួយពីអនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** ទទួលខុសត្រូវរួមចំពោះរាជរដ្ឋាភិបាលលើដំណើរការពិនិត្យមើលឡើងវិញនូវមុខងារនិងដំណើរការផ្ទេរមុខងារនិងធនធានស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**គ.ជ.អ.ប.** ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ស្តីពីវឌ្ឍនភាពនៃដំណើរការពិនិត្យមើលឡើងវិញនូវមុខងារនិងការផ្ទេរមុខងារនិងធនធាន។

ក្រសួង ស្ថាប័នដែលអនុវត្តការផ្ទេរមុខងារនិងធនធាន ត្រូវធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃដំណើរការនៃការអនុវត្តការផ្ទេរមុខងារនិងធនធានរបស់ខ្លួនជូន **គ.ជ.អ.ប.**។

**មាត្រា ២៧.-**

ក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវជាចម្បងចំពោះ **គ.ជ.អ.ប.** លើដំណើរការរៀបចំបញ្ជីវិភាគមុខងារ ការពិនិត្យមើលឡើងវិញនូវមុខងារ និងដំណើរការផ្ទេរមុខងារនិងធនធាន។

**មាត្រា ២៨.-**

រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការចូលរួមចំណែកជួយគាំទ្រដល់ដំណើរការពិនិត្យមើលឡើងវិញនូវមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលរបស់ខ្លួន។

**មាត្រា ២៩.-**

រដ្ឋបាលរាជធានីនិងរដ្ឋបាលក្រុង ត្រូវពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញស្របតាមគោលការណ៍ដែលមានចែងនៅក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ ដើម្បីកំណត់អំពីមុខងារដែលអាចធ្វើប្រតិភូកម្មឲ្យទៅដល់រដ្ឋបាលខណ្ឌនិងរដ្ឋបាលសង្កាត់ ដោយមានភ្ជាប់ជាមួយនឹងការផ្ទេរធនធានសមស្រប។

## ផ្នែកទី៧

## យន្តការគាំទ្រ

**មាត្រា ៣០.-**

**គ.ជ.អ.ប.** ត្រូវធានាថា ការផ្ទេរមុខងារនិងធនធានត្រូវបានធ្វើឡើងតាមលក្ខណៈជាប្រព័ន្ធ តាមដំណាក់កាល មានសនិទានភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព និងប្រកបដោយសមធម៌។

**មាត្រា ៣១.-**

អនុគណៈកម្មាធិការមុខងារនិងធនធាន មានភារកិច្ចជួយលើការងារសម្របសម្រួល ពិគ្រោះយោបល់ ព្រមទាំងផ្ដល់អនុសាសន៍ដល់ **គ.ជ.អ.ប.** លើការងារទាំងអស់ដែលពាក់ព័ន្ធនឹងភារកិច្ចនិងការទទួលខុសត្រូវរបស់ **គ.ជ.អ.ប.** ក្នុងការកំណត់និងការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

លេខាធិការដ្ឋាន **គ.ជ.អ.ប.** ទទួលខុសត្រូវក្នុងការជួយអនុគណៈកម្មាធិការមុខងារនិងធនធាន និង **គ.ជ.អ.ប.** ផ្នែកបច្ចេកទេស ការសម្របសម្រួល ការពិគ្រោះយោបល់ ព្រមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ដំណើរការផ្ទេរមុខងារនេះ។

## ជំពូកទី៣

## អន្តរប្បញ្ញត្តិ

### ផ្នែកទី១

### ដំណើរការផ្ទេរមុខងារនិងធនធានសម្រាប់វិស័យឬកិច្ចការអាទិភាព

**មាត្រា ៣២.-**

នៅដំណាក់កាលពីឆ្នាំ២០១២ដល់ឆ្នាំ២០១៣ **គ.ជ.អ.ប.** ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវផ្ដល់អាទិភាពដល់ដំណើរការផ្ទេរមុខងារក្នុងវិស័យឬកិច្ចការមួយចំនួនដូចខាងក្រោម៖

- កសិកម្ម
- អប់រំ
- ព្រៃឈើ ជលផល ធនធានធម្មជាតិ និងបរិស្ថាន
- សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច
- ឧស្សាហកម្មនិងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច
- ការប្រើប្រាស់ដីធ្លី
- ការងារសុរិយោដីនិងការងារសំណង់
- ការផលិតនិងការចែកចាយអគ្គិសនី
- ការគ្រប់គ្រងទឹក
- តម្រូវការពិសេសឬតម្រូវការដែលបានកំណត់ជាក់លាក់សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរដំណែលវប្បធម៌ផងដែរ
- សង្គមកិច្ច
- អភិវឌ្ឍន៍ជនបទ។

ព្រមទាំងត្រូវយកចិត្តទុកដាក់ផ្តល់ការគាំទ្រលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ មធ្យោបាយ និងសម្ភារៈចាំបាច់ដើម្បីចាត់ចែងការទទួលខុសត្រូវលើមុខងារដែលបានប្រគល់និងធ្វើប្រតិភូកម្មខាងលើនេះ។

**មាត្រា ៣៣.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើមុខងារដែលស្ថិតនៅក្នុងចំណោមវិស័យឬកិច្ចការអាទិភាពដែលបានកំណត់ក្នុងមាត្រា៣២ខាងលើនេះ ត្រូវបញ្ចប់ការធ្វើបញ្ជីវិភាគមុខងារនិងការពិនិត្យមើលមុខងារឡើងវិញ ហើយដាក់របាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារនិងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញទាំងនោះជូន **គ.ជ.អ.ប.** ដើម្បីពិនិត្យនិងសម្រេចយ៉ាងយូរនៅចុងឆ្នាំ២០១២។

ចំពោះក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធនឹងវិស័យឬកិច្ចការអាទិភាពខាងលើត្រូវអនុវត្តដំណើរការផ្ទេរមុខងារ ដោយភ្ជាប់ជាមួយការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងទៀតដែលចាំបាច់និងសមស្របទៅតាមដំណាក់កាលៗ យ៉ាងយូរនៅក្នុងឆ្នាំ២០១៣ បន្ទាប់ពីទទួលបានការឯកភាពពី **គ.ជ.អ.ប.** លើរបាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារនិងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ខ្លួន។

**មាត្រា ៣៤.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលមិនស្ថិតនៅក្នុងវិស័យឬកិច្ចការអាទិភាពខាងលើ ត្រូវអនុវត្តទៅតាមដំណើរការរៀបចំធ្វើបញ្ជីវិភាគមុខងារនិងការពិនិត្យមើលឡើងវិញនូវមុខងារដូចគ្នានឹងក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលស្ថិតនៅក្នុងវិស័យឬកិច្ចការអាទិភាពដែរ និងដាក់ជូន **គ.ជ.អ.ប.** នូវរបាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារនិងការពិនិត្យមើលមុខងារឡើងវិញសម្រាប់ការផ្ទេរមុខងារ យ៉ាងយូរនៅក្នុងឆ្នាំ២០១៣។

**មាត្រា ៣៥.-**

ពេលវេលា ដំណាក់កាលនីមួយៗ និងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលត្រូវចាប់ផ្តើមអនុវត្តដំណើរការផ្ទេរមុខងារនិងធនធាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.អ.ប.**។

## ផ្នែកទី២
## ការផ្ទេរធនធានមនុស្ស

**មាត្រា ៣៦.-**

ក្នុងអំឡុងពេលដែលមិនទាន់មានច្បាប់ឬបទប្បញ្ញត្តិស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដំណើរការ និងនីតិវិធីនៃការផ្ទេរធនធានមនុស្សសម្រាប់អនុវត្តមុខងារដែលបានផ្ទេរត្រូវកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាសស្តីពីការផ្ទេរមុខងារនិងធនធាននោះ និងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៤
## អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣៨*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- តាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់នូវគណនេយ្យភាពរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ននានាដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ២ .-**

អនុក្រឹត្យនេះ មានគោលដៅធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

**មាត្រា ៣ .-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើមន្ត្រីរាជការស៊ីវិលស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលបំពេញការងារនៅថ្នាក់ក្រោមជាតិរួមមាន មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅតាមមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ លើកលែងតែមន្ត្រីរាជការស៊ីវិលនៃអង្គភាពគយ រតនាគារ ពន្ធដារ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈនានា។

## ជំពូកទី២
## គោលការណ៍

**មាត្រា ៤ .-**

ការអនុវត្តអំណាច ដែលបានធ្វើប្រតិភូកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការតែងតាំង

ការផ្លាស់ប្ដូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិតាមស្មារតីនៃអនុក្រឹត្យនេះ ត្រូវផ្អែកលើគោលការណ៍ប្រសិទ្ធភាព ពិគ្រោះយោបល់ តម្លាភាព គណនេយ្យភាព សមធម៌ និងអព្យាក្រឹតភាពរបស់មន្ត្រីរាជការស៊ីវិល ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៥ .-**

ការតែងតាំង ការផ្លាស់ប្ដូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ត្រូវផ្អែកទៅលើនីតិវិធី លក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដែលមានកំណត់នៅក្នុងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាជាធរមាន និងបទប្បញ្ញត្តិនានានៃអនុក្រឹត្យនេះ។

**មាត្រា ៦ .-**

រាល់កិច្ចប្រជុំរបស់គណៈអភិបាល និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីពិភាក្សា និង/ឬអនុម័តលើសំណើសុំតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលតាមស្មារតីនៃអនុក្រឹត្យនេះ ត្រូវធ្វើឡើងជាសម្ងាត់។

ក្រុមប្រឹក្សាត្រូវធ្វើការអនុម័តលើសំណើសុំតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងណាមួយតាមរយៈការបោះឆ្នោតជាសម្ងាត់។

រាល់កំណត់ហេតុកិច្ចប្រជុំនានាពាក់ព័ន្ធនឹងកិច្ចប្រជុំជាសម្ងាត់នេះ មិនត្រូវផ្សព្វផ្សាយជាសាធារណៈឡើយ។ ក្រុមប្រឹក្សាអាចអនុញ្ញាតឱ្យដកស្រង់ខ្លឹមសារគោលនៃកិច្ចប្រជុំសម្រាប់ផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ព័ត៌មានផ្ទាល់ខ្លួន កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់បុគ្គលឡើយ។

ក្រុមប្រឹក្សា បុគ្គលិករបស់ក្រុមប្រឹក្សា និងមន្ត្រីពាក់ព័ន្ធនានាត្រូវថែរក្សាឯកសារនានាពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួន កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់បុគ្គលដែលត្រូវបានស្នើតែងតាំង ឬផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចជាឯកសារសម្ងាត់ និងមិនត្រូវផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈឡើយ។

## ជំពូកទី៣
## អំណាច និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្ដូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល

### ផ្នែកទី១
### មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ៧ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឱ្យចេញដីកាតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។ បន្ទាប់ពីបានទទួលការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្តត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងខាងលើនេះ។

ចំពោះបេក្ខជន ដែលស្នើតែងតាំងត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃ ដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យ ដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្ត បន្ទាប់ពីមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើសុំផ្ទេរមន្ត្រីមកពីក្រសួងមហាផ្ទៃ ឬពីសាលារាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្តត្រូវធ្វើការប្រជុំឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។

## មាត្រា ៨ .-

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនាយកទីចាត់ការហិរញ្ញវត្ថុនៃសាលារាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះមកក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងសម្រេច។

បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្តត្រូវលើកសំណើនេះមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់ការឯកភាពលើសំណើនេះ។

ផ្អែកលើការឯកភាពខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។ ក្នុងករណីដែលពុំមានការឯកភាព រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងទៅអភិបាលរាជធានី ខេត្ត ដោយបញ្ជាក់អំពីហេតុផលនៃការពុំឯកភាពនេះ និង/ឬស្នើឲ្យអភិបាលរាជធានី ខេត្ត លើកសំណើបេក្ខជនថ្មីសម្រាប់ការតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ តាមនីតិវិធីដូចបានកំណត់ក្នុងវាក្យខ័ណ្ឌនានាខាងលើនៃមាត្រានេះ។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុង

គណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើលិខិតជម្រាបជូនអភិបាលរាជធានី ខេត្តអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

**មាត្រា ៩.-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលាក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងខាងលើទៅក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័ត មុននឹងលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលក្រុង ស្រុក ខណ្ឌពុំមានមន្ត្រីដែលមានលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យសមស្របសម្រាប់ការស្នើសុំតែងតាំងក្នុងមុខតំណែងទាំងនេះទេនោះ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន អាចស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីជ្រើសរើសបេក្ខជនដែលមានលក្ខណៈសមស្របពីសាលារាជធានី ខេត្ត ឬពីសាលាក្រុង ស្រុក ខណ្ឌផ្សេងទៀត ឬស្នើសុំផ្ទេរមន្ត្រីពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ផ្អែកតាមសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវពិនិត្យអំពីលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យរបស់មន្ត្រីដែលត្រូវបានស្នើតែងតាំងដោយផ្អែកតាមការកំណត់នៃលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ករណីបេក្ខជនដែលស្នើសុំតែងតាំងនោះពុំសមស្របនឹងលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដែលបានកំណត់ អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីជ្រើសរើសបេក្ខជនថ្មីដែលមានលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យសមស្របមកជំនួស។ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាល និងស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើបេក្ខជនថ្មីនេះជូនអភិបាលរាជធានី ខេត្ត។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាល និងសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។ ក្នុងករណីចាំបាច់ អភិបាល

រាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។ ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

**មាត្រា ១០ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ មកក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងសម្រេច។

បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលក្រុង ស្រុក ខណ្ឌត្រូវលើកសំណើនេះ មកអភិបាលរាជធានី ខេត្តសាមី ដើម្បីលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការផ្តល់ការឯកភាពលើសំណើនេះ។

ផ្អែកលើការឯកភាពខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។ ក្នុងករណីដែលពុំមានការឯកភាព រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងទៅអភិបាលរាជធានី ខេត្តដោយបញ្ជាក់អំពីហេតុផលនៃការពុំឯកភាពនេះ និង/ឬស្នើឲ្យអភិបាលរាជធានី ខេត្តសាមីពិភាក្សាជាមួយអភិបាលក្រុង ស្រុក ខណ្ឌសាមីក្នុងការលើកសំណើបេក្ខជនថ្មីសម្រាប់ការតែងតាំងមន្ត្រីក្នុងមុខតំណែងនេះ តាមនីតិវិធីដូចបានកំណត់ក្នុងវាក្យខណ្ឌខាងលើនៃមាត្រានេះ។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ក្នុងករណីចាំបាច់អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុនៃការស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីគណៈអភិបាលរាជធានី ខេត្តឯកភាពលើសំណើសុំផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចនេះ អភិបាលរាជធានី ខេត្ត ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីផ្តល់ការឯកភាពលើសំណើនេះ មុននឹងចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះតាមនីតិវិធីជាធរមាន។

## ផ្នែកទី២

## មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅតាមមន្ទីរ អង្គភាព និងការិយាល័យរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ

**មាត្រា ១១ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យមានសិទ្ធិលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងប្រធានមន្ទីរ ឬអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្តមករដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីនីមួយៗ។

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ ដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដើម្បីផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័នសាមី ឬពីមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នសាមីនៅរាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថាសំណើនេះពុំមានមូលហេតុសមស្រប រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើលិខិតជម្រាបជូនអភិបាលរាជធានី ខេត្តអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។ ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ននោះ ត្រូវចេញប្រកាសផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

**មាត្រា ១២ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានមន្ទីរ ឬអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្ត។

ប្រធានមន្ទីរ អង្គភាពសាមី ត្រូវលើកសំណើសម្រាប់ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងទាំងនេះមកអភិបាលរាជធានី ខេត្ត។ អភិបាលរាជធានី ខេត្ត ត្រូវយកសំណើនេះមកពិនិត្យ និងពិភាក្សាឲ្យមានការឯកភាពគ្នានៅក្នុងគណៈអភិបាល និងស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងទាំងនេះតាមនីតិវិធីជាធរមាន។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្តរួមជាមួយនឹងប្រធានមន្ទីរ អង្គភាពសាមីដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារាជធានី ខេត្តសាមីអាចស្នើសុំយោបល់ពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័នសាមី ឬពីមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នសាមីនៅរាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ ប្រធានមន្ទីរ អង្គភាពសាមីត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្តអាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើលិខិតជម្រាបជូនប្រធានមន្ទីរ អង្គភាពសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្តដោយមានការឯកភាពពីគណៈអភិបាលត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះ។

ក្នុងករណីដែលមន្ត្រីណាមួយក្នុងមុខតំណែងទាំងនេះ ត្រូវបានរកឃើញថាមានភាពមិនប្រក្រតី ឬការប្រព្រឹត្តខុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ ឬតាមតម្រូវនៃច្បាប់ អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវផ្តល់ការណែនាំដល់ប្រធានមន្ទីរ អង្គភាពសាមី ដើម្បីលើក

សំណើផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមកអភិបាលរាជធានី ខេត្ត។ ក្នុងករណីដែលប្រធានមន្ទីរ អង្គភាពសាមី នោះពុំអនុវត្តតាមការណែនាំនេះទេ អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនអាចមានសិទ្ធិផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះ ដោយពុំចាំបាច់មានសំណើពីប្រធានមន្ទីរ អង្គភាពសាមីនោះឡើយ។

**មាត្រា ១៣ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងចាប់ពីថ្នាក់ប្រធានការិយាល័យជំនាញ ឬថ្នាក់ប្រហាក់ប្រហែលចុះក្រោមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងទាំងនេះមកអភិបាលរាជធានី ខេត្ត តាមរយៈប្រធានមន្ទីរ អង្គភាពសាមី។

ចំពោះសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានការិយាល័យជំនាញ ឬថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានការពិគ្រោះយោបល់បន្ថែមជាមួយប្រធានការិយាល័យជំនាញសាមី។

ផ្អែកលើសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ និងមតិយោបល់របស់ប្រធានមន្ទីរ អង្គភាពសាមី អភិបាលរាជធានី ខេត្ត ត្រូវយកសំណើនេះមកពិនិត្យ និងពិភាក្សាឲ្យមានការឯកភាពគ្នានៅក្នុងគណៈអភិបាលរបស់ខ្លួន មុននឹងចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងទាំងនេះតាមនីតិវិធីជាធរមាន។

ចំពោះបេក្ខជនដែលស្នើតែងតាំងនេះ ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្របនេះទេ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីក្នុងការស្នើសុំផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័ន ឬពីមន្ទីរ អង្គភាពជំនាញនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌសាមីដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី តាមរយៈប្រធានមន្ទីរ អង្គភាពសាមី។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្តដោយមានការឯកភាពពីគណៈអភិបាលរាជធានី ខេត្ត ត្រូវចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

**មាត្រា ១៤ .-**

ចំពោះការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៃអង្គភាពរបស់ក្រសួង ស្ថាប័ន ដែលមានមុខងារផ្តល់សេវាគ្របដណ្តប់លើវិសាលភាពដែនដីនៃរដ្ឋបាលថ្នាក់ក្រោមជាតិលើសពីមួយ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលអង្គភាពនោះមានការិយាល័យតាំងនៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន និងប្រធានអង្គភាពសាមី ត្រូវអនុវត្តតាមនីតិវិធីនានាដូចបានកំណត់នៅក្នុងមាត្រា១១ មាត្រា១២ និងមាត្រា១៣នៃអនុក្រឹត្យនេះ ដោយមានការពិគ្រោះយោបល់ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលពាក់ព័ន្ធ។

**មាត្រា ១៥ .-**

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិក្នុងមុខតំណែងផ្សេងទៀតដែលពុំបានចែងនៅក្នុងមាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ និងមាត្រា១៤នៃអនុក្រឹត្យនេះ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៤
## ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ និងការគាំទ្រ

**មាត្រា ១៦ .-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងក្រសួងមុខងារសាធារណៈ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាដើម្បីរៀបចំនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តអំណាចដែលបានធ្វើប្រតិភូកម្មតាមស្មារតីនៃអនុក្រឹត្យនេះ ដើម្បីធានាថា ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់អនុវត្តអំណាចក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីដោយអនុលោមទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងធានាឲ្យបាននូវគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សមធម៌ និងអព្យាក្រឹតភាពនៃមន្ត្រីរាជការស៊ីវិល។

គ.ជ.អ.ប. ត្រូវធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល០៦ខែម្តងៗអំពីការអនុវត្តអនុក្រឹត្យនេះ។

**មាត្រា ១៧ .-**

អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលតាម គោលការណ៍នៃអនុក្រឹត្យនេះមកក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីរបស់មន្ត្រី ដែលបានតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពី ថ្ងៃតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច ដើម្បីពិនិត្យនីត្យានុកូលភាព និងបំពេញបែបបទពាក់ព័ន្ធនឹង ប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ ការងារក្របខ័ណ្ឌ និងការជានាការអនុវត្តតាមនីតិវិធីជាធរមាន។

ក្នុងការពិនិត្យនីត្យានុកូលភាព ប្រសិនបើពិនិត្យឃើញថា ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ ភារកិច្ចនេះធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន សាមីត្រូវធ្វើលិខិតណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិនោះឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវឡើងវិញ។

ករណីរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនអនុវត្តតាមការណែនាំនេះ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន សាមី ត្រូវធ្វើអន្តរាគមន៍ដោយចេញប្រកាសលុបចោលដីកាដែលធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាននោះជាបន្ទាន់។

**មាត្រា ១៨ .-**

ក្នុងការអនុវត្តអំណាចប្រតិភូកម្មតាមស្មារតីនៃអនុក្រឹត្យនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើការ បណ្តុះបណ្តាលកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ការ កិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ននានាដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ អាចពិគ្រោះយោបល់ជាមួយ គ.ជ.អ.ប. ដើម្បីចេញសេចក្តីណែនាំបន្ថែមតាមការចាំបាច់។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៩ .-**

មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ដែលត្រូវបានតែងតាំងក្នុងមុខតំណែង ណាមួយនៅមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តស្ថិតក្នុងមុខតំណែង និងបំពេញការងាររហូត ដល់មានតម្រូវការនៃការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចក្នុងមុខតំណែងនោះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ២០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.

**ស ខេង**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២១*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីគោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការពិគ្រោះយោបល់ក្នុងការរៀបចំការគ្រប់គ្រងនិងការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានកំណត់ត្រង់មាត្រា៣៨និងមាត្រា៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២.-**

រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអនុក្រឹត្យនេះ សំដៅត្រឹមតែរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមិនត្រូវអនុវត្តចំពោះការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ លើកលែងតែសកម្មភាពមួយចំនួនដែលទាក់ទងនឹងការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍក្រុង ស្រុក ខណ្ឌ។

ផែនការអភិវឌ្ឍនិងកម្មវិនិយោគរបស់ខណ្ឌ សង្កាត់ ត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់រាជធានីភ្នំពេញ។

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់សង្កាត់ក្នុងក្រុង ត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ក្រុង។

**មាត្រា ៤.-**

ផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់ធ្វើជាមូលដ្ឋានយុទ្ធសាស្ត្រសម្រាប់ណែនាំរាល់ការធ្វើសេចក្តីសម្រេចក្នុងការងារអភិវឌ្ឍ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលនឹងត្រូវទទួលហិរញ្ញប្បទានក្រោមក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងធនធាន ថវិកាពីប្រភពនានាតាមលទ្ធភាពជាក់ស្តែង។ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២

## គោលការណ៍រួម

## នៃការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

## របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៥.-**

ការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រព្រឹត្តទៅតាមគោលការណ៍រួម ដូចខាងក្រោម ÷

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាពនិងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពសេដ្ឋកិច្ចនិងសង្គម
- ការធានាចីរភាពធនធានធម្មជាតិនិងបរិស្ថាន
- ការធានាសមធម៌។

## ជំពូកទី៣
## យន្តការនិងការកិច្ចក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ៦.-**

ក្រុមប្រឹក្សាទទួលខុសត្រូវ ÷

- ណែនាំគោលនយោបាយទូទៅសម្រាប់រៀបចំខ្លឹមសារផែនការអភិវឌ្ឍ រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរក្សាសង្គតិភាពជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំនិងធនធានថវិកាពីប្រភពនានាតាមលទ្ធភាពជាក់ស្តែង
- ពិនិត្យនិងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍនៅឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន និងកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ
- ពិនិត្យនិងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍក្នុងករណីចាំបាច់
- ផ្តល់សុពលភាពដល់លទ្ធផលត្រួតពិនិត្យនិងវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលរាយការណ៍ដោយគណៈអភិបាល។

**មាត្រា ៧.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សា ទទួលខុសត្រូវ ÷

- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

- ពិនិត្យនិងជូនយោបល់ទៅក្រុមប្រឹក្សា មុនធ្វើការអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យនិងជូនយោបល់ទៅក្រុមប្រឹក្សាលើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**មាត្រា ៨.-**

គណៈអភិបាល ទទួលខុសត្រូវ ÷

- ដឹកនាំការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំនៅថ្នាក់រដ្ឋបាលខ្លួន ស្របតាមការណែនាំពីក្រុមប្រឹក្សា ដូចបានកំណត់ក្នុងមាត្រា៦ខាងលើ ដោយធានាលក្ខណៈសង្គតិភាពរវាងខ្លឹមសាររបស់ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាមួយនឹងផែនការនិងគោលការណ៍ជាធរមាននានារបស់ជាតិ របស់រដ្ឋបាលថ្នាក់លើ និងឆ្ពោះទៅរកការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចាត់ចែងអនុវត្តនិងតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាមួយនឹងអនុសាសន៍ចាំបាច់ សម្រាប់លើកកម្ពស់ការអនុវត្តផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សារួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ ÷
    - ក្រុមប្រឹក្សារួមគ្នា
    - ប្រភេទក្រុមប្រឹក្សាផ្សេងៗ
    - ក្រសួង ស្ថាប័នឬអង្គភាពនានារបស់រាជរដ្ឋាភិបាល
    - ដៃគូពាក់ព័ន្ធនានា
- ធានាឱ្យមានអន្តរាគមន៍រហ័សក្នុងការដោះស្រាយការលំបាកឬបញ្ហានានាដែលកើតមានឡើងជាយថាហេតុក្នុងអំឡុងពេលអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**មាត្រា ៩.-**

តាមការឯកភាពពីក្រុមប្រឹក្សានិងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ ត្រូវមានសមាសភាពយ៉ាងតិច ÷

- អភិបាលរាជធានី ខេត្ត ប្រធាន

- អភិបាលរងរាជធានី ខេត្ត០១រូប — អនុប្រធាន
- នាយករដ្ឋបាលសាលារាជធានី ខេត្ត — សមាជិក
- ប្រធានមន្ទីរផែនការរាជធានី ខេត្ត — សមាជិកអចិន្ត្រៃយ៍
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត — សមាជិក
- នាយកទីចាត់ការហិរញ្ញវត្ថុក្រុមប្រឹក្សារាជធានី ខេត្ត — សមាជិក
- ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ — សមាជិក
- ប្រធានឬតំណាងមន្ទីរនិងអង្គភាពជំនាញនានានៅរាជធានី ខេត្ត — សមាជិក
- នាយកឬតំណាងទីចាត់ការចំណុះសាលារាជធានី ខេត្ត — សមាជិក

**មាត្រា ១០._**

តាមការឯកភាពពីក្រុមប្រឹក្សានិងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ ត្រូវមានសមាសភាពយ៉ាងតិច ÷

- អភិបាលក្រុង ស្រុក ខណ្ឌ — ប្រធាន
- អភិបាលរងក្រុង ស្រុក ខណ្ឌ០១រូប — អនុប្រធាន
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ — សមាជិក
- ប្រធានការិយាល័យផែនការ ស្ថិតិក្រុង ស្រុក ខណ្ឌ — សមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ — សមាជិក
- ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ខណ្ឌ — សមាជិក
- ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ — សមាជិក
- តំណាងអង្គភាពគាំទ្រឃុំ សង្កាត់ — សមាជិក
- ប្រធានឬតំណាងការិយាល័យនិងអង្គភាពជំនាញនានានៅក្រុង ស្រុក ខណ្ឌ — សមាជិក
- ប្រធានឬតំណាងការិយាល័យចំណុះសាលាក្រុង ស្រុក ខណ្ឌ — សមាជិក

**មាត្រា ១១._**

ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ មានភារកិច្ច ÷

- រៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលជូនគណៈអភិបាល
- ជួយគណៈអភិបាល ធ្វើការរៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសេចក្ដីព្រាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយផ្អែកលើលទ្ធផលរបស់សិក្ខាសាលានិងកិច្ចប្រជុំពិគ្រោះយោបល់នានា។

# ជំពូកទី៤
## នីតិវិធី
## ការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ១២.-**

ក្នុងឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន ក្រុមប្រឹក្សាត្រូវកសាងផែនការអភិវឌ្ឍដែលមានសុពលភាពរយៈពេលប្រាំឆ្នាំ និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលលើកទី១ សម្រាប់ថ្នាក់រដ្ឋបាលខ្លួន។ កម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

**មាត្រា ១៣.-**

ក្នុងការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវមានការពិគ្រោះយោបល់ជាមួយនឹង ÷

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាដទៃទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ១៤.-**

វិធីសាស្ត្រសម្រាប់ធ្វើការប្រជុំពិគ្រោះយោបល់អំពីការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវកំណត់ដោយក្រុមប្រឹក្សា តាមតម្រូវការចាំបាច់។

រាល់សេចក្តីសម្រេចរបស់កិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាធាតុចូលសម្រាប់ក្រុមប្រឹក្សាធ្វើការពិនិត្យនិងអនុម័តលើសេចក្តីព្រាង។

**មាត្រា ១៥.-**

ក្នុងកិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ត្រូវមានការចូលរួមពីប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ពីក្រុង ស្រុក ខណ្ឌនៅក្នុងរាជធានី ខេត្ត។

**មាត្រា ១៦.-**

ក្នុងកិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ ត្រូវមានការចូលរួមពីមេឃុំ ចៅសង្កាត់ និងអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ សង្កាត់ ពីឃុំ សង្កាត់នីមួយៗនៅក្នុងក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៥
## ការអនុម័ត ការចាត់ចែងអនុវត្ត
## ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ១៧.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុម័តដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្ដាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

**មាត្រា ១៨.-**

សេចក្ដីស្នើកែសម្រួលលើផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុម័តដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្ដាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

**មាត្រា ១៩.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវតម្កល់ទុកជាឯកសារមួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត មួយច្បាប់នៅក្រសួងមហាផ្ទៃ មួយច្បាប់នៅក្រសួងផែនការ។

**មាត្រា ២០.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកជាឯកសារមួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត មួយច្បាប់នៅសាលាក្រុង ស្រុក ខណ្ឌ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈនិងបន្ទាន់នូវផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលបន្ទាប់ពីអនុម័តរួច ជូនសាធារណជន និងភាគីពាក់ព័ន្ធបានដឹង។

**មាត្រា ២២.-**

ក្រុមប្រឹក្សាត្រូវណែនាំឱ្យគណៈអភិបាលចាត់ចែងអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័ត ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព។

**មាត្រា ២៣.-**

ករណីក្រុមប្រឹក្សាត្រូវបានរំសាយមុនអាណត្តិ ក្រុមប្រឹក្សាថ្មីដែលទទួលការងារបន្តអាចទទួលយកផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលមុនទាំងស្រុងឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍសម្រាប់រយៈពេលដែលនៅសល់របស់អាណត្តិ។

មាត្រា ២៤._

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល មានសុពលភាពរហូតដល់មានផែនការអភិវឌ្ឍថ្មី និងកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្មីដែលបានអនុម័តដោយក្រុមប្រឹក្សាអាណត្តិបន្ទាប់។

## ជំពូកទី៦

## ការតាមដាន វាយតម្លៃ និងរបាយការណ៍

មាត្រា ២៥._

ក្រុមប្រឹក្សាត្រូវចាត់ចែងឱ្យមានការតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងបណ្ដាសកម្មភាពពាក់ព័ន្ធដែលអនុវត្តដោយស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិនានា និងផ្នែកឯកជននៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន។

មាត្រា ២៦._

នៅចុងឆ្នាំសារពើពន្ធនីមួយៗ គណៈអភិបាលត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ។ របាយការណ៍ប្រចាំឆ្នាំត្រូវមាន ÷

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តក្នុងឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម។

មាត្រា ២៧._

ក្រុមប្រឹក្សាត្រូវអនុម័តនិងផ្ញើជូនទៅគ្រប់ថ្នាក់ពាក់ព័ន្ធមានសមត្ថកិច្ចនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្នុងអំឡុងពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ។

មាត្រា ២៨._

សេចក្តីណែនាំលំអិតសម្រាប់អនុវត្តការកសាងនិងការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្នុងអនុក្រឹត្យនេះ ត្រូវកំណត់និងអាចធ្វើបច្ចុប្បន្នភាពតាមតម្រូវការជាក់ស្តែង ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃនិងក្រសួងផែនការ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

មាត្រា ២៩._

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៥ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣០*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៨១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១**.-

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាអប់រំកុមារតូច សេវាអប់រំបឋមសិក្សា និងសេវាអប់រំក្រៅប្រព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការបង្វិតការសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនេះឱ្យទៅកៀកជិតប្រជាពលរដ្ឋ។

**មាត្រា២** .-

អនុក្រឹត្យនេះមានគោលដៅ៖

- ប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក
- ផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់

- កំណត់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគាំទ្រ និងអនុវត្តមុខងារការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- កំណត់គោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធប្រកបដោយគុណភាព គណនេយ្យភាព ប្រសិទ្ធភាព និងសមធម៌។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅតាមដំណាក់កាលនីមួយៗ។

## ជំពូកទី២

## ការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក

**មាត្រា៤.-**

ប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅតាមដំណាក់កាលនីមួយៗ។

រដ្ឋបាលក្រុង ស្រុកទាំង១៤នៃខេត្តបាត់ដំបងត្រូវបានកំណត់ជារដ្ឋបាលក្រុង ស្រុកគោលដៅដែលត្រូវបានប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធចាប់ពីឆ្នាំ២០១៦។

ក្រសួងអប់រំ យុវជន និងកីឡាត្រូវសហការជាមួយក្រសួងមហាផ្ទៃដើម្បីលើកសំណើសុំការសម្រេចពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអំពីរដ្ឋបាលក្រុង ស្រុកគោលដៅផ្សេងទៀត និងដំណាក់កាលបន្តបន្ទាប់នៃការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធចាប់ពីឆ្នាំ២០១៧តទៅ។

**មាត្រា៥.-**

មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ដែលត្រូវប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុករួមមាន៖

- ការគ្រប់គ្រងបុគ្គលិកអប់រំកុមារតូច
- ការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា
- ការគ្រប់គ្រងសិស្ស
- ការរៀបចំផែនការសម្រាប់ការអប់រំកុមារតូច

- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំកុមារតូច
- ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនា សម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំកុមារតូច
- ការផ្តល់អាជ្ញាប័ណ្ណសម្រាប់បើក បន្តសុពលភាព ផ្អាកជាបណ្តោះអាសន្ន និងដកហូតអាជ្ញាប័ណ្ណសាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជនកម្មវិធីសិក្សាជាតិ និងកម្មវិធីសិក្សាអន្តរជាតិ
- ការគ្រប់គ្រងកម្មវិធីគាំទ្រការអប់រំកុមារតូចដូចជាកម្មវិធីមត្តេយ្យសិក្សាផ្ទះ និងកម្មវិធីមត្តេយ្យសិក្សាឯកជន។

សកម្មភាពលម្អិតនៃមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ជាឧបសម្ព័ន្ធទី១ នៃក្រឹត្យនេះ។

**ប្រការ៦.-**

មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំបឋមសិក្សាដែលត្រូវប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង កគោលដៅរួមមាន៖

- ការគ្រប់គ្រងបុគ្គលិកអប់រំបឋមសិក្សា
- ការគ្រប់គ្រងគ្រូបង្រៀនបឋមសិក្សាជាប់កិច្ចសន្យា
- ការគ្រប់គ្រងសិស្សបឋមសិក្សា
- ការរៀបចំផែនការសម្រាប់ការអប់រំបឋមសិក្សា
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំបឋមសិក្សា
- ការផ្គត់ផ្គង់សៀវភៅសិក្សាគោល
- ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំបឋមសិក្សា
- ការគ្រប់គ្រងដំណើរការគណៈកម្មការទ្រទ្រង់សាលារៀន
- ការគ្រប់គ្រងដំណើរការគណៈកម្មការកម្រងសាលារៀន
- ការផ្តល់អាជ្ញាប័ណ្ណសម្រាប់បើក បន្តសុពលភាព ផ្អាកជាបណ្តោះអាសន្ន និងដកហូតអាជ្ញាប័ណ្ណសាលាបឋមសិក្សាឯកជនកម្មវិធីសិក្សាជាតិ
- ការគ្រប់គ្រងកម្មវិធីការងារគាំទ្រការអប់រំបឋមសិក្សា៖
    - កម្មវិធីពហុភាសា
    - កម្មវិធីពន្លឿនការសិក្សា
    - កម្មវិធីស្បៀងអាហារតាមសាលារៀន
    - កម្មវិធីអប់រំពិសេស
    - កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ
    - កម្មវិធីអប់រំសុខភាព និងអនាម័យ

• ការងារក្រុមប្រឹក្សាកុមារ

• ការងារអប់រំកាយ និងកីឡា

សកម្មភាពលម្អិតនៃមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំបឋមសិក្សាជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា៧.-**

មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ដែលត្រូវប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅរួមមាន៖

- ការគ្រប់គ្រងបុគ្គលិកអប់រំ
- ការជ្រើសរើសនិងគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ
- ការប្រមូល ការគ្រប់គ្រងសិស្ស អ្នកសិក្សា និងអ្នកចូលរួម
- ការរៀបចំផែនការសម្រាប់ការអប់រំក្រៅប្រព័ន្ធ
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំក្រៅប្រព័ន្ធ
- ការផ្តល់អាជ្ញាប័ណ្ណសម្រាប់បើក បន្តសុពលភាព ផ្អាកជាបណ្តោះអាសន្ន និងដកហូតអាជ្ញាប័ណ្ណមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមុខរបរ និងភាសាបរទេសរយៈពេលតិចជាង០១ (មួយ)ឆ្នាំ
- ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំក្រៅប្រព័ន្ធ
- ការគ្រប់គ្រងដំណើរការកម្មវិធី និងសេវាពាក់ព័ន្ធនឹង៖
  • កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ
  • កម្មវិធីក្រោយអក្ខរកម្ម
  • កម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា
  • កម្មវិធីបង្កើនប្រាក់ចំណូល
  • កម្មវិធីចូលរៀនឡើងវិញ

សកម្មភាពលម្អិតនៃមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

គោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅដូចមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣
## ការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

**មាត្រា៩**.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលក្រុង ស្រុកគោលដៅ ដើម្បីកំណត់អំពីកញ្ចប់ធនធានហិរញ្ញវត្ថុ រូបមន្ត លក្ខណវិនិច្ឆ័យ ការបែងចែកធនធាន កាលវិភាគនៃការផ្ទេរ និងលក្ខខណ្ឌនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ។

ការកំណត់កញ្ចប់ធនធានហិរញ្ញវត្ថុ រូបមន្ត លក្ខណវិនិច្ឆ័យ ការបែងចែកធនធាន កាលវិភាគនៃការផ្ទេរ និងលក្ខខណ្ឌនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០**.-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវគ្រោងឥណទានចំណាយសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ នៅក្នុងជំពូកចំណាយមិនបានគ្រោងទុកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជូនដំណឹងជាផ្លូវការទៅរដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗ អំពីទំហំធនធានហិរញ្ញវត្ថុដែលត្រូវផ្ទេរសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដើម្បីឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅដាក់បញ្ចូលថវិកានេះទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ។

**មាត្រា១១**.-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្ទេរថវិកាសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗទៅតាមនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗ។

**មាត្រា១២.-**

រដ្ឋបាលក្រុង ស្រុកគោលដៅអាចប្រើប្រាស់ចំណែកធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀតសម្រាប់គាំទ្រដល់ការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់។

**មាត្រា១៣.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលក្រុង ស្រុកគោលដៅដើម្បីកំណត់អំពីទ្រព្យសម្បត្តិដែលត្រូវផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅសម្រាប់គាំទ្រអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅ។

**មាត្រា១៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសហការជាមួយក្រសួងអប់រំ យុវជន និងកីឡាដើម្បីរៀបចំផ្ទេរទ្រព្យសម្បត្តិនានាដែលកំពុងប្រើប្រាស់សម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ព្រមទាំងទ្រព្យសម្បត្តិចាំបាច់ផ្សេងទៀតតាមការកំណត់ដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់។

ការផ្ទេរទ្រព្យសម្បត្តិខាងលើនេះត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៥.-**

រដ្ឋបាលក្រុង ស្រុកគោលដៅត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានផ្ទេរឱ្យសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធស្របតាមលក្ខខណ្ឌ និងនីតិវិធីនានាដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការផ្ទេរធនធានមនុស្ស

**មាត្រា១៦.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ រដ្ឋបាលក្រុង ស្រុកគោលដៅ និង

អង្គភាពពាក់ព័ន្ធនានាដើម្បីកំណត់អំពីប្រភេទ និងចំនួនបុគ្គលិកនៃការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកដែលកំពុងគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដើម្បីផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗ។

**មាត្រា១៧.-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំផ្ទេរបុគ្គលិកដែលបានកំណត់ដូចមានចែងក្នុងមាត្រា១៦នៃអនុក្រឹត្យនេះឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅទៅតាមនីតិវិធីដែលបានកំណត់ដោយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ត្រូវមានលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗមិនទាបជាងលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួល។

**មាត្រា១៨.-**

ការគ្រប់គ្រង និងការចាត់ចែងបុគ្គលិកដែលបានផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅត្រូវអនុលោមតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៥

## រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុកគោលដៅ

**មាត្រា១៩.-**

ផ្ទេរការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកនៃក្រសួងអប់រំ យុវជន និងកីឡាឱ្យមកស្ថិតក្រោមរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុកគោលដៅសាមីនីមួយៗ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យអប់រំ យុវជន និងកីឡាដែលត្រូវបានផ្ទេរឱ្យមកស្ថិតក្រោមរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុកគោលដៅសាមីនីមួយៗត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា និងពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកដែលត្រូវបានផ្ទេរឱ្យមកស្ថិតក្រោមរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុកត្រូវបំពេញតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុកគោលដៅលើការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យរដ្ឋបាលក្រុង ស្រុក និងត្រូវបំពេញតួនាទីជាសេនាធិការឱ្យប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តលើការអនុវត្តមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការងារយុវជន ការងារកីឡា និងការងារផ្សេងទៀតដែលពុំទាន់បានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក។

ក្រសួងអប់រំ យុវជន និងកីឡាត្រូវដាក់ចេញនូវសេចក្តីណែនាំស្តីពីការគ្រប់គ្រង និងការអនុវត្ត

មុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការងារយុវជន ការងារកីឡា និងការងារផ្សេងទៀតដែលពុំទាន់បានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក។

**មាត្រា២០.-**

រដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗត្រូវទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានប្រគល់ដូចមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងស្តង់ដាជាតិអប់រំ។

ដើម្បីអនុវត្តមុខងារទាំងនេះ រដ្ឋបាលក្រុង ស្រុកគោលដៅ៖

- ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក
- ត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកដែលបានផ្ទេរសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់
- លើកសំណើសុំបង្កើត ប្រែក្លាយ បិទសាលាមត្តេយ្យសិក្សារដ្ឋ សាលាបឋមសិក្សារដ្ឋ
- លើកសំណើអំពីតម្រូវការបុគ្គលិកអប់រំ និងតម្រូវការនៃការបណ្តុះបណ្តាលបុគ្គលិក
- ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- អាចធ្វើប្រតិភូកម្មនូវមុខងារចាំបាច់មួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធទៅឱ្យដល់រដ្ឋបាលឃុំ សង្កាត់
- អាចកៀរគរការគាំទ្រថវិកា សម្ភារ និងបច្ចេកទេសពីអ្នកពាក់ព័ន្ធនានា និងអាចប្រើប្រាស់ធនធានទាំងនោះតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធតាមកាលកំណត់ ជូនមន្ទីរអប់រំ យុវជន និងកីឡាដើម្បីបូកសរុបជូនក្រសួងអប់រំ យុវជន និងកីឡា
- ត្រូវរៀបចំរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៃការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធតាមកាលកំណត់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបូកសរុបជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៦

## ការគាំទ្រ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**មាត្រា២១.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការប្រគល់មុខងារ និងធនធាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅតាមដំណាក់កាលនីមួយៗដែលបានកំណត់ ព្រមទាំងត្រូវសម្របសម្រួលដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលក្រុង ស្រុកគោលដៅក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រអប់រំ ស្តង់ដាជាតិអប់រំ គោលការណ៍ និងនីតិវិធីដែលបានកំណត់។

**មាត្រា២២.-**

ក្រសួងអប់រំ យុវជន និងកីឡាមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ស្តង់ដាជាតិអប់រំ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- រៀបចំកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន សៀវភៅសិក្សាគោលសម្រាប់ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- កំណត់និយាមសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ស្តង់ដាអប្បបរមាសម្រាប់ផ្គត់ផ្គង់ និងការប្រើប្រាស់បុគ្គលិកពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់រដ្ឋបាលក្រុង ស្រុកគោលដៅ និងបុគ្គលិកអប់រំដែលត្រូវបានផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ
- ជ្រើសរើស បណ្តុះបណ្តាល បែងចែក និងរៀបចំការគ្រូមត្តេយ្យសិក្សា គ្រូបឋមសិក្សា
- វាយតម្លៃគុណភាពការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុកគោលដៅអំពីការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- កៀរគរធនធានពីប្រភពនានាសម្រាប់គាំទ្រដល់កម្មវិធី ឬសកម្មភាពនានាពាក់ព័ន្ធនឹងការកែលម្អគុណភាពនៃការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ។

ក្រសួងអប់រំ យុវជន និងកីឡាអាចធ្វើប្រតិភូកម្មជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្នុងការគាំទ្រ

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកគោលដៅ។

**មាត្រា២៣.-**

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុកគោលដៅក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ និងធនធានពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ព្រមទាំងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

**មាត្រា២៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីគាំទ្រ និងតាមដានត្រួតពិនិត្យលើការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

**មាត្រា២៥.-**

ក្រសួងមុខងារសាធារណៈមានតួនាទីគាំទ្រដល់ការផ្ទេរបុគ្គលិកអប់រំកុមារតូច អប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ និងតាមដាន ត្រួតពិនិត្យការចាត់ចែងបុគ្គលិកដែលបានផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា២៦.-**

ក្នុងអំឡុងពេលដែលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្ទេរតំណាងទានថវិកាមិនទាន់រៀបចំរួចរាល់ ការគ្រប់គ្រង ការចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ត្រូវអនុវត្តតាមបែបបទ និងនីតិវិធីហិរញ្ញវត្ថុដែលកំពុងអនុវត្តបច្ចុប្បន្ន ដោយត្រូវរាយការណ៍ជូនក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុកគោលដៅ។

**មាត្រា២៧.-**

ក្នុងអំឡុងពេលដែលលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់អនុវត្តព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ក្រសួងមុខងារសាធារណៈត្រូវដាក់ចេញជាបន្ទាន់នូវសេចក្ដីណែនាំអំពីគោលការណ៍ បែបបទ និងនីតិវិធីដើម្បីធានាដល់ការផ្ទេរ និងការគ្រប់គ្រងបុគ្គលិកអប់រំដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និងក្រសួងផែនការ**
លេខ [illegible] ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការរៀបចំផែនការអភិវឌ្ឍន៍
## និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

********

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/១០៥៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងតាមការសម្រេចនៃកិច្ចប្រជុំ គ.ជ.អ.ប លើកទី៥ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១..**

ប្រកាសនេះ មានគោលបំណងណែនាំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការកសាង អនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់រដ្ឋបាលរបស់ខ្លួន ដោយមានការចូលរួម និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្រោមសុពលភាពនៃប្រកាសអន្តរក្រសួង នេះ ។

**ប្រការ ២..**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ យ៉ាងយូរបំផុត នៅក្នុងឆ្នាំទី២នៃអាណត្តិរបស់ខ្លួន។ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

**ប្រការ ៣..**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធានាឱ្យបានថា ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ត្រូវបានដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

**ប្រការ ៤..**

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ និងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់រាជធានី។

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់ក្រុង។

**ប្រការ ៥..**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារផ្លូវការ ហើយក្រុមប្រឹក្សានីមួយៗត្រូវរៀបចំចាត់ចែងផ្សព្វផ្សាយឯកសារនេះជាសាធារណៈ និងរក្សាទុកនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

# ជំពូកទី២

## យន្តការ និងភារកិច្ចក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៦..**

ដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរួមរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ភារកិច្ចសំខាន់ៗរបស់ក្រុមប្រឹក្សារួមមាន :

- ត្រួតពិនិត្យ និងចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ណែនាំផ្នែកគោលនយោបាយសម្រាប់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- តាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៧..**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ក្រៅពីភារកិច្ចខាងលើ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល មុននឹងក្រុមប្រឹក្សាធ្វើការពិនិត្យ និងអនុម័ត។

**ប្រការ ៨..**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ដឹកនាំ និងសម្របសម្រួលការងារកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្របតាមការណែនាំរបស់ក្រុមប្រឹក្សា ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៩..**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុមការងារកសាងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដឹកនាំ និងសម្របសម្រួលដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នានាជាមួយភាគីពាក់ព័ន្ធនានា ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ១០..**

ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទីចាត់ការ និងការិយាល័យនានា នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការដឹកនាំ និងសម្របសម្រួលដំណើរការកសាង អនុម័ត តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សហការជាមួយក្រុមការងារកសាងផែនការក្នុងការដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចូលរួមវិភាគស្ថានភាពនិងពិគ្រោះយោបល់ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួល និងចូលរួមការបណ្តុះបណ្តាលអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ។

## ជំពូកទី៣

## ដំណើរការកសាងផែនការអភិវឌ្ឍន៍

## និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ១១..**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន តាមរយៈដំណើរការដែលមានការចូលរួមនិងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេងទៀត សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រកបដោយគុណភាព និងស្របតាមគោលការណ៍ ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យលេខ២១៩ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ និងប្រតិទិនស្តីពីដំណើរការកសាងផែនការឱ្យបានច្បាស់លាស់ ដោយផ្អែកលើតម្រូវការអាទិភាពរបស់មូលដ្ឋាន សក្តានុពលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយរបស់ជាតិ ។

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា ត្រូវរៀបចំតាមរយៈដីកា ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

ការចំណាយនានាសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺត្រូវរ៉ាប់រងដោយថវិការបស់ក្រុមប្រឹក្សានីមួយៗ។

**ប្រការ ១២.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច :** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានក្នុងស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល
- **ក្របខ័ណ្ឌអភិវឌ្ឍន៍ :** រៀបរាប់ពីចក្ខុវិស័យ គោលដៅ គោលបំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃផែនការអភិវឌ្ឍន៍
- **ការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ :** រៀបរាប់អំពីអ្នកទទួលខុសត្រូវនិងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

**ប្រការ ១៣.-**

ក្នុងការកសាងផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការផ្សព្វផ្សាយពត៌មានអំពីដំណើរការ និងនីតិវិធីសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការកសាងផែនការអភិវឌ្ឍន៍ តាមរយៈការវិភាគស្ថានភាព និងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ និង
- ការអនុម័តផែនការអភិវឌ្ឍន៍

**ប្រការ ១៤.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច :** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច ក្នុងស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម និងតម្រូវការជាអាទិភាពរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- **គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល :** រៀបរាប់អំពីគម្រោងវិនិយោគ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងឆ្នាំទី១នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល។
- **ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ :** រៀបរាប់អំពីអ្នកទទួលខុសត្រូវ និងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

**ប្រការ ១៥.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយផ្អែកលើផែនការអភិវឌ្ឍន៍។ កម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ សកម្មភាពសំខាន់ៗនៃដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរួមមាន :

- ការវិភាគស្ថានភាព ដោយផ្តោតលើការកំណត់បញ្ហា និងតម្រូវការជាអាទិភាព
- ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ១៦.-**

ក្រសួងផែនការត្រូវជួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំព័ត៌មានស្តីពីវឌ្ឍនភាព នៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា កម្រងឯកសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យផ្សេងទៀតដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ប្រការ ១៧.-**

ក្រោយពេលដែលក្រុមប្រឹក្សារាជធានី ខេត្ត បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តរួចហើយ គណៈអភិបាលរាជធានី ខេត្តត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយដាក់ជូនអភិបាលរាជធានី ខេត្តនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើការថតចម្លងសេចក្តីព្រាងនេះជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវធ្វើការសម្របសម្រួល ពិនិត្យ ពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ជាមួយក្រសួងទាំងបីខាងលើនេះ ព្រមទាំងជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្រោយពេលពិនិត្យ និងពិគ្រោះយោបល់រួចរាល់ហើយ លេខាធិការដ្ឋានត្រូវធ្វើកំណត់បង្ហាញសុំយោបល់មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់របស់អភិបាលរាជធានី ខេត្ត។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ការធ្វើទំនាក់ទំនងជាមួយអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់របស់ក្រសួងមហាផ្ទៃលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានី ខេត្ត និងក្រសួងមហាផ្ទៃអំពីខ្លឹមសារសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រសួងមហាផ្ទៃត្រូវរាយការណ៍ និងស្នើសុំ គ.ជ.អ.ប ដើម្បីធ្វើការសម្រុះសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីក្រសួងមហាផ្ទៃផ្ញើទៅអភិបាលរាជធានី ខេត្តទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីក្រសួងមហាផ្ទៃ។

**ប្រការ ១៨..**

ក្រោយពេលដែលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌរួចហើយ គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើជូនអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋាននានា។ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់ដោយអភិបាលក្រុង ស្រុក ខណ្ឌ ដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធនានា។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការធ្វើទំនាក់ទំនងរវាងអភិបាលក្រុង ស្រុក ខណ្ឌ ជាមួយនឹងអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយអភិបាលរាជធានី ខេត្ត លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលរាជធានី ខេត្ត អំពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវរាយការណ៍ និងស្នើសុំមកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីអភិបាលរាជធានី ខេត្តទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីអភិបាលរាជធានី ខេត្ត។

ក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវពិចារណាអំពីភាពស្របច្បាប់ និងសង្គតិភាពនៃខ្លឹមសារផែនការអភិវឌ្ឍន៍ទៅនឹងគោលនយោបាយជាតិ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

**ប្រការ ១៩..**

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបោះពុម្ព បែងចែក ផ្សព្វផ្សាយជាសាធារណៈនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានអនុម័តដោយក្រុមប្រឹក្សា និងតម្កល់ទុកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរផែនការរាជធានី ខេត្ត ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ និងផ្ញើទៅក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

**ប្រការ ២០..**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសេចក្តីកែប្រែផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតែអនុម័តដោយសម្លេងឆ្នោតភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងមូល។

ក្នុងករណីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរំសាយមុនអាណត្តិ យោងតាមមាត្រា៦៤ នៃច្បាប់

ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌថ្មី អាចទទួលយកផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលកំពុងមានទាំងស្រុង ឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ សម្រាប់រយៈពេលអាណត្តិដែលនៅសល់ ។

## ជំពូកទី៤

## ការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ២១..**

បន្ទាប់ពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវបានអនុម័ត ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាត់ចែងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព ។

**ប្រការ ២២..**

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តគម្រោង និងសកម្មភាពនានានៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដូចជាការធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មជាដើម ។ល ។

## ជំពូកទី៥

## ការតាមដាន ការវាយតម្លៃ និងរបាយការណ៍

**ប្រការ ២៣..**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរួមទាំងគម្រោងនិង សកម្មភាពនានាដែលអនុវត្ត និងគ្រប់គ្រងក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដោយ :

- ប្រភេទក្រុមប្រឹក្សាដូចគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀត
- មន្ទីរ អង្គភាពនានា
- អ្នកពាក់ព័ន្ធផ្សេងទៀតដូចជា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ។

**ប្រការ ២៤..**

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល និងសមិទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល សមិទ្ធផល [illegible]ការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល០៦ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

នីតិវិធីនៃការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ គ.ជ.អ.ប ។

**ប្រការ ២៥.-**

នៅចុងឆ្នាំនីមួយៗ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ ខ្លឹមសាររបាយការណ៍នេះរួមមាន :

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម ។

ក្រៅពីរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ផ្សេងទៀត ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ ។

**ប្រការ ២៦.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុម័តរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដាន និងវាយតម្លៃ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ។

របាយការណ៍ប្រចាំឆ្នាំរបស់រាជធានី ខេត្ត ត្រូវផ្ញើជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា ។

របាយការណ៍ប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើជូនអភិបាលរាជធានី ខេត្ត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា ។

របាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ ការិយាល័យផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ជំពូកទី៦

## ការរៀបចំ និងការផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ២៧.-**

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធនានា ដើម្បីរៀបចំផ្សព្វផ្សាយ និងណែនាំឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនេះ ស្របតាមខ្លឹមសារនិងសកម្មភាពសំខាន់ៗដូចមានចែងក្នុងប្រការ១៣ ប្រការ១៤ ប្រការ១៥ និងប្រការ១៦នៃប្រកាសនេះ ។

**ប្រការ ២៨..**

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប អាចធ្វើការកែសម្រួលសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមការចាំបាច់ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

**ប្រការ ២៩..**

ក្រសួងផែនការនិងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំឯកសារ កម្មវិធីផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានក្នុងសេចក្តីណែនាំបច្ចេកទេសនេះ ។

## ជំពូកទី៧

## អវសានបញ្ញត្តិ

**ប្រការ ៣០..**

ប្រកាសនេះ ពុំមានអធិកភាពលើប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំសង្កាត់ឡើយ ប៉ុន្តែប្រកាសទាំងពីរមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ជាពិសេសសម្រាប់សង្កាត់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរាជធានី និងសង្កាត់ស្ថិតក្នុងដែនសមត្ថកិច្ចក្រុង ។

**ប្រការ ៣១..**

ប្រកាស និងសេចក្តីណែនាំទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣២..**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ខែ ធ្នូ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *សមាជិក "គ.ជ.អ.ប"*
- *ក្រសួង.ស្ថាប័នពាក់ព័ន្ធ*
  *"ដើម្បីជូនជ្រាប"*
- *សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ.កាលប្បវត្តិ*

គំនូសបំព្រួញស្ដីពី "យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣"






រូបភាព 5៖ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

<u>សម្គាល់</u>៖ ភូមិ ពុំមែនជាថ្នាក់រដ្ឋបាលនោះឡើយ។ ភូមិ គឺជាភ្នាក់ងាររបស់ឃុំ សង្កាត់ ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅសម្រាប់បម្រើឲ្យការគ្រប់គ្រងប្រជាពលរដ្ឋ និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងភូមិនីមួយៗ។




## រូបភាព 6៖ រចនាសម្ព័ន្ធរដ្ឋបាលស្រុក




## រូបភាព 7៖ រចនាសម្ព័ន្ធរដ្ឋបាលខេត្ត

# រចនាសម្ព័ន្ធរដ្ឋបាលខេត្ត



## រចនាសម្ព័ន្ធរដ្ឋបាលក្រុង



## មូលនិធិឃុំ សង្កាត់ ២០០២ ដល់២០១៧

| ឆ្នាំ | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|---|
| រដ្ឋបាល | 13,848,170,000 | 19,388,797,000 | 19,333,333,000 | 20,712,000,000 | 24,645,200,000 | 32,514,000,000 | 32,836,220,000 | 34,324,100,000 | 38,629,240,000 |
| អភិវឌ្ឍន៍ | 16,839,740,000 | 32,030,731,000 | 38,666,667,000 | 45,388,000,000 | 53,168,800,000 | 57,036,000,000 | 60,188,780,000 | 79,015,900,000 | 109,944,760,000 |
| **សរុប** | **30,687,910,000** | **51,419,528,000** | **58,000,000,000** | **66,100,000,000** | **77,814,000,000** | **89,550,000,000** | **93,025,000,000** | **113,340,000,000** | **148,574,000,000** |
| **Commune/Sangkat Fund 2002-2017 (USD)** | | | | | | | | | |
| Year | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
| Administration | 3,462,043 | 4,847,199 | 4,833,333 | 5,178,000 | 6,161,300 | 8,128,500 | 8,209,055 | 8,581,025 | 9,657,310 |
| Development | 4,209,935 | 8,007,683 | 9,666,667 | 11,347,000 | 13,292,200 | 14,259,000 | 15,047,195 | 19,753,975 | 27,486,190 |
| Total Allocation | **7,671,978** | **12,854,882** | **14,500,000** | **16,525,000** | **19,453,500** | **22,387,500** | **23,256,250** | **28,335,000** | **37,143,500** |

| 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | សរុប |
|---|---|---|---|---|---|---|---|
| 52,602,000,000 | 52,737,000,000 | 54,107,000,000 | 105,230,000,000 | 139,795,000,000 | 160,177,000,000 | 227,603,000,000 | 1,028,482,060,000 |
| 106,798,000,000 | 129,253,000,000 | 150,311,000,000 | 132,036,000,000 | 132,159,000,000 | 148,233,000,000 | 147,801,000,000 | 1,438,870,378,000 |
| **159,400,000,000** | **181,990,000,000** | **204,418,000,000** | **237,266,000,000** | **271,954,000,000** | **308,410,000,000** | **375,404,000,000** | **2,467,352,438,000** |

**Commune/Sangkat Fund 2002-2017 (USD)**

| 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | Total |
|---|---|---|---|---|---|---|---|
| 13,150,500 | 13,184,250 | 13,526,750 | 26,307,500 | 34,948,750 | 40,044,250 | 56,900,750 | **257,120,515** |
| 26,699,500 | 32,313,250 | 37,577,750 | 33,009,000 | 33,039,750 | 37,058,250 | 36,950,250 | **359,717,595** |
| **39,850,000** | **45,497,500** | **51,104,500** | **59,316,500** | **67,988,500** | **77,102,500** | **93,851,000** | **616,838,110** |

Note: 1USD=4000R

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៣០៤ ស.ណ.ន

# សេចក្តីណែនាំ
# ស្តីពី
# បែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង ជំនួយការមេភូមិ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការ អំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងយោងតាមការសំរេចនៃកិច្ចប្រជុំគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់លើកទី ២១ កាលពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ដូចខាងក្រោម :

## ១. អំពីភូមិ

ភូមិ មិនមែនជាថ្នាក់រដ្ឋបាលដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ ។

ភូមិ គឺជាកន្លែងប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន ។ ភូមិជាច្រើនរួមផ្តុំគ្នាបង្កើតបានឃុំ ឬសង្កាត់មួយ ។

ភូមិនីមួយៗ ត្រូវគ្រប់គ្រងដោយមេភូមិម្នាក់ អមដោយអនុប្រធានភូមិម្នាក់ និងសមាជិកភូមិម្នាក់ជាជំនួយការ ។

## ២. បែបបទ និង នីតិវិធីនៃការជ្រើសរើសមេភូមិ

អនុលោមតាមមាត្រា ៣០ និងមាត្រា ៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី១នេះ ត្រូវធ្វើការជ្រើសរើសមេភូមិនៅគ្រប់ភូមិទាំងអស់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ការរៀបចំជ្រើសរើសមេភូមិ ត្រូវធ្វើឡើងតែនៅភូមិណាដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ ។

ផ្អែកតាមសេចក្តីណែនាំនេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវចាត់ឱ្យមេឃុំ ចៅ

សង្កាត់របស់ខ្លួន ធ្វើសេចក្តីរាយការណ៍អំពីឈ្មោះភូមិដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ ។ ដើម្បីជ្រើសរើសមេភូមិសំរាប់ភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

**ក**-ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងរបស់ខ្លួន រៀបចំជ្រើសរើសបេក្ខជនមេភូមិយ៉ាងតិច ០៣ រូប សំរាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន ។

**ខ**-បេក្ខជនមេភូមិ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម ÷

- មានសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
- មានអាយុយ៉ាងតិច ២៥ ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិដែលបានដាក់ស្នើបេក្ខជននេះ យ៉ាងតិច ០៦ ខែជាប់ៗគ្នា ។

**គ**-មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ត្រូវពិគ្រោះពិភាក្សាគ្នាខិតខំជ្រើសរើសឱ្យមានស្ត្រីសំរាប់ជាបេក្ខជនមេភូមិ នៅភូមិនានានៃឃុំ សង្កាត់របស់ខ្លួន ។

**ឃ**-ក្រោយពីបានរៀបចំបេក្ខជនសំរាប់ភូមិនីមួយៗរួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័តបង្កើតគណៈកម្មការបោះឆ្នោតដែលមានសមាជិកយ៉ាងច្រើនត្រឹម ០៣រូប ដោយមានស្មៀនឃុំ សង្កាត់ចូលរួមផងដែរ ។ គណៈកម្មការបោះឆ្នោត ត្រូវរៀបចំសន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវប្រើក្រដាសពណ៌ស ដែលមានទំហំប៉ុនគ្នា ដោយសរសេរនូវឈ្មោះបេក្ខជន (សរសេរដោយដៃ ឬដោយម៉ាស៊ីនអង្គុលីលេខ ឬដោយកុំព្យូទ័រ) ដែលបានដាក់ស្នើដោយមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ទៅតាមលំដាប់អក្សរនៃឈ្មោះរបស់បេក្ខជនម្នាក់ៗ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗនោះ ត្រូវរៀបចំឱ្យមានចំនួនស្មើនឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សាមី ។ សន្លឹកឆ្នោតសំរាប់បេក្ខជននៃភូមិនីមួយៗ ត្រូវមានត្រារបស់ឃុំ សង្កាត់ដែលបោះនៅលើខ្នងនៃសន្លឹកឆ្នោត ។

**ង**-បន្ទាប់ពីបានរៀបចំសន្លឹកឆ្នោតតាមភូមិនីមួយៗចំណុះឃុំ សង្កាត់ របស់ខ្លួនរួចហើយ គណៈកម្មការបោះឆ្នោត តាមរយៈមេឃុំ ចៅសង្កាត់ ត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ដើម្បីរៀបចំបោះឆ្នោតជ្រើសរើសម្តងមួយភូមិៗក្នុងរយៈពេលមិន

ឱ្យលើសពី ០៧ថ្ងៃ បន្ទាប់ពីថ្ងៃដាក់ស្នើបេក្ខជននោះ ។

៤-មុនចាប់ផ្ដើមបោះឆ្នោតជ្រើសរើសមេភូមិ អធិបតីនៃអង្គប្រជុំត្រូវធ្វើសេចក្ដីរាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន អំពីគោលការណ៍សំខាន់ៗនៃការបោះឆ្នោតជ្រើសរើសមេភូមិ រួចហើយត្រូវប្រគល់ភារកិច្ចជូនគណៈកម្មការបោះឆ្នោតដើម្បីរៀបចំនីតិវិធីដូចខាងក្រោម ÷

- សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យមានចំនួនស្មើនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យដូចៗគ្នានូវទំរង់ ទំហំ និងឈ្មោះបេក្ខជន ។

- រាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន អំពីឈ្មោះបេក្ខជនសំរាប់ភូមិនីមួយៗ ។

- សមាជិកក្រុមប្រឹក្សាម្នាក់ៗមានសិទ្ធិទទួលបានសន្លឹកឆ្នោតមួយសន្លឹកសំរាប់ភូមិមួយដែលបានចែកជូនក្នុងពេលបោះឆ្នោត ។

- សមាជិកក្រុមប្រឹក្សាម្នាក់ត្រូវគូសជ្រើសយកបេក្ខជនដែលខ្លួនគាំទ្រតែម្នាក់ប៉ុណ្ណោះលើសន្លឹកឆ្នោតដែលបានចែកជូនដោយគណៈកម្មការបោះឆ្នោត ។

- សន្លឹកឆ្នោតមិនបានការជាសន្លឹកឆ្នោតដែល :

+ មិនមែនជាសន្លឹកឆ្នោតដែលបានចែកជូនដោយគណៈកម្មការបោះឆ្នោត
+ គ្មានត្រារបស់ឃុំ សង្កាត់
+ គូសគាំទ្របេក្ខជនលើសពីម្នាក់
+ មិនមានគំនូសគាំទ្របេក្ខជនណាម្នាក់
+ មានសញ្ញាដែលធ្វើឱ្យគេស្គាល់អ្នកបោះឆ្នោត
+ រហែក ឬខូច
+ មានគំនូស តែគណៈកម្មការរៀបចំការបោះឆ្នោតមិនអាចកំណត់បានថាគាំទ្របេក្ខជនណាមួយ ។

៥-បន្ទាប់ពីបានណែនាំពីគោលការណ៍ នៃការបោះឆ្នោតជ្រើសរើសរួចរាល់ហើយ គណៈកម្មការបោះឆ្នោតត្រូវចែកសន្លឹកឆ្នោតជូនសមាជិកក្រុមប្រឹក្សាដែលមានវត្តមានក្នុងកិច្ចប្រជុំ ដើម្បីបោះឆ្នោតជ្រើសរើសមេភូមិម្ដងមួយភូមិៗ ។

៦-ក្រោយពីសមាជិកក្រុមប្រឹក្សាគ្រប់ៗរូប ដែលមានវត្តមានក្នុងកិច្ចប្រជុំបានបោះឆ្នោតជ្រើសរើសរួចរាល់អស់ហើយ គណៈកម្មការបោះឆ្នោតត្រូវធ្វើការរាប់សន្លឹកឆ្នោតភូមិដែលបានបោះឆ្នោតនោះនៅចំពោះមុខអង្គប្រជុំ ដោយកត់ត្រាលទ្ធផលនៃការបោះឆ្នោត

ជ្រើសរើសមេភូមិនៃភូមិនីមួយៗនោះ នៅលើក្តារខៀន ឬផ្ទាំងក្រដាសស រួចហើយអធិបតីនៃអង្គប្រជុំត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោត បន្ទាប់ពីការរាប់សន្លឹកឆ្នោតហើយភ្លាម ។

**ឃ**-បន្ទាប់មកអធិបតីនៃអង្គប្រជុំ ត្រូវចាត់ឱ្យគណៈកម្មការបោះឆ្នោត រៀបចំបោះឆ្នោតជ្រើសរើសមេភូមិផ្សេងទៀតដែលនៅសល់ជាបន្តបន្ទាប់រហូតគ្រប់ចំនួនភូមិដែលបានទទួលស្គាល់ជាផ្លូវការ ។

**៣**- បេក្ខជនដែលជាប់ឆ្នោត គឺជាបេក្ខជនដែលមានសម្លេងឆ្នោតគាំទ្រច្រើនជាងគេ ហើយសម្លេងគាំទ្រនោះ ត្រូវមានចំនួនលើសពីពាក់កណ្តាល នៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

**៤**-ក្នុងពេលរាប់សន្លឹកឆ្នោត ប្រសិនបេក្ខជនណាដែលមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។ ក្នុងករណីសម្លេងស្មើគ្នានោះជាបេក្ខ-ជនបុរស និងបេក្ខជនស្ត្រី បេក្ខជនស្ត្រីត្រូវបានជាប់ឆ្នោតជាមេភូមិ ។

**៥**-ចំពោះបេក្ខជនភូមិណាដែលមិនបានទទួលសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាល នៃសមាជិកក្រុមប្រឹក្សាទាំងមូល អធិបតីនៃអង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ចៅសង្កាត់រងដាក់ស្នើបេក្ខជនជាថ្មីសំរាប់ភូមិនោះ ទៅតាមបែបបទ នីតិវិធី ដូចមានចែងក្នុងចំណុច **ក ខ គ** និង **ឃ** ។

ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំដើម្បីបោះឆ្នោតជ្រើសរើសលើបេក្ខជនមេភូមិនោះជាលើកទី២ ទៅតាមបែបបទ នីតិវិធីនៃការបោះឆ្នោតចាប់ពីចំណុច **ខ** ដល់ចំណុច **៤** ខាងលើ ក្នុងរយៈពេលយ៉ាងយូរ០៧ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោតលើកទី១ ។

នៅក្នុងការបោះឆ្នោតលើកទី២នេះ ប្រសិនបើបេក្ខជននៅតែមិនបានទទួលសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូលទៀត អធិបតីនៃអង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ជ្រើសយកតែបេក្ខជនពីររូបដែលមានសម្លេងឆ្នោតគាំទ្របន្តបន្ទាប់គ្នាមកធ្វើការបោះឆ្នោតជ្រើសរើសសារឡើងវិញភ្លាម ។ ក្នុងការបោះឆ្នោតលើកចុងក្រោយនេះ បើគ្មានបេក្ខជនណាម្នាក់បានទទួលសម្លេងឆ្នោតគាំទ្រគ្រប់គ្រាន់ដូចមានចែងក្នុងចំណុច **៣** ខាងលើនេះទេ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- សំរេចជ្រើសយកបេក្ខជនជាស្ត្រីធ្វើជាមេភូមិ បើក្នុងចំណោមបេក្ខជនទាំងពីរខាងលើនេះមានម្នាក់ជាស្ត្រី
- សំរេចជ្រើសយកបេក្ខជនដែលមានអាយុចាស់ជាងធ្វើជាមេភូមិ បើសិនជាបេក្ខជនទាំងពីរខាងលើនេះជាបុរស ។

បេក្ខជនមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបោះឆ្នោតជ្រើសរើស ៧/២

រួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចតែងតាំងមេភូមិនីមួយៗនោះក្នុងរយៈពេល ០៧ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបោះឆ្នោត ។

៣. **អំពីការតែងតាំងជំនួយការមេភូមិ**

អនុលោមតាមមាត្រា ៣០ និង មាត្រា ៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវណែនាំមេភូមិនីមួយៗដែលបានទទួលការតែងតាំងជាផ្លូវការរួចហើយនោះ អោយធ្វើការដាក់បេក្ខជនជំនួយការរបស់ខ្លួនជាអនុប្រធាន និងសមាជិកភូមិ រួចហើយលើកសំណើដល់មេឃុំ ចៅសង្កាត់សាមីដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ពិនិត្យ និងអនុម័តក្នុងរយៈពេលយ៉ាងយូរ ០៧ ថ្ងៃ បន្ទាប់ពីថ្ងៃតែងតាំងមេភូមិនោះជាផ្លូវការ ។

ក្នុងការរៀបចំបេក្ខជនអនុប្រធាន និងសមាជិកភូមិនីមួយៗ មេភូមិ និងមេឃុំ ចៅសង្កាត់ ត្រូវរៀបចំឱ្យមានបេក្ខជនស្ត្រីយ៉ាងហោចណាស់ម្នាក់ សំរាប់មុខតំណែងអនុប្រធានភូមិ ឬសមាជិកភូមិ ចំពោះភូមិទាំងឡាយណាដែលមានមេភូមិជាបុរស ។

បេក្ខជនសំរាប់មុខតំណែងអនុប្រធាន និងសមាជិកភូមិ មានលក្ខណៈសម្បត្តិដូចគ្នានឹងមេភូមិ ដូចបានកំណត់ក្នុងចំណុច ខ នៃចំណុចទី២ ខាងលើ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តដោយលើកដៃ លើបេក្ខជនអនុប្រធាន និងសមាជិកភូមិនីមួយៗចំណុះឃុំ សង្កាត់របស់ខ្លួន តាមសម្លេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាទាំងមូល ក្នុងរយៈពេល ០៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបេក្ខជននេះ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសម្លេងស្មើគ្នា សម្លេងអធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។ ផ្ទុយទៅវិញប្រសិនបើបេក្ខជនសំរាប់មុខតំណែងជាអនុប្រធានភូមិ ឬសមាជិកភូមិនៃភូមិណាមួយដែលមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់របស់ខ្លួនពិគ្រោះពិភាក្សាជាមួយជំទប់ចៅសង្កាត់រង ដើម្បីណែនាំមេភូមិឱ្យដាក់ស្នើបេក្ខជនជាលើកទី២ ក្នុងរយៈពេល ០៥ថ្ងៃយ៉ាងយូរ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំវិសាមញ្ញដើម្បីពិនិត្យ និងអនុម័តនៅលើបេក្ខជនជំនួយការនោះជាលើកទី២ ក្នុងរយៈពេលយ៉ាងយូរ ០៧ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ស្នើបេក្ខភាព ។

លើកទី២នេះ ប្រសិនបើបេក្ខជនដែលបានដាក់ស្នើនេះនៅតែមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ ដោយសម្លេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាទាំងមូលទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យបោះឆ្នោតគាំទ្រម្តងទៀត ដោយសម្លេងភាគ

ច្រើននៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានចូលរួម ។

បេក្ខជនជំនួយការមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តយល់ព្រមរួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្ដីសំរេចតែងតាំងជំនួយការមេភូមិនីមួយៗ នោះក្នុងរយៈពេល ០៧ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័ត ។

ប្រធាន អនុប្រធាន និងសមាជិកភូមិក្នុងមុខតំណែងត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មីមកជំនួស ។

ប្រធាន អនុប្រធាន និងសមាជិកភូមិក្នុងមុខតំណែង អាចត្រូវជ្រើសរើសជាបេក្ខជនសំរាប់មុខតំណែងមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិបាន ឱ្យតែជននោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមការណែនាំនេះ ។

## ៤. អាណត្តិការងារ និង ការបាត់បង់មុខតំណែង

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ។

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយដូចខាងក្រោម ÷

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនដាក់ពាក្យសុំលាឈប់ពីមុខតំណែងជាលាយល័ក្ខអក្សរ
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីភ្នាក់ងារមានសមត្ថកិច្ច
- សាមីខ្លួនត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃឃុំ សង្កាត់របស់ខ្លួន
- សាមីខ្លួនត្រូវតុលាការផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សាមីខ្លួនផ្លាស់ទីលំនៅទៅភូមិផ្សេង
- សាមីខ្លួនមានកំហុសឆ្គងក្នុងការងារ ហើយត្រូវបញ្ឈប់ពីមុខតំណែងដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ដែលអនុវត្តផ្ទុយពីតួនាទី ភារកិច្ច និងរបៀបរបបការងារដូចមានចែងក្នុងចំណុចទី ៥ នៃសេចក្ដីណែនាំនេះ ត្រូវចាត់ទុកថាមានកំហុសឆ្គងក្នុងការងារ ។

ក្នុងករណីមានមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាមួយ ដែលបានប្រព្រឹត្តខុសឆ្គងក្នុងការងារ មេឃុំ ចៅសង្កាត់សាមី ត្រូវធ្វើការណែនាំជាលាយល័ក្ខអក្សរឱ្យសាមីខ្លួនកែលំអចំណុចខុសឆ្គងទាំងនោះ និងត្រូវធ្វើសេចក្ដីរាយការណ៍ជូនក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ក្នុងករណីដែលបានទទួលការណែនាំហើយ ប៉ុន្តែសាមីខ្លួននៅតែប្រព្រឹត្តខុសឆ្គងបន្តទៀតនោះ មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្ដីរាយការណ៍ WC

ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះអញ្ជើញសាមីខ្លួនអោយមកទទួលការណែនាំនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីឱ្យសាមីខ្លួនធ្វើការកែលំអកំហុសឆ្គង ។ ក្រោយពីបានទទួលការណែនាំពីក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ ប្រសិនបើសាមីខ្លួនមិនព្រមរាងចាល មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងស្នើសុំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់សំរេចអនុម័ត បញ្ឈប់ជននោះពីមុខតំណែងតាមសម្លេងភាគច្រើននៃក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

ក្នុងករណីមានមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាម្នាក់ត្រូវបានបាត់បង់ពីមុខតំណែងតាមករណីណាមួយខាងលើនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យធ្វើការជ្រើសរើសបេក្ខជនសំរាប់កន្លែងដែលទំនេរនោះ ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យអនុម័ត ក្នុងរយៈពេល ០៧ថ្ងៃយ៉ាងយូរ ស្របទៅតាមបែបបទ និងនីតិវិធី ដូចមានចែងក្នុងចំណុចទី២ និងចំណុចទី៣ នៃសេចក្តីណែនាំនេះ ។

## ៥. តួនាទី ភារកិច្ច និង របៀបរបបការងាររបស់ភូមិ

ផ្អែកតាមមាត្រា ៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងមាត្រា ២៣ ២៤ ២៥ ២៦ ២៧ ២៨ និងមាត្រា ២៩ នៃអនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិត្រូវបានកំណត់តួនាទី ភារកិច្ច និងរបៀបរបបការងារដូចខាងក្រោម ÷

- មេភូមិ ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសំរាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។

- ក្នុងការអនុវត្តការងារ មេភូមិត្រូវ :

១. បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន

២. ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមាន ជាអាទិ៍ :

+ ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិអំពីតម្រូវការនិងផលប្រយោជន៍របស់ភូមិ

+ ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ

+ ផ្តល់យោបល់ដល់គណៈកម្មាធិការផែនការអភិវឌ្ឍន៍ និងថវិកា អំពី :

- តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងថវិកានិងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុវត្តថវិកា និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា និងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន ។

- មេភូមិត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

- មេភូមិត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

- មេភូមិត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

- មេភូមិ មិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងផ្សេងទៀតក្នុងនាមភូមិបានឡើយ ។

- មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវជួបប្រជុំគ្នាយ៉ាងតិចមួយដងក្នុងមួយខែ ។

- មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវធ្វើការពិគ្រោះឱ្យបានទៀងទាត់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិភាក្សាជាមួយមេភូមិ ដើម្បីរៀបចំឱ្យមានទីកន្លែងសំរាប់មេភូមិជួបប្រាស្រ័យជាមួយមជ្ឈដ្ឋាននានាតាមភូមិនីមួយៗ ។

ទីកន្លែងនោះ អាចជាទីស្នាក់ការភូមិ ចំពោះកន្លែងដែលមានទីស្នាក់ការភូមិ ។ ចំពោះកន្លែងដែលគ្មានទីស្នាក់ការភូមិ ត្រូវពិគ្រោះពិភាក្សាគ្នា ដើម្បីរកទីកន្លែងសមស្របណាមួយ ដែលអាចជាសាលារៀន វត្តអារាម វិហារសាសនា អគារសាធារណៈ ឬគេហដ្ឋានផ្ទាល់របស់មេភូមិ ។ ការជ្រើសរើសយកកន្លែងទាំងនោះ ត្រូវមានការពិគ្រោះពិភាក្សាឱ្យឯកភាពគ្នាពីក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងត្រូវមានការយល់ព្រមជាមុនពីម្ចាស់ទីកន្លែងទាំងនោះ ។ មេភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយទីកន្លែងនោះដល់សាធារណៈជន ។

ទីកន្លែងនោះត្រូវបើកទទួលប្រជាពលរដ្ឋយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍។

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ត្រូវមានវត្តមាននៅទីកន្លែងដែលបាន

កំណត់នោះ នាថ្ងៃនោះ ដើម្បីជួបប្រជាពលរដ្ឋ ។

ក្រៅពីការជួបប្រាស្រ័យជាទៀងទាត់ជាមួយប្រជាពលរដ្ឋរបស់ខ្លួននៅទីកន្លែងដែលបានកំណត់នោះ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ អាចនឹងជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនជាប្រចាំតាមការចាំបាច់ ។

មេភូមិត្រូវធានាផ្តល់ព័ត៌មានជាឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារព័ត៌មានទាំងនោះអាចរួមមាន ព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ ។

មេភូមិ ពុំមានសិទ្ធិអំណាចសំរេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់បានឡើយ ។

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួមហាផ្ទៃដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។

ដើម្បីធានាអនុវត្តតួនាទី ភារកិច្ចខាងលើនេះ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបានធ្វើការបែងចែកប្រគល់ភារកិច្ចដូចខាងក្រោម ÷

- មេភូមិទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន
- អនុប្រធានភូមិទទួលជំនួសមេភូមិ ក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជា មានជម្ងឺ ឬមានបេសកកម្មក្រៅពីឃុំ សង្កាត់សាមី លើសពី ០១ថ្ងៃ។ ក្រៅពីនេះ អនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគំរោងអភិវឌ្ឍន៍នានាក្នុងភូមិ តាមគំរោងផែនការរបស់ឃុំ សង្កាត់ ។
- សមាជិកភូមិទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ ។

ក្រៅពីការងារខាងលើនេះ មេភូមិអាចធ្វើការបែងចែក ប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី ។

## ៦. អំពីការបង្កើតភូមិថ្មី ការបង្រួម និង ការរំសាយភូមិ

ដើម្បីធានាដល់ការចាត់ចែងការងារ និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់អាចលើកសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិ ចំណុះឃុំ

សង្កាត់របស់ខ្លួនបាន ប៉ុន្តែត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

**ក. <u>ការបង្កើតភូមិថ្មី</u> ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ :**

- មានលំនៅដ្ឋាន និងប្រជាពលរដ្ឋយ៉ាងតិច ១៥០គ្រួសារ ដែលប្រមូលផ្តុំគ្នានៅទីតាំងមួយសមស្រប ហើយដែលលំបាកដាក់បញ្ចូលនៅក្នុងភូមិណាមួយនៃឃុំ សង្កាត់ជាមួយ ឬឃុំ សង្កាត់ដែលជិតខាងជាប់គ្នា
- មិនត្រូវស្ថិតក្នុងទីតាំងដែលច្បាប់ហាមឃាត់
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលនៃភូមិដែលគ្រោងបង្កើតថ្មីនោះគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ជិតខាងដែលនៅជាប់គ្នា ។

**ខ. <u>ការបំបែកភូមិ</u> ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ :**

- ភូមិដែលស្នើបំបែកនោះ មានប្រជាពលរដ្ឋច្រើនលើសលប់ ឬពិបាកគ្រប់គ្រង
- ក្រោយពេលបំបែកហើយ នៅសល់ចំនួនប្រជាលរដ្ឋសមស្របយ៉ាងហោចណាស់ស្មើនឹងភូមិដែលបង្កើតថ្មីដែរ
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ណាមួយជិតខាងដែលនៅជាប់គ្នា ។

**ឃ. <u>ការរំសាយ និងការបង្រួមភូមិបញ្ចូលគ្នា</u> ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :**

- មានចំនួនលំនៅដ្ឋាននិងគ្រួសារប្រជាពលរដ្ឋតិចពេក ឬមានភូមិសាស្ត្ររាយប៉ាយពិបាកក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍
- ក្រោយពេលរំសាយ និងបង្រួមបញ្ចូលគ្នាហើយ មានចំនួនប្រជាពលរដ្ឋយ៉ាងហោចណាស់ស្មើនឹងភូមិដែលទើបបង្កើតថ្មី
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលនៃភូមិដែលត្រូវរំសាយ និង បង្រួមបញ្ចូលគ្នានោះគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ណាមួយដែលនៅជិតខាងជាប់គ្នា ។

លក្ខណៈសម្បត្តិខាងលើនេះមិនត្រូវយកមកអនុវត្តចំពោះភូមិប្រជាពលរដ្ឋជនជាតិដើមភាគតិចឡើយ ។

មេឃុំ ចៅសង្កាត់នៅពេលដែលពិនិត្យឃើញមានតម្រូវការចាំបាច់ក្នុងការបង្កើតភូមិថ្មី ឬការបំបែក ឬរំសាយ និងបង្រួមភូមិ ត្រូវចាត់ឱ្យមានគណៈកម្មការមួយ ដើម្បីស្រាវជ្រាវ រៀបចំរបាយការណ៍ និងឯកសារផ្សេងៗទៅសុំការសំរេចពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់សំរេចឯកភាពលើសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយភូមិ និងបង្រួមបញ្ចូលគ្នានោះ មេឃុំ ចៅសង្កាត់ត្រូវលើកសំណើទៅអភិបាល

ខេត្ត ក្រុងសាមី ។ ក្រោយពីទទួលបានសំណើ អភិបាលខេត្ត ក្រុងត្រូវចាត់អោយធ្វើការពិនិត្យ និងវាយតំលៃតាមលក្ខណៈវិនិច្ឆ័យខាងលើនេះ ។ ករណីពិនិត្យឃើញថា សំណើនេះមានលក្ខណៈសមស្របហើយ អភិបាលខេត្ត ក្រុងត្រូវសុំការសំរេចពីក្រសួងមហាផ្ទៃ ។ ការបង្កើតភូមិថ្មី ឬការបំបែក ឬការរំសាយ និងការបង្រួមភូមិ ត្រូវធ្វើដោយប្រកាសក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានហេតុផលគ្រប់គ្រាន់បញ្ជាក់ថា សំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិណាមួយដែលមិនស្របតាមលក្ខណៈវិនិច្ឆ័យ និងមិនអនុវត្តតាមបែបបទខាងលើនេះ ក្រសួងមហាផ្ទៃអាចបដិសេធសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិនោះ រួចហើយត្រូវណែនាំអោយរៀបចំសំណើជាថ្មី ឬអាចផ្អាកការបង្កើតភូមិថ្មី ឬការបំបែក ឬការរំសាយ និងបង្រួមភូមិនោះ ដោយភ្ជាប់ជាមួយនូវការណែនាំអំពីវិធានការចាំបាច់នានាក្នុងការលើកកំពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍ភូមិទាំងនោះ ។

យោងតាមសេចក្តីណែនាំនេះ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវនូវសេចក្តីណែនាំនេះ ។ អភិបាលខេត្ត ក្រុងនីមួយៗត្រូវផ្អែកតាមសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្ម ដូចមានចែងក្នុងប្រកាសក្រសួងមហាផ្ទៃលេខ ១៨៨៤ ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ដើម្បីជួយគាំទ្រដល់ឃុំ សង្កាត់អនុវត្តឱ្យបានសំរេចនូវសេចក្តីណែនាំនេះ ។

សេចក្តីណែនាំនេះមានប្រសិទ្ធភាពចាប់ថ្ងៃចុះហត្ថលេខា និងឡាយព្រះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០៦

**ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

<u>**ចម្លងជូន**</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ទីស្តីការក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល
  "ដើម្បីជូនជ្រាប"
- អគ្គលេខាធិការដ្ឋាន
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល
- គ្រប់សាលាខេត្ត ក្រុង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

11